ជំនួយស្មារតី

# សទ្ទានុក្រម

# ៦

សាស្ត្រាចារ្យ ទូច-គីមស្រ៊ាង
សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព. ស. ២៥៥៨ គ. ស. ២០១៥

ជំនួយស្មារតី

# សទ្ទានុក្រម

# ទ


សាស្ត្រាចារ្យ ទូច-គីមស្រ៊ាង
សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ



ព. ស. ២៥៦៣ គ. ស. ២០១៩

**សន្ធានុក្រម ៈ**

រៀបរៀង : លោក **ទូច-គីមស្រ៊ាន** បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ

ជំនួយការ : លោក **អ៊ុន-សុនា** បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ

ឧត្តមទីប្រឹក្សា : ព្រះតេជព្រះគុណ **យស-ហ៊ុត** ខេមចារោ

: ព្រះតេជព្រះគុណ **លឹម-ថេង** សោតណោ

: ឯកឧត្តម នាយឧត្តមសេនីយ៍ **តេង-សាវង្ស**

: ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ម-សំ**

: ឯកឧត្តម ឧត្តមសេនីយ៍ទោ **អៀ-សាវ៉ន**

: លោក **អៀង-សុធារ៉ា** ប្រធានមូលនិធិអៀង

ពិនិត្យអក្ខរាវិរុទ្ធ : ព្រះមហា **វ៉ែន-វិបុល** : លោក **អៀង-ពិសី**

: កញ្ញា **ផៃ-សារ៉ែម** : កញ្ញា **ចាន់-នីតា**

: កញ្ញា **និញ-នីណា** : លោក **តោគ-ច័ន្ទវិបុល**

: លោក **វ៉ាន់-ផល្លី** : លោក **ប៊ុត-សុផល**

: លោក **សុខ-ធម្មតាសី** : លោក **ហ៊ិន-ស៊ីនី**

រចនាក្រប : កញ្ញា **នូ-ស៊ីនួន** រោងពុម្ព JSRC Printing House

ISBN-9 789996 3705571 រក្សាសិទ្ធិគ្រប់យ៉ាង ©

បោះពុម្ពលើកទី១ : ១៥កើត ខែមាឃ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

: ត្រូវនឹងថ្ងៃអង្គារ ទី៣ ខែកុម្ភៈ គ.ស. ២០១៥

ឧបត្ថម្ភបោះពុម្ព : **សប្បុរសជន**

អាសយដ្ឋានចែកចាយ : បណ្ណាល័យ សកលវិទ្យាល័យ វិទ្យាល័យ អនុវិទ្យាល័យ...

**“ការថតចម្លងស្នាដៃរៀបរៀងនៃអ្នកនិពន្ធមកធ្វើអាជីវកម្មជាអំពើល្មើសច្បាប់”**

# អារម្ភកថា

សៀវភៅ សទ្ទានុក្រម រ នេះដែលព្រះតេជព្រះគុណ សម្ដេច ទ្រង់ ឯកឧត្ដម ឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ប្រិយមិត្តកំពុងតែអាន ខ្ញុំបានប្រើពេលវេលាយ៉ាងយូរក្នុងការរៀបរៀងសៀវភៅនេះឡើង ដោយគោលបំណងបំពេញទៅតាមសំណូមពរលោកគ្រូ អ្នកគ្រូ និស្សិត អ្នកសិក្សាស្រាវជ្រាវទាំងឡាយ ដើម្បីយល់ដឹងពីគំនិតល្អៗជាច្រើននៃ សទ្ទានុក្រម រ ដែលមនុស្សទូទៅមិនទាន់បានយល់ដឹងច្បាស់លាស់ទៅលើការសរសេរពាក្យដែលមានព្យញ្ជនៈ រ នៅខាងចុងនិងកំណត់ចំណាំពាក្យទាំងនោះឱ្យបានត្រឹមត្រូវតាមលក្ខណៈអក្ខរាវិរុទ្ធខ្មែរនៅឡើយ។

ការប្រមូលស្នាដៃរបស់អ្នកនិពន្ធទាំងឡាយតាំងពីអតីតកាល មករៀបរៀងជាសៀវភៅនេះឡើង គឺមានគោលបំណង គោលដៅ វិសាលភាព និយមន័យ បទពិសោធ ទស្សនៈបុរាណ ទស្សនៈថ្មីៗ ដើម្បីចូលរួមចំណែកអភិរក្សនិងអភិវឌ្ឍវិស័យភាសាខ្មែរយើង។

ក្នុងការសិក្សាកន្លងទៅគេបានកំណត់ថា **ភាសា អក្សរសាស្ត្រ** ជាមែកធាងសំខាន់ជាងគេនៃវប្បធម៌ ជាមេនៃប្រាជ្ញា ជាមេនៃការសិក្សា ជាមេនៃសិល្បៈ ជាអត្តសញ្ញាណជាតិយ៉ាងសំខាន់បំផុត។

ប្រសិនបើមានកំហុសឆ្គងខ្វឹមសារដោយប្រការណាមួយ សូមអ្នកសិក្សាមេត្តាអធ្យាស្រ័យផងចុះ។ ខ្ញុំរង់ចាំទទួលយកកំហុសឆ្គងខ្វឹមសារអក្ខរាវិរុទ្ធដោយសុច្ឆន្ទៈមនសិការសោមនស្សគំនិតកែលម្អពីសំណាក់លោកអ្នកសិក្សាទាំងឡាយ។

រាជធានីភ្នំពេញ ១៥កើត ខែមាឃ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃអង្គារ ទី៣ ខែកុម្ភៈ គ.ស.២០១៥

សាស្ត្រាចារ្យ **ខូច-គីមស្រ៊ាង**

# **កតញ្ញូកតវេទិកថា**

កូនសូមក្រាបថ្វាយបង្គំលើកហត្ថាប្រណម្យឧទ្ទិសស្នាដៃនេះ គោរពជូនចំពោះលោកឪពុក **ទ្រី-យ៉េន** និងអ្នកម្ដាយ **អ៊ី-មាស** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃជីវិតកូន។

កូនសូមគោរពសម្ដែងកតញ្ញូកតវេទិតាធម៌ ជាអនេកប្បការចំពោះលោកមានគុណទាំងទ្វេ ដែលបានផ្ដល់កំណើតដល់រូបកូននិងបានចិញ្ចឹមបីបាច់ថែរក្សាការពារអប់រំរូបកូនឱ្យឃ្លាតចាកឆ្ងាយពីអវិជ្ជា។ ព្រះគុណដ៏មហាប្រសើរនេះរូបកូនចងចាំអស់មួយជីវិតហើយមិនអាចរកអ្វីយកមកតបស្នងសងគុណឱ្យស្មើបានឡើយ។

សៀវភៅដែលកូនបានរៀបរៀងនេះគ្រាន់តែជាស្នាដៃតូចមួយប៉ុណ្ណោះ តែវាជាសក្ខីភាពមួយបញ្ជាក់ថា រូបកូនមិនបណ្ដោយពេលវេលាឱ្យកន្លងផុតទៅដោយឥតប្រយោជន៍នោះទេ ហើយក៏មិនប្រើពេលវេលាដើម្បីប្រព្រឹត្តអំពើមិនគួរគប្បីណាមួយនោះដែរ។

កូនសូមគោរពសច្ចាប្រណិធានប្រព្រឹត្តតែកុសលកម្មនិងរស់នៅជាពលរដ្ឋល្អក្នុងសង្គមជាតិជារៀងរហូត។

រាជធានីភ្នំពេញ ១៥កើត ខែមាឃ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃអង្គារ ទី៣ ខែកុម្ភៈ គ.ស.២០១៥

សាស្ត្រាចារ្យ **ទ្វូច-គីមស្រ៊ាន**

## **ឧទ្ទិសកថា**

សូមឧទ្ទិសស្នាដៃនេះគោរពថ្វាយ ប្រគេន ជូនចំពោះ

❖ បុព្វបុរសខ្មែរស្នេហាជាតិដែលបានធ្វើពលិកម្មគ្រប់យ៉ាងការពារជាតិមាតុភូមិ

❖ អ្នកប្រាជ្ញ បណ្ឌិត កវី អ្នកនិពន្ធខ្មែរគ្រប់ជំនាន់ដែលបានខិតខំថែរក្សា ការពារវប្បធម៌ ភាសា អក្សរសាស្ត្រជាតិឱ្យបានរីកចម្រើនគង់វង្សរហូតមក

❖ សម្តេចព្រះមហាសុមេធាធិបតី **ជួន-ណាត** ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី១ នៃគណៈមហានិកាយ ដែលព្រះអង្គបានបន្សល់ទុកស្នាព្រះហស្តដ៏ពិសេសសម្រាប់ខ្មែរគ្រប់ជំនាន់គឺ **វចនានុក្រមខ្មែរ**

❖ បុព្វការីជនរបស់ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទទាំងអស់

សូមជួយទ្រទ្រង់វិស័យវប្បធម៌ អក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ច។

រាជធានីភ្នំពេញ ១៥កើត ខែមាឃ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃអង្គារ ទី៣ ខែកុម្ភៈ គ.ស.២០១៥

សាស្ត្រាចារ្យ **ទូច-គីមស្រ៊ាង**

នាមសប្បុរសជនអ្នកមានឧបការគុណក្នុងការងារធម្មទាន
ដែលបានលះបង់សេចក្តីសុខផ្ទាល់ខ្លួនគ្រប់យ៉ាងដើម្បីអត្ថប្រយោជន៍បណ្តុះ
ពូជពន្លឺបញ្ញាបារមីផ្សព្វផ្សាយវប្បធម៌អក្សរសាស្ត្រខ្មែរយើងដល់សង្គមជាតិ
និងដើម្បីដំណើរការសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

❖ មូលនិធិអៀង

❖ មណ្ឌលព័ត៌មានស្ត្រីកម្ពុជា

❖ CAM-PAINT ថ្នាំពណ៌ជាតិ

❖ មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន

| | | | |
|---|---|---|---|
| ❖ មហាឧបាសិកា | សុខ-អ៊ីម | និងបុត្រ | ឆ្វ-ឆៃគៀង |
| ❖ ឧបាសក | ដាំ-គុយ | និងឧបាសិកា | សុខ-ពៅ |
| ❖ ឧបាសក | អៀង-អឿន | និងឧបាសិកា | អៀង-សាតឹម |
| ❖ ឧបាសិកា | ហេង-ហ៊ាង | និងកូនចៅ | ហេង-ចំណូល |
| ❖ ឯកឧត្តម | តេង-សាវង្ស | និងលោកជំទាវ | ស៊ាង-តឹម |
| ❖ ឯកឧត្តម | ម៉ម-សំ | និងលោកជំទាវ | អ៊ុត-បុប្ផាផល្គុណា |
| ❖ ឯកឧត្តម | អឿ-សារ៉ន | និងលោកជំទាវ | ពៅ-សាអឿន |
| ❖ ឯកឧត្តម | ប៉ែន-វចិត្រ | និងលោកជំទាវ | ដេន-សុភ័ក្ត្រនារី |
| ❖ ឯកឧត្តម | គាង-ហៀង | និងលោកជំទាវ | លី-តឹមមួយ |
| ❖ ឯកឧត្តម | ចាន់-សារ៉េត | និងលោកជំទាវ | ស៊ីម-ថារី |
| ❖ ឯកឧត្តម | ពេជ-សាវឿន | និងលោកជំទាវ | ឈិម-ស៊ីថន |
| ❖ ឯកឧត្តម | ម៉ម-ឈាង | និងលោកជំទាវ | ឯម-មុំ |
| ❖ ឯកឧត្តម | លី-វណ្ណានី | និងលោកជំទាវ | ប្រាក់-ចិន្តា |

| | | | |
|---|---|---|---|
| ❖ ឯកឧត្ដម | ស៊ិន-ច័ណ្ឌី | និងលោកជំទាវ | ហែន-ស្រីឡែន |
| ❖ ឯកឧត្ដម | ឆាង-សុជីវី | និងលោកជំទាវ | ប៊ាង-ឆវី |
| ❖ ឯកឧត្ដម | ហង្ស-ចិន្ដា | និងលោកជំទាវ | ឆាង-ឆាថនល័ក្ខណ៍ |
| ❖ លោក | សោម-សម្បត្តិ | និងលោកស្រី | អ៊ុក-ចន្ថា |
| ❖ លោក | ចាន់-សេរី | និងលោកស្រី | តាំង-មនោ |
| ❖ លោក | ហេង-ឃាង | និងលោកស្រី | លី-មុយឡេង |
| ❖ លោក | តីវ-សុខា | និងលោកស្រី | កៀង-សម័យ |
| ❖ លោក | អៀង-ណារិន | និងលោកស្រី | ប្រាក់-សេដ្ឋាវី |
| ❖ លោក | ពីវ-វ៉ាន់ឌី | និងលោកស្រី | ប៊ាង-សុជាតា |
| ❖ លោក | អេង-យូលីម | និងលោកស្រី | ឆន់-ហ៊្លិចហ្លួយ |
| ❖ លោក | អេង-ហ៊ី | និងលោកស្រី | លីម-ខេង |
| ❖ លោក | គុយ-វ៉ាត | និងលោកស្រី | ឌុយ-តីន |
| ❖ លោក | អ៊ួង-គីមសេង | និងលោកស្រី | ជា-លីណា |
| ❖ លោក | ឃាង-ច័ន្ទវិទ្ធា | និងលោកស្រី | លី-ហាក់ហៀង |
| ❖ លោក | យៀង-សុគន្ធា | និងលោកស្រី | សូ-សុផាន់ណាវី |
| ❖ លោក | ថាវ-វណ្ណា | និងលោកស្រី | ម៉ី-សុខឌី |
| ❖ លោក | នុត-រ៉ានី | និងលោកស្រី | អ៊ុន-សោភា |
| ❖ លោក | នុត-វុទ្ធី | និងលោកស្រី | កែន-ប៊ុណ្ណា |
| ❖ លោក | នួន-សុខា | និងលោកស្រី | អ៊ូច-វណ្ណាថា |
| ❖ លោក | យិន-សារិទ្ធ | និងលោកស្រី | ឡឿន-សុគន្ធា |
| ❖ លោក | សួវ-ឆាយ | និងលោកស្រី | ប៊ី-សុតី |

- លោក ច្រឹក-សុខនឹម និងលោកស្រី ហៀង-ឆវី
- លោក ឈី-ចាន់ឡឿន និងលោកស្រី ផូ-ដាលីស
- លោក នួន-ហ៊ិន និងលោកស្រី ឈឹម-ចន្ទ័កែវ
- លោក ចាន់-ធីតា និងលោកស្រី ជឹម-ស្រីមនោ
- លោក ស៊ូវ៉ាត-តស្ណា និងលោកស្រី ឈឹម-ឡាលីន
- លោក តឹម-ទីរៈ និងលោកស្រី ភូ-ជីនជីន
- លោក ហ៊ិង-បូរ៉ា និងលោកស្រី អូម-សោភា
- លោក ឡុង-និត្យ និងលោកស្រី ពេជ្រ-ណារី
- លោក តឹម-ប៊ុន្នី និងលោកស្រី សុភ-ស្រី

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណជាអតិបរមាចំពោះឧត្តមភរិយា **ម៉ែន-សេងយ៉ុង** ហៅ **ស្រីចិន** និងក្រុមគ្រួសារដែលបានយោគយល់និងចែករំលែកពេលវេលាដើម្បីឱ្យខ្ញុំអាចមានឱកាសសិក្សាស្រាវជ្រាវប្រកបដោយជោគជ័យ។

ជាពិសេស ខ្ញុំសូមគោរពសម្តែងការដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **សប្បុរសជន** ដែលមានសន្តានចិត្តសប្បុរិសធម៌ឧបត្ថម្ភធម្មទានថវិកាបំពេញបញ្ញាបារមីបោះពុម្ពសៀវភៅសទ្ទានុក្រម រ ក្នុងគោលដៅសំខាន់ផ្សព្វផ្សាយអក្សរសាស្ត្រខ្មែរ ដើម្បីឱ្យប្រជាពលរដ្ឋទូទៅបានយល់ដឹងពីផលប្រយោជន៍នៃគុណតម្លៃវប្បធម៌ ភាសា អក្សរសាស្ត្រជាតិ ព្រមទាំងដើម្បីឱ្យដំណើរការ **សមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ**។

សូមថ្លែងអំណរគុណឯកឧត្តម លោកជំទាវ សប្បុរសជន លោកអ្នកអាន ដែលបានជួយលើកស្ទួយគុណតម្លៃស្នាដៃរៀបរៀងសៀវភៅរបស់ខ្ញុំ សូមមេត្តាអធ្យាស្រ័យកំហុសឆ្គងដោយប្រការផ្សេងៗ។ ខ្ញុំនឹងរីករាយទទួលយកការកែលម្អកំហុសដើម្បីឱ្យខ្ញុំបានបម្រើអស់លោកអ្នកអានកាន់តែប្រសើរជាងមុនថែមទៀត។

រាជធានីភ្នំពេញ ១៥កើត ខែមាឃ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃអង្គារ ទី៣ ខែកុម្ភៈ គ.ស.២០១៥

សាស្ត្រាចារ្យ **ទូច-តីមស្រ៊ាង**

# អក្សរសង្ខេប

## ប្រើក្នុងសទ្ទានុក្រម វ នេះ

| | | |
|---|---|---|
| *កិ.* | : | កិរិយាសព្ទ |
| *កិ.នុ.* | : | កិរិយានុគ្រោះ |
| *កិ.វិ.* | : | កិរិយាវិសេសន៍ |
| *គ.ស.* | : | គ្រិស្តសករាជ |
| *គុ.* | : | គុណសព្ទ |
| *ន.* | : | នាមសព្ទ |
| *និ.* | : | និបាត |
| *ប.* | : | បរិវារសព្ទ |
| *ប.សំ.* | : | បកតិសំខ្យា |
| *បា.* | : | បាលី |
| *បា.ក្ល.* | : | បាលីក្លាយ |
| *បា.សំ.* | : | បាលីនិងសំស្រ្កឹតលាយគ្នា |
| *បា.សំ.ក្ល.* | : | បាលីនិងសំស្រ្កឹតក្លាយ |
| *បារ.* | : | បារាំង |
| *បុ.ស.* | : | បុរិសសព្វនាម |
| *ព.កា.* | : | ពាក្យកាព្យ |
| *ព.ទ.បុ.* | : | ពាក្យទំនឹមបុរាណ |
| *ព.បុ.* | : | ពាក្យបុរាណ |

| | | |
|---|---|---|
| *ព.ប្រ.* | : | ពាក្យប្រៀបធៀប (ពាក្យប្រើចំពោះ) |
| *ព.ស.* | : | ពុទ្ធសករាជ |
| *ព.សា.* | : | ពាក្យសាមញ្ញ (ពាក្យធម្មតាឬពាក្យផ្សារ) |
| *រ.ស.* | : | រាជសព្ទ |
| *វេវ.* | : | វេវចនៈ |
| *ស.* | : | សៀម (ភាសាសៀម) |
| *សំ.* | : | សំស្ក្រឹត |
| *សំ.ក្ល.* | : | សំស្ក្រឹតក្លាយ |
| *សំ.ស.* | : | សំស្ក្រឹតសន្មត |
| *អា.និ.* | : | អាយតនិបាត |
| *ឧ.* | : | ឧទានសព្ទ |

# សទ្ទានុក្រម ក

**កករ** *ន.* ផង់ឬកម្ទេចល្អិតដែលនៅក្នុងសភាវៈរាវមាន ទឹក, ស្រា, ប្រេង ជាដើម :

❖ កករប្រេង។

១. **កករចិត្ត** : ចិត្តសៅហ្មងហាក់ដូចជាមានកករ។

☞ ប្រើដូចជា *គុ.* ក៏បាន ចិត្តកករល្អក់។

**កកូរ** *កិ.* កូរញោយៗ :

❖ កកូរត្រុំឬសម្ល។

*ន.* ឈ្មោះសម្លខ្មែរមួយប្រភេទ :

❖ សម្លកកូរ។

**កកេរ** *កិ.* ខាំរឿយៗដើម្បីឱ្យដាច់ :

❖ កកេរពោត

❖ កណ្ដុរកកេរទូ។

**កង្វារ** *ន.* ប្រដាប់សម្រាប់ខ្វារ :

❖ កង្វារក្ដាម

❖ កង្វារកង្កែប

❖ កង្វារត្រចៀក។

**កង្វេរ** *ន.* ប្រដាប់មានផ្លែក្ងក់ធ្វើដោយដែកមានដងធ្វើដោយឈើសម្រាប់ការដំរី។

**អន្ទារ** *ន.* ប្រដាប់មានស្លាបដែលអាចនឹងវិលដោយកម្លាំងខ្យល់បាន។

**អន្ទាវ** *ន.* ឈ្មោះខេត្តមួយក្នុងដែនកម្ពុជាក្នុងកាលអំពីដើម (ឥឡូវរួមក្នុងខេត្តក្រចេះ)។

**អនិភារ** (ធា.) *ន.* ឈ្មោះផ្កាឈើមួយប្រភេទមានផ្កា-សសណ្ឋានប្រហែលនឹងផ្កាម្លិះក្លិនក្រអូប។

**អណ្ដាវ** *ន.* ដែកសម្រាប់ក្ដារ (គ្រឿងជាងឈើ) :

- ដែកកណ្ដារ។

**អណ្ដុរ** *ន.* សត្វចតុប្បាទតូចមួយប្រភេទ ក្នុងពពួកសត្វមានដោះជាសត្វឱ្យទុក្ខដល់មនុស្សដោយហេតុបំផ្លាញមានកាត់សំពត់អាវជាដើម។ កណ្ដុរមានច្រើនយ៉ាង :

- កណ្ដុរល្មេះ
- កណ្ដុរប្រេង។

**អណ្ដៀវ** *ន.* ឈ្មោះសត្វល្អិតមួយពួកក្នុងពួកកណ្ដាច់ចេះពូនដីឱ្យកើតជាដំបូកជាត្រោកបាន។

**អន្ដារ** (ធា.) *ន.* ផ្លូវលំបាកឬផ្លូវដែលច្រើនប្រកបដោយគ្រោះថ្នាក់ :

- **ចោរកន្ដារ** : ផ្លូវលំបាកព្រោះចោរ។
- **ទុព្ភិក្ខកន្ដារ** : ផ្លូវលំបាកព្រោះគ្មានបាយ។
- **និរុទកកន្ដារ** : ផ្លូវលំបាកព្រោះគ្មានទឹក។

🙞 **វាឡកន្តារ** : ផ្លូវលំបាកព្រោះសត្វសាហាវ។

🙞 **អមនុស្សកន្តារ** : ផ្លូវលំបាកព្រោះអមនុស្សមានយក្សជាដើម។

**កន្ទរ** *ន.* ឈ្មោះត្រីស្រកាមួយប្រភេទមានរូបប្រហែលនឹងត្រីកំភ្លាញតែធំជាង :

❖ ត្រីកន្ទរ

❖ ងៀតកន្ទរ។

**កម្ទរ** *កិ.* ឬ *កិ.វិ.* ធ្វើឱ្យខ្ទរ, ធ្វើឱ្យលាន់ឮសាយ :

❖ កម្ទរសម្ដី

❖ វាយស្គរកម្ទរ។

**កម្ទារ** *កិ.* ធ្វើឱ្យខ្ទារ, ស្រែកឱ្យលាន់ឮកងរំពងឡើង :

❖ កម្ទារសម្ដី

❖ ស្រែកកម្ទារ។

☞ បំប៉ោងរោមនិងស្លាបឱ្យប៉ោងពង់ឡើងស្ទុះទៅរកញី :

❖ ក្ងោកឈ្មោលពង់កម្ទារទៅរកញី។

**កម្មករ** (បា.) *ន.* អ្នកធ្វើការបម្រើដោយឈ្នួល (អ្នកស៊ីឈ្នួល) :

❖ ពួកកម្មករកំពុងធ្វើការខ្សៀវ។

**កប៌ូរ** (សំ.) *ន.* ជ័រមួយយ៉ាងមានក្លិនប្រហើរឆ្អួលសម្រាប់ប្រើជាថ្នាំឈឺក្បាល, ជ័រមួយយ៉ាងមានក្លិនប្រហើរឆ្អួលសម្រាប់ប្រើជាថ្នាំតឹងច្រមុះ។

**ករ** (បា.) *ន.* ដៃ :

❖ លើកករប្រណម្យ។

**កសិករ** (បា.) *គុ.* ឬ *ន.* អ្នកធ្វើកសិកម្ម។

**កាកនាសូរ** (សំ.) *ន.* ឈ្មោះក្អែកមួយមានក្បាលជាយក្សក្នុងរឿងរាមកេរ្តិ៍។

**ការ** *កិ.* មូរសរសៃសូត្រ, មូរសរសៃអំបោះ ជាដើមដោយខ្នារ :

- ការសូត្រ
- ការអំបោះ។

*កិ.* បិទបាំង, រាំងរា, ឃាត់ឃាំង, ការមិនឱ្យសត្រូវចូលមក, ការខ្លួន :

- មេមាន់ការកូន។

*កិ.* រៀបចំអាវាហវិវាហមង្គល, ផ្សំផ្គុំបុរសនិងស្ត្រីឱ្យបានជាគូស្វាមីភរិយា :

- ការកូន
- ការក្មួយ។

*ន.* កិច្ចដែលត្រូវធ្វើ, អំពើដែលត្រូវធ្វើ :

- ធ្វើការ
- មានការ។

*ន.* ពាក្យសម្រាប់ប្រើដាក់ខាងដើមពាក្យដែលជាកិរិយាសព្ទផ្សេងៗដើម្បីធ្វើឱ្យទៅជា នាមសព្ទ ដូចជា :

- សំពះ *កិ.* ការសំពះ *ន.* ...។

**ការងារ** *ន.* កិច្ចដែលត្រូវធ្វើតាមមុខងាររបស់ខ្លួន :

- ធ្វើការងារ

❖ មានការងារ។

**ការពារ** *កិ.* ឃាត់ឃាំង, រាំងរា, មិនឱ្យសត្រូវចូលដល់ខ្លួនឬដល់លំនៅដោយគ្រឿងអាវុធឬគ្រឿងរាំងមានរបងនិងកំពែងជាដើម។

**កិន្នរ** (បា.សំ.) *ន.* ឈ្មោះបក្សីមួយប្រភេទ ថាមានរូបដូចមនុស្សមានស្លាបហើរបាន មាននិយាយតែក្នុងរឿងបុរាណ។ បើញី កិន្នរី។

**កុញ្ជរ**(បា.សំ.) *ន.* សត្វចតុប្បាទមានប្រមោយ (ដំរី)។

*គុ.* ប្រសើរ, ខ្ពង់ខ្ពស់។

**កុបករ** (បា.) *ន.* អ្នកបះបោរ, អ្នកនាំបង្កហេតុជ្រួលជ្រើម។

**កុមារ** (បា.សំ.) *ន.* ក្មេងប្រុស។

**កុម្ភការ** (បា.) *ន.* អ្នកធ្វើក្អមឆ្នាំង, អ្នកធ្វើភាជនៈដី, ស្មូនឆ្នាំង។

**កុរ** *ន.* ឈ្មោះឆ្នាំទី១២ (ជ្រូក)។

**កូនកណ្ដុរ** *ន.* ឈ្មោះរោគដុំមួយយ៉ាងមានសណ្ឋានប្រហែលនឹងគ្រាប់ខ្នុរច្រើនកើតតែនៅមណ្ឌល-ក, ក្រលៀន, ក្លៀក :

❖ ឡើងកូនកណ្ដុរនៅក។

**កូរ** *កិ.* ធ្វើវត្ថុរាវឱ្យកម្រើក, ធ្វើវត្ថុរាវឱ្យវិលដោយយកអ្វីៗទៅវឹក :

❖ កូរនំ

❖ កូរបបរ។

*ន.* ឈ្មោះនំមួយប្រភេទធ្វើពីម្សៅនិងស្ករកូរលាយចូលគ្នា :

❖ នំកូរ។

**ក្ទួរ** *ន.* ចង្កោមផ្លែ, សំណុំផ្លែ :

❖ ក្ទួរស្រូវ

❖ ក្ទួរស្ពៅ។

☞ ចំពោះអម្ពិលនិងសណ្ដែកទ្រើងគេហៅសំដៅយកតួផ្លែតែម្ដងថា ក្ទួរ :

❖ ក្ទួរអម្ពិល

❖ សណ្ដែកមួយក្ទួរ។

**កៀរ** *កិ.* ជួតដោយខ្សែ, ប្រមូលដោយខ្សែ; ប្រមូលនាំយកទៅ។

**កៀរគរ** *កិ.* កៀរឱ្យបានជាគំនរ, ប្រមូលឱ្យបានច្រើន :

❖ ខំដើរកៀរគរ។

☞ និយាយបញ្ចុះបញ្ចូលផ្សេងៗពីនេះខ្លះពីនោះខ្លះដើម្បីឱ្យគេចុះចូល :

❖ និយាយកៀរគរ ។

**កេរ** *ន.* ដំណែលជាសម្បត្តិរបស់ដូនតាឬមាតាបិតាជាដើម :

❖ ស្រែនេះជាកេររបស់ដូនតាខ្ញុំ

❖ ប្រាសាទនគរវត្តជាកេររបស់ព្រះមហាក្សត្រជាបុព្វបុរសរបស់ខ្មែរ។

**កេសរ** (**បា.សំ.**) *ន.* លំអងផ្កា, កេសរផ្កា។

☞ សំណុំរោមវែងៗត្រង់កសត្វចតុប្បាទមាន **សីហៈ** ជាដើម។

**កោរ** *កិ.* កាត់រំលីងដោយកាំបិតកោរ :

❖ កោរសក់

❖ កោរពុកចង្កា។

**កោសេយ្យទប្បករ** (បា.) *ន.* អ្នកចិញ្ចឹមនាង, អ្នកប្រកបមុខរបរស្លូត្រ។

**កំចាយមារ** *ន.* ឈ្មោះស្រុកមួយក្នុងខេត្តព្រៃវែង :

❖ ស្រុកកំចាយមារ។

**កំដរ** *កិ.* ឬ *កិ.វិ.* ធ្វើឱ្យបានជាគ្នា :

❖ ដេកកំដរ

❖ ទៅកំដរគេ។

**កំណាត់** *ន.* របស់សម្រាប់ការខ្លួន។

**កំណៀរ** *ន.* ការកៀរដោយខ្មៀរ, ការប្រមូលដោយខ្មៀរ :

❖ កំណៀរអាចម៍ដី

❖ កំណៀរពពុះទឹក។

☞ អ្វីៗដែលគេកៀរយកទៅឬយកមក :

❖ របស់កំណៀរ។

**កំណោរ** *ន.* មនុស្សដែលមានសក់កោរ; ជាងកោរសក់; ក្បាលដែលកោរ :

❖ ជាងកំណោរ

❖ ក្បាលកំណោរ

❖ សមណៈកំណោរ។

**កំបោរ** *ន.* វត្ថុមានសាច់ផុសផង់មានពណ៌សកើតអំពីថ្មមួយយ៉ាងដែលដុត សុសឬអំពីសំបកលៀស, គ្រំជាដើមដែលគេដុតឱ្យសុស :

❖ កំបោរថ្ម

❖ កំបោរលៀស។

**កំពូរ** *គុ.* ដែលមានស្នាមរវើមរវាមសណ្ឋានប្រហែលនឹងពួរ :

❖ ជើងកំពួរ។

**កំភរ** *ន.* ឈ្មោះត្រីស្រកាមួយប្រភេទរាងវែងកន្ទុយមានឆ្នូតក្រហម, ខ្លួនមានខ្មៅមួយដុំសងខាង :

❖ ត្រីកំភរ។

*គុ.* ដែលចូលចិត្តតែខាងភរកុហកឬធ្លាប់តែភរកុហក, ដែលមិនពិត :

❖ ពាក្យកំភរ

❖ មនុស្សកំភរ។

**កុះករ** *គុ.* ច្រើន, បរិបូណ៌, សម្បូណ៌, ដេរដាស :

❖ ស្រុកនេះមានមនុស្សកុះករ។

**ក្ខូរ** *គុ.* ដែលមានសំឡេងរលំនិយាយមិនសូវច្បាស់ដោយខ្យល់ចេញពីច្រមុះច្រើនព្រោះខូចមណ្ឌលច្រមុះឬធ្លុះគល់ក្រអូម, ដាច់កន្ទើត :

❖ មនុស្សក្ខូរ

❖ សំឡេងក្ខូរ។

**ក្ដារ** *កិ.* ខារទម្លុះ, ទម្លុះដោយដែកកណ្ដារ។

*ន.* បន្ទះឈើដែលអារមានបន្ទារធំទោលតូចសម្រាប់ប្រើការមានក្រាលជារនាបនិងបិទបាំងជាជញ្ជាំងជាដើម។

**ក្បូរ** *ឧ.* ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ ក្បាច់ :

២ **ក្បាច់ក្បូរ** : ការវិចិត្ររចនាមានក្បាច់ផ្សេងៗ។

**ក្បៀរ** *និ.* ប្រប, ខាង :

❖ ក្បៀរផ្លូវ

❖ ក្បៀរមាត់ច្រាំង។

**ក្រគរ** *ន.* ឈ្មោះស្រុកមួយក្នុងខេត្តពោធិ៍សាត់ :

❖ ស្រុកក្រគរ។

**ក្រញូរ** *ន.* ចង្អួយម្រាមដៃ :

❖ ក្រញូរដៃ។

*គុ.* ក្រញង់លាមិនរួច (និយាយបានតែពីម្រាមដៃ, ម្រាមជើង) :

❖ ម្រាមដៃក្រញូរ។

**ក្រមការ** (សំ.) *ន.* ងារក្នុងតំណែងរាជការឃុំ។

**ក្រមរ** *ន.* ខ្ទុះឈាមដែលខះនៅមុខកមដំបៅជាដើមឬសំបកឈើស្រទាប់ក្រៅ ដែលក្រៀមក្រាត :

❖ ក្រមរដំបៅ

❖ ក្រមរពោធិ៍។

**ក្រសារ** *ន.* ឈ្មោះសត្វស្លាបមានកវែងមានស្លាបសម្បុរប្រផេះ។

**ក្រឡាដុខដោរ** (ព.បុ.) *ន.* ផ្ទៃដីព្រៃ។

**ក្រូចឆ្មារ** *ន.* ឈ្មោះស្រុកមួយឋិតនៅតាមដងទន្លេមេគង្គក្នុងខេត្តកំពង់ចាម។

❖ ស្រុកក្រូចឆ្មារ។

**ក្រៃសរ** *ន.* ងារក្នុងតំណែងស្មៀន :

❖ ឃុនក្រៃសរ។

**ក្សីរ (សំ.)** *ន.* ទឹកដោះស្រស់ :

❖ ទឹកក្សីរ។

**ក្សេត្រាធិការ (សំ.)** *ន.* ឈ្មោះក្រសួងដែលបង្គាប់បញ្ជាត្រួតត្រាលើការស្រែចម្ការចម្បារដំណាំ :

❖ ក្រសួងក្សេត្រាធិការ (សព្វថ្ងៃយើងប្រើពាក្យថាក្រសួងសេដ្ឋកិច្ច)។

**ខណ្ឌាស្ករ** *ន.* ឈ្មោះថ្នាំកែរោគមួយយ៉ាងស្រដៀងនឹងស្ករក្រាម (មាននិយាយតែក្នុងក្បួនផ្សំថ្នាំពីបុរាណ)។ ឈ្មោះស្វាយមួយប្រភេទផ្លែរាងតូចខ្ចីសំបកទុំហើយក៏នៅតែបៃតងជ័រច្រើន :

❖ ស្វាយខណ្ឌាស្ករ។

**ខរ** *ន.* (**បា.សំ.** "សត្វលា; រណារ"; *ន្ទ.* កាច, រឹងរូស) ឈ្មោះយក្សមួយក្នុងរឿងរាមកេរ្តិ៍។

**ខារ** *កិ.* ទាញអូសដោយគ្រឿងចក្រ :

❖ ខារឈើហុបពីក្នុងទឹកមកលើគោក។

*ន្ទ.* ដែលស្មើរហាងស្មើរក្រពុលស្មើរខ្ជួរ :

❖ ក្លិនខារ។

*ន.* ឈ្មោះគ្រាប់មួយប្រភេទផ្លែមានរសខារ :

❖ ត្រប់ខារ (ខ្លះហៅ ត្រប់ខ្ជួរ)។

**ខុរៗ** *គុ.* ស្ងួរឮដោយស្រមុក :

❖ ស្រមុកខុរៗ។

**ខ្ជូរ** *ន.* អាការៈនៅក្នុងក្បាលឬក្នុងឆ្អឹងខាប់ដូចចាហួយ :

❖ ខួរឆ្អឹង

❖ ខួរក្បាល។

**ខោរ** *ន.* ឈ្មោះស្វាមួយពួកសម្បុរខ្មៅជាងស្វាក្រិសរូបធំមុខខ្លី :

❖ ស្វាខោរ។

**ខ្ជូរ** *កិ.* ខ្ជូរ, ខ្ជូរខ្ជារ, លេចឮពាសពេញ :

❖ កេរ្តិ៍ឈ្មោះពីរោះខ្ជួរ។

**ខ្ជារ** *ឬ.* ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ ខ្សៀវ :

❖ ខ្សៀវខ្ជារ។

**ខ្សៀវខ្ជារ** *កិ.វិ.* ដែលទ្រហឹងអឹងកងដោយសូរសម្រែកនៃសត្វបក្សី :

❖ សារិកាកែវស្រែកខ្សៀវខ្ជារ។

**ខ្មែរ** *ន.* ឈ្មោះវល្លិមួយប្រភេទផ្លែមានមមីសរមាស់ណាស់ :

❖ វល្លិខ្មែរ

❖ ខ្មែររោល។

✍ **ដូងខ្មែរ** : ដូងដែលកើតក្នុងវល្លិខ្មែរ។

*ន.* ឈ្មោះល្ហុងមួយប្រភេទដាងវែងស្លឹកធំឆែកៗមានប្រហោងក្នុងដាង ក្លិនក្រពុលផ្លែចង្កោមៗ ក្បូរផ្លែមួយៗទំហំប៉ុនផ្លែពុទ្រាឬផ្លែកន្ទួត, មានរោម នៅសំបកដូចផ្លែសាវម៉ាវ, គ្រាប់ធ្វើជាប្រេង :

❖ ល្ហុងខ្មែរ។

**ខ្ទុរ** ***កិ.១.*** ឬ ***គុ.*** ដែលលាន់រំពងញាប់ញ័រ :

❖ ស្ងួរខ្ទុរខ្ទារ

❖ បាញ់ខ្ទុរខ្ទារ។

**ខ្ទុរខ្ទ័រ** ***កិ.១.*** ឬ ***គុ.*** ដែលលាន់រំពងញ័រសុសសាយដោយបាញ់កាំភ្លើងឬដោយ វាយស្គរធំជាដើម :

❖ បាញ់កាំភ្លើងឮខ្ទុរខ្ទ័រ។

**ខ្ទ័រ** ***កិ.*** ឬ ***កិ.១.*** ញ័រលាន់រំពងសង្កៀរត្រចៀក។

**ខ្នារ** ***ន.*** ប្រដាប់សម្រាប់ការស្ទូត្រ, ប្រដាប់សម្រាប់ការអំបោះធ្វើដោយឫស្សី បិតឬត្រែងដែលហៅថា ត្រែខ្នារគាំ ជាដើម។

*ន.* ឈ្មោះគ្រឿងប្រហារមួយមានសណ្ឋានដូចស្នាសម្រាប់បាញ់។

*ន.* ទីដីជាទួលខ្ពស់ពទ្ធជុំវិញត្រពាំងឬជាតស្រះ គឺស្រះដែលកើតឯង ដោយឥតអ្នកណាជីក, ជួនកាលគេកភូមិឬកវត្តលើទួលនោះគេហៅថា ភូមិខ្នារ, វត្តខ្នារ តាមឈ្មោះដើម។ ត្រពាំងឬជាតស្រះនោះក៏គេហៅតាម ឈ្មោះទួលនោះដែរ :

❖ ត្រពាំងខ្ទារ; បើគេបញ្ចុះដំរីឱ្យត្រាំទឹកគេហៅ ត្រាំខ្ទារ។

ខ្ទុរ ន. ឈ្មោះរោគបូសដែលច្រើនតែកើតនៅក្បាលកូនក្មេង :

❖ បូសខ្ទុរ

❖ ក្មេងកើតខ្ទុរ។

ន. ឈ្មោះឈើដំណាំមួយប្រភេទមានផ្លែជាអាហារខ្លឹមប្រើស្ងោរយកទឹកជ្រលក់សំពត់ចីវរអ្នកបួសក្នុងព្រះពុទ្ធសាសនា។ ខ្នុរមានច្រើនយ៉ាង :

❖ ខ្នុរណាំងសាច់រឹង

❖ ខ្នុរបាយស្រោសាច់ជ្រាយ។

ខ្នៀរ ន. ប្រដាប់សម្រាប់កៀរ :

❖ ខ្នៀរកៀរដីជាដើម។

ខ្ពុរ កិ. បៀមទឹកអង្រង់លាងមាត់ :

❖ បរិភោគអាហារហើយត្រូវខ្ពុរមាត់។

ខ្ជូរ កិ. ឬ គុ. រួញក្រញង់ដូចគេមួរ :

❖ ស្លឹកត្រចៀកខ្ជូរ

❖ កុំហាលស្លឹកនេះយូរពេកវាខ្ជូរខូចអស់ហើយ។

៦ **មនុស្សមុខខ្វួរ** : មនុស្សដែលអៀនខ្មាសច្រើនប្រើឱ្យទៅប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដទៃមិនបានការ។

ខ្ជូរ គុ. ខារដោយអាប់អួ :

❖ ក្លិនខ្ជួរ។

*ន.* ឈ្មោះត្រប់មួយប្រភេទមានក្លិននិងរសខារ។

**ខ្មែរ** *ន.* មនុស្សដែលកើតឬនៅក្នុងដែនកម្ពុជាហើយលុះនៅក្នុងអំណាចច្បាប់ខ្មែរ :

❖ ជាតិខ្មែរ។

**ខ្មោះខ្ជួរ** *គុ.* ដែលមានក្លិនខ្មោះនិងមានក្លិនខ្ជួរលាយគ្នា។ ដែលមានអាការៈច្រឡោះបោះ :

❖ សម្ដីខ្មោះខ្ជួរ។

*កិ.វិ.* ដែលច្រឡោះបោះ :

❖ និយាយខ្មោះខ្ជួរ។

**ខ្លោងទ្វារ** *ន.* បង្គោលមួយគូមានធ្នឹមធ្វើដោយឥដ្ឋឬដោយឈើភ្ជាប់នឹងកំពែងឬរបងមានចន្លោះជាផ្លូវសម្រាប់ដើរចេញចូលបាន :

❖ ខ្លោងទ្វារវត្ត

❖ ខ្លោងទ្វារផ្ទះ។

**ខ្វារ** *កិ.* ការទាញដោយកង្វារ :

❖ ខ្វារក្ដាម

❖ ខ្វារកង្កែប។

**ខ្វេរ** *គុ.* ដែលកោងខុបដូចកង្វេរ។

**គគីរ** *ន.* ឈ្មោះឈើធំមួយប្រភេទសាច់រឹងជាប់សម្រាប់ប្រើធ្វើទូកនិងការឯទៀតផ្សេងៗ។ គគីរមានឈ្មោះច្រើនយ៉ាង :

❖ គគីរថ្ម

❖ គគីរខ្សាច់។

**គឃរ** *កិ.វិ.* ឬ *គុ.* ដែលមានអាការៈខ្ទរ, គឃ្លើនឥតកោតញញើត :

- **ដើរគឃរ** : ដើរគឃ្លើនឥតកោតញញើត។
- **សម្ដីគឃរ** : សម្ដីក្អេងក្អាងឥតកោតញញើត។
- **អួតគឃរ** : អួតក្អេងក្អាងឥតកោតញញើត។

**គឃារ** *គុ.* ដែលស្គុយ, ដែលស្រុងពេក :

❖ បង់កសំពត់គឃារ

❖ ស្លៀកសំពត់គឃារ។

**គឃៀរ** *កិ.វិ.* ឬ*គុ.* ដែលបែកញើសហៀរហូរសស្រាក់ :

❖ បែកញើសគឃៀរ

❖ ញើសហូរគឃៀរ។

**គជសារ** *ន.* ដំរីសារ, ដំរីមានមាឌធំសម្បើម។

**គណៈកម្មការ** (បា.សំ.) *ន.* ជនមួយក្រុមឬក្រុមជំនុំដែលចាត់តាំងឡើងដោយពិធីបោះឆ្នោត ឬដោយការជ្រើសតាំងសម្រាប់ឱ្យពិនិត្យកិច្ចការណាមួយដាច់មុខដោយឡែក :

❖ គណៈកម្មការវប្បធម៌បានបង្កើតពាក្យខ្មែរថ្មីៗជាច្រើន។

**គណៈកម្មាធិការ** (បា.) *ន.* សមាជិកមួយក្រុមដែលតាំងឡើងក្នុងក្រសួងរាជការឬក្នុងសភាដើម្បីឱ្យប្រតិបត្តិសម្រេចការណាមួយ :

❖ មុខការនេះស្រេចលើគណៈកម្មាធិការ។

**គណនេយ្យករ** (បា.) *ន.* អ្នកកាន់កាប់ការខាងគណនេយ្យ។

**គន់គូរ** *កិ.* ពិចារណាដោយក្បួនវេទមានវាយលេខជាដើម :

❖ ហោរាគន់គូរ។

**គមនាការ** (បា.) *ន.* អាការៈទៅ, អាការៈដែលប្រុងធ្វើដំណើរទៅ, ដំណើរដែលប្រុងនឹងទៅ :

❖ ធ្វើគមនាការដោយទូក

❖ ធ្វើគមនាការដោយរថយន្ត។

**គម្ពីរ** (បា.សំ.ភ្ល.) *ន.* សាស្ត្រា, ច្បាប់, ធម្មវិន័យដែលរួបរួមដោយពួកដោយប៉ែកដោយខ្សែ :

❖ សាស្ត្រាមួយគម្ពីរ។

**គម្ភីរ** (បា.សំ.) *គុ.* ដែលមានជម្រៅ, ជ្រៅ។

🙤 **គម្ភីរភាព** : ភាពជ្រៅ, ជម្រៅ។

🙤 **គម្ភីរមតិ** : មតិជ្រៅ, គំនិតជ្រៅ។

🙤 **គម្ភីរបទ** : បទឬចំណែកនៃសេចក្ដីដ៏ជ្រាលជ្រៅ។

**គរ** *កិ.* ធ្វើឱ្យជាគំនរ។

**គរគោក** *កិ.វិ.* ឬ *គុ.* ដែលច្រើនពាសពេញ, ដែលច្រើនដេរដាស។

**គួរ** *កិ.* ធ្វើឱ្យកើតជាគំនូរតំណាងរូបរាងសរពើដោយដីខ្មៅ, ប៉ាកកាឬជក់ :

❖ គូររូប

❖ គូរគំនូរ

❖ គូរផែនទី។

*ម.* ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ គិត :

✍ **គិតគូរ** : គិតហើយសឹមគូរ។

**គួរ** *កុ.* សម; គប្បី; ឥតទាស់ :

❖ អ្នកថាហ្នឹងគួរហើយ

❖ ពាក្យនោះគួរហើយ។

**គួរីយេរ** (**បារ.**) *ន.* មនុស្ស, រថ, រថយន្ត, នាវាដែលដឹកនាំសំបុត្រស្នាមឬបញ្ញើផ្សេងៗជាដើម; សំណុំលិខិត, លិខិតផ្សេងៗដែលប្រមូលរួមជាសំណុំក៏ហៅថា គួរីយេរ ដែរ។

**គោចរ** (**បា.សំ.**) *ន.* វិស័យ, ដំណើរនៃឥន្ទ្រិយគឺ រូប, សំឡេង, ក្លិន, រស, សម្ផស្ស។ ដំណើរយាត្រាទៅរកអាហារចំណី, ទីដែលមានអាហារចំណី, ទីដែលសមណៈគួរត្រាច់ចរទៅបានតាមពុទ្ធានុញ្ញាត។

**គោរមងារ** ឬ **គោរម្យងារ** *ន.* របៀបពាក្យដ៏ឧត្ដមបន្ថែមតពីងារទៅទៀតជាពាក្យសរសើរងារសម្រាប់ប្រើសរសេរចំពោះតែការចេញសំបុត្រដីកាធំៗ។

**គំនរ** *ន.* អ្វីៗដែលប្រគរលើគ្នា, អ្វីៗដែលគេដាក់គរលើគ្នា :

❖ គំនរចំបើង

❖ គំនរសំរាម។

**គំនូរ** *ន.* រូបភាព, ក្បាច់រចនា, ក្បូរក្បាច់រំលេចដែលកើតមានឡើងដោយគូរ :

❖ គំនូររឿងវេស្សន្តរជាតក។

**គំនួរ** *ន.* ការសម្តែងសេចក្តីគួរសម :

📖 **គំនាប់គំនួរ** : គំនាប់យកតែគួរដោយអាការៈតោះតើយយ៉ាងស្បើយ

សោះតែគេថា។

**គាំពារ** *កិ.* អបអង, ជួយ, ទំនុកបម្រុង :

❖ ឯងកុំចោលវាគួរជួយគាំពារគ្នាផង។

**គ្នាន់គ្នេរ** *កិ.* រិះរេគិតលៃលកមើល។

**គ្នេរ** *កិ.* រិះរេមើល, គិតលៃលក :

❖ នឹងធ្វើការអ្វីៗត្រូវគ្នេរមើលឱ្យស្រួលសិន។

**គ្រជួរ** *កិ.* ឬ *គុ.* ក្រញូវ, ដែលក្រញូវមុខជូរ :

❖ មុខគ្រជូរ

❖ ខឹងគ្រជូរ។

**គ្រមរ** *គុ.* រលឬក្រាស់ដោយព្រមរឥតរាង, មិនសម :

❖ ធំគ្រមរ

❖ រាងគ្រមរ។

**គ្រលរ** *កិ.១.* ពាក្យសម្រាប់ចម្រើនពាក្យនិយាយឱ្យវិសេសឡើង :

❖ និយាយគ្រលរ។

**គ្រហារ** *ន.* ពាក្យជេរដោយស្និទ្ធស្នាល, ពាក្យជេរដោយស្រលាញ់ :

❖ មេគ្រហារ

❖ អាគ្រហារ។

*កិ.* ជេរដោយកំហឹងតែសម្រាលពាក្យមិនឱ្យធ្ងន់ពេក :

❖ មេចោរគ្រហារ។

**គ្រួសារ** *ន.* ត្រកូល, ប្រជុំត្រកូលមនុស្សគឺមាតាបិតានិងបុត្រធីតា :

❖ គ្រួសាររបស់ខ្ញុំនៅរស់ទាំងអស់គ្នា។

**ឃូរៗ** *ន.* សូរខ្យល់កើតដោយផ្លុំ, សូរខ្យល់កើតដោយសប់, សូរខ្យល់កើតដោយបក់ :

❖ ផ្លុំឃូរៗ

❖ សប់ភ្លើងឃូរៗ។

**ឃោរ** (បា.សំ.) *គុ.* ខ្លាំង, ពន្លឹក, គួរខ្លាច, គួរស្បើម :

✎ **ខឹងឃោរ** : ខឹងខ្លាំង។

*ន.* ដូចពាក្យខ្លះថា បុណ្យបាត់ផ្សិតបាប លាភបាត់ផ្សិតឃោរ។

**ឃោសនាការ** (បា.) *ន.* ឈ្មោះក្រសួងរដ្ឋមន្ត្រីមួយផ្នែកខាងការផ្សាយដំណឹងផ្សេងៗ :

❖ ក្រសួងឃោសនាការ។

**ងរ** *កិ.* សម្ដែងអាការៈមាយានាំ ងរ :

❖ ងរចុះ ងរឡើង។

**ងារ** *ន.* មុខការ, ទីតំណែងរាជការតាមបណ្ដាសក្ដិ, ទីតំណែងរាជការតាមក្រសួង, បណ្ដាសក្ដិ, យសសក្ដិ, ឋានន្តរ :

❖ លោកហ្នឹងមានងារជាអ្វី?

❖ មានងារជាហ្លួងពិភក្ដិអក្សរ។

*ន.* ភាគដីល្មមកម្លាំងបុរសធ្វើមួយពេលហើយការ :

❖ ដីមួយងារ

❖ ភ្ជួរស្រែមួយព្រឹកបានពីរងារ។

*ន.* ការដែលចែកដោយមុខ, ដោយឡែកក៏ហៅថា ងារ ដែរ :

❖ ធ្វើការកាន់ងារ

❖ ធ្វើការតាមមុខងារ។

*ឲ.* ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ ការ :

✍ **ការងារ** : កិច្ចការដែលត្រូវធ្វើដោយមុខ។

**ង៉េង៉ក់** *កិ.វិ.* វិលវល់ស្ទាក់ស្ទើរ, កកែកករមិនដាច់ស្រេច :

❖ ដើរង៉េង៉ក់

❖ និយាយង៉េង៉ក់។

**ចងការ** *កិ.* ខ្ចីប្រាក់គេដោយមានខសន្យាថាត្រូវឱ្យប្រាក់ការទៅគេតាមកម្រិត :

❖ ខ្ញុំទ័លណាស់ត្រូវចងការប្រាក់គេដោះទ័លសិន។

**ចង្ហួរ** ឬ **ចង្អួរ** *ន.* ជ្រលងទឹកតូច :

❖ ចង្ហួរទឹកឬចង្អួរទឹក។

**ចង្អូរ** *ន.* គន្លងនង្គ័លក្នុងនាទីថ្នាលសំណាបដែលគេបែងជាជ្រលង :

❖ ដើរតាមចង្អូរ។

☞ ភាគដីក្នុងចន្លោះៗនោះក៏ហៅ ចង្អូរ ដែរ :

❖ សំណាបប្រាំចង្អូរ។

**ចង្អើរ** *ន.* រានសម្រាប់ផ្អើរត្រី, ផ្អើរសាច់, ផ្អើរនំ, ផ្អើរម្ទេសជាដើម។

**ចង្អេរ** *ន.* ប្រដាប់ត្បាញដោយបន្ទោះឫស្សីសម្រាប់អុំស្រូវ, អុំអង្ករជាដើម; ឬសម្រាប់ហាលអ្វីៗ។ ចង្អេរមានបីយ៉ាង :

✍ **ចង្អេរអុំ** : សម្រាប់ប្រើអុំ។

✍ **ចង្អេរគ្រាង** : សម្រាប់ប្រើហាលអ្វីៗ។

✍ **ចង្អេរកន្ត្រៃ** : ចង្អេរជំទើរតូចស្ទើរជាងច្រែងរាក់ជាងចង្អេរអុំ សម្រាប់ហាលឬសំដិលអ្វីៗគឺអំបុកមួយចង្អេរកន្ត្រៃ។

**ចង្អោរ** *កិ.* រើខ្យល់ដោយទឹកមាត់ (កើតអំពីរមួលក្នុងក្រពះ) :

❖ លេបថ្នាំចូលទៅចេះតែចង្អោរមកវិញ។

**ចម្ការ** *ន.* ទីដែលគេភ្ការសម្រាប់ដាំសរពើដំណាំ :

❖ ចម្ការពោត។

❖ ចម្ការឪឡឹក

**ចរ** (បា.សំ.) *កិ.* ត្រាច់, ដើរ, ទៅ; ប្រព្រឹត្ត។

**ចរាចរ** (បា.) *កិ.* ដើរទៅដើរមក, ដើរត្រលប់ចុះត្រលប់ឡើង, ទៅមកៗ, ដើរៗ ទៅមកមានទចម្ដងៗ។

**ចាមរ** (បា.សំ.) *ន.* ឈ្មោះគ្រឿងប្រដាប់មួយប្រភេទមានសណ្ឋានដូចផ្ចិត សម្រាប់មន្ត្រីសង្ឃទីរាជាគណៈ ប៉ុន្តែគ្មានកំពូលស្រួចនិងឆែកៗជុំវិញទេ មានដងវែងសម្រាប់ក្បួនហែក្នុងព្រះរាជពិធីផ្សេងៗមាន :

❖ ព្រះរាជពិធីរាជាភិសេក, ...។

**ចារ** *កិ.* ធ្វើរបងទាបដោយដោតចម្រឹងឱ្យជាចារឹក :

❖ ចារចំណារ។

*កិ.* សរសេរដោយដែកចារ :

❖ ចារសាស្ត្រា។

*ន.* ឈ្មោះឈើមានផ្កាសម្បុរក្រហមក្លិនឆ្អាប :

❖ ផ្កាចារ

❖ ដើមចារ។

**ចិន្តនាការ** (បា.) *ន.* អាការៈដែលគិត, ដំណើរដែលគិត។ (រ.ស.) ប្រើជា *កិ.* ក៏បាន :

❖ ទ្រង់ចិន្តនាការ...។ គួរប្រើជា *ន.* ថាទ្រង់មានព្រះចិន្តនាការ...។

**ចិរស្សការ** (បា.) *ន.* ការយឺតយូរ, ការដែលត្រូវធ្វើក្រហើយ :

❖ សំណង់ស្ពានបេតុងនេះជាចិរស្សការ។

**ចីពរ** (បា.សំ.ភ្ល.) *ន.* គ្រឿងស្លៀកដណ្ដប់សម្រាប់អ្នកបួសក្នុងពុទ្ធសាសនា; ខ្មែរប្រើពាក្យនេះចំពោះតែ ឧត្តរាសង្គ។

**ចីរចរ** (បា.សំ.ចិរចរ) *ន.* ដំណើរទៅយូរ (សម្រាប់ប្រើក្នុងកាព្យ)។

**ចីវរ** (បា.សំ.) *ន.* គ្រឿងស្លៀកដណ្ដប់សម្រាប់អ្នកបួសក្នុងពុទ្ធសាសនា; ខ្មែរប្រើពាក្យនេះចំពោះតែ ឧត្តរាសង្គ។

**ចុងអង្គារ** *ន.* ឈ្មោះលតាជាតិមួយប្រភេទ ផ្កាស ស្លឹកតូចវែងៗ ប្រើជាបន្លែស្ងោបាន។

**ចូរ** *កិ.* ធ្វើឱ្យមានស្នាមដោយឆ្លូតឬគូសនឹងដែកនឹងក្រចកជាដើម។

*កិ.ន្ទ.* ពាក្យបង្គាប់ឱ្យប្រព្រឹត្ត, ពាក្យបង្គាប់ឱ្យព្រមតាម :

❖ ចូរមកចុះ!

❖ អ្នកទាំងឡាយចូរឈប់នៅនេះចុះ!

**ចៀរ** *កិ.* ចិតឱ្យជាចំនៀរ, កាត់ឱ្យជាចំនៀរ :

❖ ចៀរស្លឹកចេក។

*កិ.* តម្រឹម :

❖ ចៀរជើងសក់។

**ចេរ** (ព.ចុ.) *កិ.* ដឹង, ជ្រាប, យល់ :

✍ **ពុំចេរពុត** : ពុំដឹងពុត។

✍ **ពុំចេរហេតុការណ៍** : ពុំដឹងរឿងហេតុ។

*គុ.* យូរ, យឺតយូរ :

✍ **ចេរកាល** : កាលយូរ។

**ចោរ** (បា.) *ន.* ជនអ្នកលួចគេ, លួច :

✍ **ចោរឆក់** : ចោរអ្នកឆក់ទ្រព្យគេ។

**ចោរប្លន់** : ចោរអ្នកប្លន់គេ។

**ចោរព្រៃ** : ចោរដែលវេលាថ្ងៃពួននៅតែក្នុងព្រៃវេលាយប់ចេញលួចឬប្លន់គេ (ច្រើនតែចោរប្លន់) គឺចោរព្រៃមានចោរស្រុកជារនុកជាអ្នកឱ្យការណ៍ទើបអាចលួចឬប្លន់អ្នកស្រុកបាន, ដូចមនុស្សកាចឬមនុស្សខូចដែរបើគ្មានគ្នីគ្នាចូលដៃសមគំនិតកាន់ជើងទេក៏កាចខូចពុំកើតឡើយ។

*ន.* ស្ត្រីដែលខូចលួចក្បត់ចិត្តប្ដីឬក្បត់ចិត្តសហាយហៅថា **ចោរក្បត់ចិត្ត**, បើស្ត្រីជាជាចោរលួចទ្រព្យគេហៅថា **ចោរី**។

**ចៅអធិការ** *ន.* ភិក្ខុជាមេវត្ត។

**ចំណរ** *ន.* ការចរ, ការត្រាច់ចរ។

**ចំណារ** *ន.* ការដែលគេចារ; អក្សរដែលគេចារ; ចម្រឹងទាំងឡាយដែលគេចារឱ្យមានព្រំមានចារឹក។

**ចំណូរ** *ន.* ការចូរ, ការដែលគូសឆូត; ស្នាមដែលគេចូរ, ដីឬកន្លែងដែលចូរ :

- ធ្វើចំណូរ
- លុបចំណូរនេះចោលចេញ។

**ចំណោរ** *ន.* ដំណើរប្រព្រឹត្តទៅនៃកាលតទៅខាងមុខ, អំណើះ :

- លុះចំណោរតមក
- ចំណោរទៅខាងមុខ។

**ចំទើរ** ឬ **ជំទើរ** *ន.* ស្មើរធំស្មើរតូច :

- រាងចំទើរ

❖ តូចចំទើរ។

**ចំនៀរ** *ន.* ចំណិតដែលចៀរ, កំណាត់ដែលចៀរ :

❖ ចំនៀរក្រដាស។

*ន.* ចំណិត, ប៉ែកតូចវែង :

❖ ចំនៀរដី។

**ច្បារ** *ន.* សួនដំណាំ, ទីដីដែលដាំបន្លែឬដាំដំណាំរាយរងផ្សេងៗដែលមានចំណារដោយឡែកដោយសង្កាត់ :

❖ ច្បារផ្កា

❖ ច្បារម្ទេស។

**ច្រអរ** *គុ.* ដែលតឹងពោះខ្លាំងស្ទើរតែនឹងបិទមាត់មិនជិត។

**ឆកាមាវចរ** (បា.) *ន.* ឋានសួគ៌៦ជាន់ក្នុងពួកកាមភព គឺ ចាតុម្មហារាជិកា, តាវត្តិង្ស, យាមា, តុសិត, និម្មានរតី, បរនិម្មិតវសវត្តី។

**ឆទ្វារ** (បា.សំ.) *ន.* ទ្វារ៦ : ទ្វារភ្នែក, ទ្វារត្រចៀក, ទ្វារច្រមុះ, ទ្វារអណ្តាត, ទ្វារកាយ, ទ្វារមនោ។

**ឆរ** *ន.* ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ ឈូ :

❖ មនុស្សផ្អើលឈូឆរ។

**ឆាយាធរ** (បា.សំ.) *ន.* អ្នកទ្រទ្រង់នូវពន្លឺ, អ្នកទ្រទ្រង់នូវស្រមោល (ព្រះចន្ទ; កញ្ចក់)។

**ឆុរ** (សំ.) *កិ.* ខ្សុរឡើង, ឆេវឡើង។

✍ **ឆុរឆេះ** : ក្រោធក្ដៅខ្លាំងទប់មិនឈ្នះ។

✍ **ឆុរឆេវ** : ខឹងខ្លាំងដូចជាចាប់ពើតឆេវៗ។

☞ *ន.* ស្ករឮដោយប្រេងឬខ្លាញ់ដែលពុះព្រោះត្រូវចំហាយក្ដៅ។

**ឆែកឆេរ** *កិ.* (ក្លាយមកពី **បារ.** ស៊ែរសេះ Chercher “រក”) ស្ទួររក, ពិនិត្យមើល, ត្រួតត្រាមើលឱ្យដឹង :

❖ ទៅផ្សារត្រូវយកកាតទៅផងក្រែងប្រទះនគរបាលឆែកឆេរ។

☞ ច្រើនប្រើកាត់ពាក់កណ្ដាលពាក្យថា ឆែក ឬ ឆេរ :

❖នគរបាលឆែកកាត

❖ មេគយឆេរថ្នាំ។

**ឆ្ការ** *កិ.* ត្រួសត្រាយ :

❖ ឆ្ការព្រៃ

✍ **ឆ្ការដៃ** : វាសដៃដូចគេឆ្ការព្រៃ។

**ឆ្នោរ** *ន.* ដុំមាស, ...។

**ឆ្នេរ** *ន.* មាត់សមុទ្រឬមាត់ទន្លេ, ស្ទឹងត្រង់ដែលមានសណ្ឋានជ្រាលមានផ្នូកខ្សាច់រាបស្រួល :

❖ ឆ្នេរសមុទ្រ។

**ឆ្មារ** *គុ.* តូចបំផុត; សម្រាប់ហៅវត្ថុដែលតូចវែងឬសំឡេងតូចស្រួច :

❖ សំឡេងឆ្មារ

❖ សរសៃអំបោះឆ្មារ។

🙰 **ក្រូចឆ្មារ** ៖ ក្រូចដើមទាបផ្លែតូចៗសម្រាប់ប្រើការបានច្រើនយ៉ាង មានប្រើធ្វើម្ជូរជ្រក់ជាដើម។

**ឆ្អើរ** ***កិ.*** ចម្អិនឬកម្ដៅដោយដាក់លើវាន ដុតភ្លើងពីក្រោមដើម្បីនឹងទុកឱ្យបាន យូរឬគ្រាន់តែឱ្យស្រស់ស្ងួតទឹក ៖

❖ ឆ្អើរត្រី

❖ ឆ្អើរសាច់។

🙰 **ដេកឆ្អើរភ្លើង** ៖ ដេកលើដំណេកដែលមានភ្លើងកម្ដៅពីក្រោម។

☞ ***គុ.*** ដែលឆ្អើរស្រេចហើយ, ដែលឆ្អិន, ដែលក្រៀមដោយឆ្អើរ ៖

❖ ត្រីឆ្អើរ

❖ សាច់ឆ្អើរ។

**ជជួរ** ***កិ.១.*** ដែលស្រុង, ស្ដុយហៀរកែង ៖

❖ ស្ទៀកហ្វូលជជួរ

❖ ស្លៀកសម្ពុយជជួរ។

🙰 **ជជួរជជាយ** ៖ ស្ដុយជាយជជួរស្មើរនឹងអូសដី។

**ជដាធរ** (**បា.សំ**) ***ន.*** អ្នកទ្រទ្រង់ផ្នួងសក់, អ្នកទុកផ្នួងសក់ (តាបស)។

**ជណ្ដើរ** ***ន.*** ប្រដាប់មានកាំជាជាន់ៗឬជាថ្នាក់ៗភ្ជាប់ទៅនឹងមេទាំងពីរខាង សម្រាប់ជាន់ដើរឡើងចុះ ៖

❖ ជណ្ដើរថ្ម

❖ ជណ្ដើរឈើ។

**ជននិករ** (បា.) *ន.* ប្រជុំជន, ពួកជន។

**ជនាចារ**(បា) *ន.*សណ្ដាប់ធ្នាប់, បែបបទរបស់ពួកជនក្នុងប្រទេស, ស្រុក, ភូមិ។

**ជន្លួញបរ** *ន.* ឈ្មោះឈើមួយប្រភេទ។

**ជរ** *ន.* ក្បាច់រំលេចសម្រាប់ដាក់ប្រកបត្រង់ជាយ, ត្រង់រឹម, ត្រង់ហាម :

❖ សំពត់មានជរ។

*គុ.* ដែលមានជរ :

❖ ហូលជរ

❖ អាវជរ។

**ជរជួរ** *គុ.* ដែលស្អុយមានជររត់ជួរ, ដែលស្រុងរត់ជួរ :

❖ ស្បៀកសំពត់ជរជួរ។

**ជ័រ** *ន.* ខ្លាញ់រុក្ខជាតិ, លតាជាតិឬតិណជាតិចំពូកខ្លះមានសម្បុរផ្សេងៗមានលក្ខណៈស្អិត។

**ជ័រត្រាក់** : ជ័រដែលចេញព្រោះកម្ដៅភ្លើងឆេះរណ្ដៅជ័រ កាលនៅក្ដៅវារថ្លា លុះអស់អំណាចក្ដៅក៏កករឹងក្ដាំង។

**ចុងជ័រ** : ជ័រដែលហូរចេញឯងអំពីឈើផ្ទឹក។

**ជីពចរ** (បា.សំ.ភ្ល.) *ន.* កម្លាំង, សន្ទុះ, ដង្ហើមនៃសរសៃលោហិតដែលកម្រើកលោតៗនៅសព៌ាង្គកាយ។

**ជីរ** (បា.សំ.) *ន.* ឈ្មោះដំណាំមួយពួកសម្រាប់ប្រើស្លឹកជារបោយឬបង់សម្រាប់បំបាត់ក្លិនរសស្អាប, ជីរមានច្រើនយ៉ាង :

❖ ជីរអង្កាម

❖ ជីរនាងវង

❖ ជីរលីងលាក់។

**ជូរ** *គុ.* ដែលមានរសជាតិធ្វើឱ្យស្រៀវសង្កៀរធ្មេញ។

**ជួរ** *ន.* របៀបរៀបរៀងតគ្នា :

❖ ឈរជាជួរ

❖ ពោត៥០ជួរ។

☞ តំណវង្សត្រកូលនៃបុព្វបុរស, ជំបូរ :

❖ ជួរខាងម្ដាយ

❖ ជួរខាងឪពុក។

**ជើងការ** *ន.* ដំណើរការណ៍, ពត៌មាន, ទំនងឬលំនាំនៃរឿងរ៉ាវ :

❖ ដឹងជើងការហើយ

❖ ខ្ញុំមិនទាន់ទៅទេចាំស្ដាប់ជើងការមើលសិន។

**ជើងថ្ករ** *ន.* បង្គោលបួនបោះអមទប់ក្ដារមឈ្ងូសតម្កល់ក្នុងទីធ្វើឈាបនកិច្ច :

❖ បោះជើងថ្ករ។

☞ ទីដីនិងខសដែលរៀបចំធ្វើឈាបនកិច្ចនោះក៏ហៅជើង ជើងថ្ករ ដែរ :

❖ លត់ជើងថ្ករ។

**ជើងនេះ** *ន.* ដីនារត្រង់មាត់ច្រាំង, ដីនារត្រង់ទីជម្រាល :

❖ ដើរតាមជើងទេរ

❖ គេដាំដំណាំនៅជើងទេរ។

**ជើងហារ** *ន.* លេខដែលបែងចែកឬរកឱ្យឃើញជាចំណែក, ជើងលេខចែក។

**ជើងអាធារ** *ន.* ប្រដាប់សម្រាប់ទ្រគម្ពីរ :

❖ សម័យដែលពុំទាន់មានសាលាបាលីរបស់រាជរដ្ឋាភិបាលនៅឡើយ, ភិក្ខុសាមណេរអ្នករៀនប្រែបាលីសុទ្ធតែមានជើងអាធារតម្កល់គម្ពីររៀន។

**ជេតុត្តរ** (បា.) *ន.* ឈ្មោះស្រុកមួយមាននិយាយក្នុងរឿងវេស្សន្តរជាតកជានគរដែលព្រះបាទវេស្សន្តរទ្រង់គង់។

❧ **ក្រុងកបិលវត្ថុ** ឬ **កបិលពស្តុ** : ក្រុងជេតុត្តរពីដើមនុះឯង។

**ជេរ** *កិ.* ពោលពាក្យអសប្បុរសដោយកំហឹងឬដោយអាការៈឡេះឡោះផង។

❧ **ជេរប្រទេច** : ជេរផងប្រទេចផង។

**ជោតនាការ** (បា.) *ន.* អាការៈនៃសេចក្ដីរុងរឿង, អ្នកដែលមានអាការៈរុងរឿង។

**ជោរ** *កិ.* ពោរឡើង :

❖ ទឹកជោរ។

*កិ.* ឬ *គុ.* ឡើងចិត្ត, ស្រស់ចិត្ត, រីកចិត្តដោយពាក្យបញ្ជោរ។

*គុ.* ដែលញោស, ជ្រុលហួស :

❖ ទុំជោរ

❖ ចាស់ជោរណាស់ហើយ។

**ជំនេរ** *ន.* ការជេរ, ពាក្យជេរ :

❖ អាហ្នឹងខ្ជិលណាស់ប្រើវាឱ្យធ្វើការអ្វីៗទាល់តែមានជំនេរថែមទៀត ទើបរហ័សរហួនគ្រាន់បើបន្តិច។

**ជំនោរ** *ន.* ទឹកដែលជោរ; ដំណើរដែលជោរ។

☞ ឈ្មោះខ្យល់នាំទឹកឱ្យជោរ :

❖ ត្រូវជំនោរ

❖ ធ្លាក់ជំនោរ។

**ជំបួរ** *ន.* ជួរ, គោត្រ, ត្រកូល, ពូជ, ផៅនៃបុព្វបុរស :

❖ ជំបួរខាងម្ដាយ

❖ ជំបួរខាងឪពុក។

**ជំហរ** *ន.* កម្ពស់ដែលឈរ, ឥរិយាបថឈរ, ភាពដែលឈរ :

❖ មួយជំហរមនុស្ស។

*គុ.* ដែលឈរតែ, ដែលមិនសូវបានការ, ដែលបានតែខាងអួត, ដែលបានតែខាងស៊ីខាងចាយជាដើម :

❖ ជំហរតែស៊ី

❖ ជំហរតែអួត

❖ ជំហរតែចាយ។

**ឈរ** *កិ.* ឋិតពេញជំហរជើងជាន់ត្រង់, ជាឈ្មោះឥរិយាបថមួយក្នុងឥរិយាបថទាំង៤គឺ ដើរ, ឈរ, អង្គុយ, ដេក។

☞ ស្ថិតនៅ, នៅស្ដីទីរាជការ :

❖ រាជការត្រូវចាត់លោក...ឱ្យទៅឈរខេត្តស្វាយរៀង

❖ ខ្ញុំបានឈរធ្វើរាជការទីអភិបាលខេត្តនៅខេត្តកំពតអស់៥ឆ្នាំ។

☞ នៅទ្រឹងមិនឡើងមិនចុះ, មិនគ្រាន់បើមិនរឹតឡើង (ជំងឺ) :

❖ ជំងឺឈរឱ្យមើលយូរណាស់មិនគិតរកគ្រូមើលគ្នា។

*គុ.* ឬ *ន.* អក្សរដែលមានតួរាងត្រង់ :

❖ អក្សរឈរ។

**ឈូឆរ** *កិ.១.* អ៊ូអរ :

❖ ផ្អើលឈូឆរ

❖ ជួយឈឺឆ្អាលឈូឆរ

❖ មានមនុស្សទៅឈូឆរ។

**ឈ្នូលតន្ទា** *ន.* ប្រដាប់ធ្វើដោយឈើមានសណ្ឋានជមសំប៉ែត កំពុងកណ្ដាល សម្រាប់ថ្កុរតម្បាញ។

**ញញ៉េរ** *កិ.១.* ឬ *គុ.* ដែលញ៉េរទទ្រើកដោយរងាឬដោយខ្លាច, ដោយជញ្ជួយ :

❖ រងាញញ៉េរ

❖ ដើរញញ៉េរ។

✍ **ញញ្ញាក់ញញ្ញ៉េរ** : ដែលញ៉េរញ្ញាក់ទទ្រាក់ទទ្រើក។

**ញញួរ** *ន.* អន្លូងក្បាលស្វាតូចធ្វើដោយដែកជាប្រដាប់សម្រាប់ជាងទង, ជាងដែក, ជាងឈើ។

**ញ៉េរ** *កិ.* កម្រើកទទាក់, កម្រើករន្ថាន់។

**ដងភ្នារ** *ន.* គ្រឿងរចនាគ្រឹហាមានសណ្ឋានជាតួខ្លួននាគប្រើដាក់ភ្ជាប់ពីគល់ជហ្វាមកភ្ជាប់នឹងនាគសន្ទឹកជាគ្រឿងវិហារឬប្រាសាទ។

**ដងបង្ហួរ** ឬ **ឆងបង្ហួរ** *ន.* ទងសរសៃធំជាបំពង់បស្សាវៈនៃមនុស្សឬសត្វចតុប្បាទពួកខ្លះ។

**ដរ** *គុ.* ដែលរោគរើឡើងដោយប៉ះទង្គិច :

❖ ដំបៅដរ

❖ បូសដរ។

**ដរឆរ** *កិ.* អាមណាម, រាលដាល, សុសសាយដោយនិយាយតៗគ្នាពីមួយទៅមួយ :

❖ រឿងសម្ងាត់ហ្នឹងឥឡូវវាដរឆរសុសសាយអស់ទៅហើយ។

**ដារ** (**បា.សំ.ទ្ក.**) *ន.* ឈ្មោះបុណ្យតូចម្យ៉ាងក្នុងពុទ្ធសាសនា ជាបុណ្យទក្ខិណានុប្បទាន, ទាយកនិមន្តព្រះភិក្ខុសង្ឃសូត្រសត្តប្បករណាភិធម្មនិងតិរោកុឌ្ឍសូត្រ ហើយគេរាប់បាត្ររួចឧទ្ទិសចំណែកផលបុណ្យជូនទៅឱ្យបុព្វបេតបុគ្គលដែលចែកឋានទៅកាន់បរលោកហើយ :

❖ ធ្វើបុណ្យដារ

❖ និមន្តលោកដារ។

**ដុល្លារ** *ន.* (អ. Dollar) ឈ្មោះរូបិយវត្ថុរបស់សហរដ្ឋអាមេរិក។

**ដូរ** *កិ.* ប្តូររបស់, ឱ្យរបស់ទៅវិញទៅមកដោយទុកតម្លៃជាស្មើគ្នា :

❖ ដូរគោ

❖ ដឹកឱ្យឡឹកទៅដូរស្រូវ។

**ដើរ** ***កិ.*** សម្រេចឥរិយាបថមួយផ្សេងអំពីឥរិយាបថបី គឺ ឈរ, អង្គុយ, ដេក, គឺលើកជើងឈានទៅ :

❖ ដើរទៅ

❖ ដើរមក។

☞ កម្រើកដោយកម្លាំងផ្សេងៗមានចំហាយក្តៅជាដើម :

❖ គ្រឿងចក្រដើរ

❖ ម៉ាស៊ីនដើរស្រួល

❖ នាឡិកានេះដើររហ័សណាស់។

☞ ប្រព្រឹត្តទៅ :

❖ ការរបស់យើងឥឡូវដើរស្រួលជាងពីដើម។

☞ កាន់ការដោយគ្រឿងដឹកនាំផ្សេងៗ :

❖ ដើរទូក

❖ ដើរកប៉ាល់។

☞ ទទួលភារៈដឹកនាំគ្រឿងផ្ទុកឬមនុស្សអ្នកជិះទៅមក :

❖ ផ្លូវនុ៎ះមានរថយន្តដើរឥតអាក់។

❖ ចែកឋាន (ស្លាប់) ក៏ហៅ ដើរ បានដែរ (ពាក្យរាបសាសម្រាប់ប្រជាជនសាមញ្ញ) :

❖ បើតាមការសង្កេតមើលដង្ហើមរបស់គាត់ឃើញថា គាត់មុខជានឹងដើរក្នុងពេលឆាប់ៗនេះហើយ...។

**ដើរហើរ** *កិ.* ធ្វើអំពើស្មន់អន្ទករនឹងគ្នា, លបលួចខ្ចូចនឹងគ្នាដោយផ្លូវកាមគុណ (ពាក្យរាបសា) :

❖ ឮថាវាបានដើរហើរនឹងគ្នាទៅហើយ។

**ដេរ** *កិ.* ភ្ជាប់អ្វីៗដោយម្ជុលនិងចេស :

❖ ដេរខោ

❖ ដេរអាវ។

**ដែរ** *និ.* ដូចគ្នា, បានដូចគ្នា, ផង; ដូចពាក្យថា :

❖ ខ្ញុំទៅដែរ

❖ ដូច្នេះក៏បានដែរ

❖ អ្នកទៅជាមួយនឹងខ្ញុំដែរឬ?

**ដោយសារ** *កិ.* អាស្រ័យផង :

❖ ដោយសារទូកគេ

❖ ដោយសាររទេះគេ

*អា.និ.* ព្រោះតែ; អាស្រ័យនឹង :

❖ រស់ដោយសារគេចិញ្ចឹម។

**ដោរ** *កិ.១.* ឬ *គុ.* ដែលឡើងកន្ទួលធំខ្លោតដោយពិសអ្វីរោលជាដើម :

❖ កម្ទេចអាលរោលសាច់ឡើងដោរពាសពេញអស់ទាំងខ្លួន។

**ដំណូរ** *ន.* ការដូរ :

❖ ដំណូរសេះនឹងគោ។

**ដំណើរ** *ន.* អំពើដែលដើរ, ឥរិយាបថដើរ។ ទំនង, លំនាំ, ការណ៍, ហេតុ, សេចក្ដី :

❖ ដំណើរពាក្យ

❖ ដំណើរសេចក្ដី

❖ ដំណើរនេះមិនស្រួលទេ។

✍ **កើតដំណើរ** : កើតមានវិវាទ, កើតក្ដី។

**ដំណោរ** *ន.* ការដេរ, ការធ្វើឱ្យកើតបានជាថ្នេរ, វិជ្ជាជីវៈឬសិល្បៈខាងការកាត់ដេរ :

❖ គេមានសញ្ញាបត្រខាងដំណោរ។

**ដំបារ** *ន.* ផ្ទាំង, ផ្ទៃ :

✍ **ដំបារពោះ** : ផ្ទៃពោះ

✍ **ដំបារមាស** : ផ្ទាំងមាស។

*គុ.* មាំក្រាស់ទង្គះ, ដែលនាគាងចេញ :

❖ រាងដំបារ

❖ ខ្នងដំបារ។

**ឋបនាការ** (បា.) *ន.* ការដែលឋិត, ការដែលតាំង, ការដែលតម្កល់នៅ :

❖ ឋបនាការរោងចក្រចម្រាញ់ប្រេងកាតនៅក្រុងព្រះសីហនុ។

**ឋានន្តរ** (បា.) *ន.* លំដាប់នៃទី, មុខងារ, ងារ, ថ្នាក់ងារ, ថ្នាក់សក្តិយស :

❖ លោកមានឋានន្តរជាអ្វី?

❖ ឋានន្តរជាអភិបាលស្រុក

❖ ឋានន្តរជាព្រះចម្រើនសម្បត្តិ។

**ឋិតថេរ** (បា.)*គុ.* ដែលឋិតនៅយូរ, អង្វែង; ដែលតាំងនៅមាំមួន, ខ្ជាប់ខ្ជួន; ដែលជាប់បានយូរ; ស្ថាពរ :

❖ របស់ឋិតថេរ

❖ ការងារឋិតថេរ។

*កិ.វិ.* ដែលមានជាប់យូរមកហើយមិនដែលដាច់, មិនដែលឈប់ :

❖ ធ្វើការឋិតថេរ។

**ខេបនាការ** (បា.) *ន.* អាការៈបោះចោល :

❖ ធ្វើខេបនាការ។

**តង្កេរ** *ន.* ខ្សែអំបោះឆ្មារសម្រាប់ថ្កុរតម្បាញ :

❖ ខ្ញុំមិនទាន់បានត្បាញក្រមានៅឡើយព្រោះខ្វះតង្កេរ។

**តម្បារ** *ន.* ប្រដាប់សម្រាប់ត្បារ :

❖ តម្បារត្រចៀក។

**តុល្យការ** (បា.) *ន.* ការស្មើភាគគ្នា, ការថ្លឹងឱ្យមានទម្ងន់ស្មើគ្នា; បញ្ជីគិតគូរគ្នេរគ្នាន់ឱ្យដឹងមុខចំណូលចំណាយ :

❖ រឿងនេះពុំទាន់ដឹងជាយ៉ាងណាទេចាំធ្វើតុល្យការមើលសិន។

**តុល្យាការ** (បា.) *ន.* អាការៈថ្លឹងមើលឱ្យដឹងនូវភាគស្មើគ្នា, តារាងឬបញ្ជី គិតគូរឱ្យដឹងនូវកិច្ចការផ្សេងៗ :

❖ តាមតុល្យាការក្នុងត្រីមាសទី២នេះឃើញថា កិច្ចការនៃសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរយើងបានចម្រើនកើនជាងត្រីមាសទី១។

**តុលាការ** (បា.សំ.) *ន.* ការថ្លឹង, ការស្ទង់មិនឱ្យមានល្អៀង; អ្នកស្ទង់តម្រង់សេចក្តី។ ក្រសួងជម្រះក្តីឬចៅក្រមអ្នកវិនិច្ឆ័យក្តី។

**តោងការ** *កិ.* ត្រូវការ :

❖ តោងការធ្វើ

❖ មិនតោងការ (មិនសូវប្រើ)។

**តោមរ** (បា.សំ.) *ន.* លំពែងស្នែងក្របី, ផ្គាក់កកុក :

❖ រេហ៍ពលករកាន់តោមរស្ទុះចូលឈ្លូកកំដរសេនាទ័ពស្រួច។

**តោមរធរ** (បា.សំ.) *ន.* អ្នកកាន់លំពែងស្នែងក្របីឬអ្នកកាន់ផ្គាក់កកុក :

❖ ឯពួកពលតោមរធរស្រែកហ៊ោកម្ទេចឃរស្ទុះចូលតយុទ្ធ។

**ត្បារ** *កិ.* មូរបង្ខិល, ដុសខាត់ប្រហោងដោយតម្បារ :

❖ ត្បារត្រចៀក

❖ ត្បារខ្ទុះបូស។

**ត្បុរ** *កិ.* សសុលចូល, មមុលចូល។

**ត្រចៀកកណ្ដុរ** *ន.* ឈ្មោះផ្សិតដុះនឹងដើមឈើសម្បុរក្រមៅមានសណ្ឋានស្រដៀងនឹងត្រចៀកកណ្ដុរ; ច្នួនកាលដុះនៅដីប្រាបក៏មាន :

❖ ផ្សិតត្រចៀកកណ្ដុរ។

**ត្រដរ** *កិ.* ខំប្រឹង, ខំស្ទុះឡើងដោយកម្លាំងយ៉ាងតិច :

❖ រកស៊ីទាំងត្រដរ

❖ ខំត្រដរដើរទាំងឈឺចាប់។

**ត្រដោកក្ដារ** ឬ **ថ្ដោកក្ដារ** *ន.* ប្រដាប់ធ្វើដោយឈើ, ប្រដាប់ធ្វើដោយឫស្សី សម្រាប់ប្រហកច្រកក្ដារម្ងរត្បាញ។

**ត្របែកជ្វា** *ន.* ឈ្មោះឈើព្រៃនាមមួយប្រភេទស្លឹកតូចជាងត្របែកព្រៃ តែផ្កាមានសណ្ឋានដូចត្របែកព្រៃដែរ។

**ត្រាក់ទ័រ** (**បារ.** Tracteur) *ន.* គ្រឿងចក្រប្រដាប់ដោយម៉ាស៊ីនសម្រាប់ប្រើ ការឈ្ជូសច្ចូកដី, គាស់រំលើងដើមឈើជាដើម :

❖ ធ្វើថ្នល់ដោយត្រាក់ទ័រ។

**ត្អូញត្អែរ** *កិ.* ត្អូញហើយត្អូញទៀតចែប៉ប្រែ :

❖ កុំត្អូញត្អែរច្រើនពេក។

**ត្អូរ** *កិ.វិ.* ឬ *គុ.* ដែលមានមុខជូរសំយុងចុះដោយទាស់ចិត្ត, ខុសអធ្យាស្រ័យ :

❖ មុខត្អូរ

❖ ធ្វើមុខត្អូរ។

**ថេរ** (**បា.**) *គុ.* មាំមួន, ខ្ជាប់ខ្ជួន, យឺនយូរ; សម្រាប់និយាយផ្សំនឹងពាក្យ ចិត :

☙ **ចិតថេរ** : តាំងនៅមាំ, តាំងនៅយឺនយូរ។

**ថោមនាការ** (**បា.**) *ន.* អាការៈ, ដំណើរនៃសេចក្ដីស្ញើចសរសើរ :

❖ សម្ដែងថោមនាការ។

**ថ្កុរ** *កិ.* ឆ្មាក់តង្កុរតម្បាញ។

*ន.* ឈ្មោះមច្ឆជាតិមួយប្រភេទពួកឆ្លាម។

**ថ្ងិចថ្ងូរ** *កិ.* ឬ *គុ.* មាយាឆ្មុឹកង៉ក់នាំ-ងរដែលមានកិរិយាមាយាក្និចក្នក់ច្រើន។

**ថ្ងូរ** *កិ.* បញ្ចេញសំឡេងដោយមានទុក្ខវេទនាអំពីរោគបៀតបៀនជាដើម :

❖ ឮតែស្នូរថ្ងូរទាល់ព្រឹក

❖ ទោះបីឈឺធ្ងន់យ៉ាងហ្នឹងក៏ដោយពុំដែលថ្ងូរម្ដងទេ។

**ថ្នូរ** *គុ.* ដែលមានវ័យស្រករគ្នា, ដែលមានភាពស្មើគ្នាទាំងជិតដិតស្និទ្ធស្នាល ទៀតផង, ប្រើបានចំពោះតែផ្សំភ្ជាប់ជាមួយនឹងពាក្យគ្នាថា គ្នាថ្នូរ គឺ ជាគ្នាស្មើ, ជាគូកន :

❖ ពុំត្រូវយកអ្នកធំជាគ្នាថ្នូរឡើយ។

**ថ្នូរ** *ន.* របស់ដែលប្ដូរ, តម្លៃដែលដូរ :

❖ អ្នកដូរគោហ្នឹងមកឱ្យខ្ញុំចុះខ្ញុំឱ្យពីរថ្នូរ។

**ថ្នេរ** *ន* លំអានដែលដេរ។ អ្វីៗដែលមានសណ្ឋានដូចគេដេរក៏ហៅថា ថ្នេរ ដែរ។

**ថ្មើរ** *ន.* ពេល, កាល :

❖ ថ្មើរម៉ានហើយ?

❖ ថ្មើរណោះហើយទៅមិនបានទេ។

☞ និយាយក្លាយជា ថ្មារ ក៏មានខ្លះ។

**ថ្លៃថ្នូរ** *គុ.* ដែលមានតម្លៃគួរលើកសរសើរគួររាប់អាន :

❖ មនុស្សនេះឫកថ្លៃថ្នូរណាស់។

*ន.* មនុស្ស, សត្វ, អ្វីៗដែលមានតម្លៃគួរសរសើរគួររាប់អាន។

**ទន័រ** *កិ.* ឬ *កិ.ឲ.* ញ៉័រខ្លាំង, កន្ត្រាក់ទទាក់ខ្លាំង :

❖ ដើរហាលភ្លៀងរងាញ៉័រទទ័រ។

**ទទារ** *គុ.* ដែលផ្ទុយពីចោត, ដែលមិនស្ងួរច្រាក :

❖ ដំបូលផ្ទះនេះទទារណាស់។

**ទទីទន័រ** *កិ.* ឬ *កិ.ឲ.* ទទ័រខ្លាំង, ទទ័ររឿយៗ :

❖ ជីតាខ្ញុំខំប្រឹងដើរមកទាំងទទីទទ័រ។

**ទទូរ** *កិ.* ឬ *កិ.ឲ.* គ្របក្បាលដោយសំពត់ :

❖ ដេកទទូរ

❖ ខ្ញុំទទូរសំពត់ក៏បាន។

**ទន្តការ** *ន.* អ្នកប្រកបខាងទន្តកម្ម :

❖ ជាងធ្មេញ

❖ ជាងឆ្លាក់ភ្លុក។

**ទន្ទូរ** *ឲ.* ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ ទន្ទេញ :

✍ **ទន្ទេញទន្ទូរ** : ទន្ទេញរទូរឬររអ៊ូរឿយៗខ្ជាន់ៗ។

**ទព្វសម្ភារ** (បា.) *ន.* គ្រឿងប្រុង គឺគ្រឿងប្រដាប់សម្រាប់ផ្គុំ, គ្រឿងប្រដាប់សម្រាប់ផ្សំ, គ្រឿងប្រដាប់ដំឡើងដូចយ៉ាងគ្រឿងគេហដ្ឋាននិងគ្រឿងរទេះជាដើម :

❖ មុននឹងសង់គេហដ្ឋានគប្បីរកទព្វសម្ភារឱ្យបានសព្វគ្រប់សិន។

**ទម្រង់ការ** *ន.* របៀបធ្វើមង្គលការអាពាហ៍ពិពាហ៍ :

៦ **ទម្រង់ការព្រះជ័យចេស្តា** : របៀបមង្គលការអាពាហ៍ពិពាហ៍ដែលព្រះបាទសម្តេចព្រះជ័យចេស្តាទ្រង់មានព្រះរាជបញ្ជាឱ្យរៀបរៀង។

**ទរ** *កិ.* កិន គឺជេរ, ស្តីឱ្យ, បន្ទោស; វាយ, ទះ, តប់... (ជាពាក្យសាមញ្ញសម្រាប់និយាយបញ្ចៀងមិនចំពោះដំណើរជេរ, បន្ទោសជាដើមនោះទេ) :

❖ ខ្ញុំឥតដឹងរឿងហ្នឹងសោះស្រាប់គាត់មកដល់ភ្លាមតាំងទរខ្ញុំតែម្តង។

*កិ.* ស៊ី :

❖ ឆ្កែទរនំអស់។

**ទឡ្ហប្រហារ** (បា.សំ.) *ន.* ការប្រហារ គឺវាយ, សំពង, កាប់ពេញកម្លាំងឬពេញទំហឹង :

❖ ធ្វើទឡ្ហប្រហារ

❖ បៀតបៀនដោយទឡ្ហប្រហារ។

**ទាមទារ** *កិ.* ទាមផងទារផង, ទារដោយទាមចំណែកឬទារតវ៉ាយករបស់ជាមត៌កខ្លួនជាកេរដំណែលឱ្យបានមកខ្លួនវិញ។

**ទារ** *កិ.* ស្រដីក្រើនយករបស់ដែលគេជំពាក់, ក្រើនតឿនបន្តឹងយកប្រាក់តាមកំណត់ដែលត្រូវចេញ, ត្រូវបង់ :

❖ ទារប្រាក់

❖ ទារប្រាក់ពន្ធ។

**និគ្គ្ហរ** (សំ.) *ន.* អ្នកយកទិសជាសម្លៀក គឺអ្នកបួសដែលកាន់លទ្ធិអាក្រាត មិនស្លៀកសំពត់។ ទិគម្ពរនេះក្នុងប្រទេសឥណ្ឌាមានតាំងពីក្នុងបុរាណសម័យ រហូតមកដល់បច្ចុប្បន្នសម័យ, សម័យបច្ចុប្បន្ននេះអ្នកកាន់តាមលទ្ធិជេននៅ តែប្រកាន់តាមលទ្ធិនេះមានឈ្មោះប្រាកដថាពួក និគម្ពរ ឬ លទ្ធិនិគម្ពរ។

**និដ្ឋាការ** (បា.) *ន.* អាការៈដែលបានឃើញ, បានជួបប្រទះមកហើយ។ សព្វថ្ងៃ ពាក្យនេះ ប្រើសំដៅយកហត្ថលេខាជាចាំបាច់នៃអ្នករាជការមានសមត្ថកិច្ច ដែលត្រូវចុះលើលិខិតផ្សេងៗ មានលិខិតឆ្លងដែននិងអាណត្តិបើកប្រាក់ជាដើម ជាការបញ្ជាក់ថាខ្លួនបានពិនិត្យឃើញត្រឹមត្រូវហើយ :

- លិខិតនេះមានទិដ្ឋាការពីក្រុមសន្តិសុខជាតិហើយឬនៅ?
- អាណត្តិបើកប្រាក់នេះ ក្រុមអភិបាលប្រាក់ចំណាយមិនទាន់ចុះ ទិដ្ឋាការនៅឡើយទេព្រោះមានការទាស់ខុស...។

**និនករ** (បា.សំ.) *ន.* អ្នកធ្វើនូវថ្ងៃ (ព្រះអាទិត្យ)។

**និវាករ** (បា.សំ.) *ន.* អ្នកធ្វើនូវថ្ងៃ (ព្រះអាទិត្យ)។

**និវាចរ** (បា.សំ.) *គុ.* ឬ *ន.* ដែលចរតែក្នុងវេលាថ្ងៃ, ដែលចេញរកស៊ីតែក្នុង វេលាថ្ងៃ; សត្វដែលចេញរកស៊ីតែក្នុងវេលាថ្ងៃវេលាយប់ឈប់ដេក :

- សេក
- លលក...។

**ព.ផ្ទ.** សាចរ, រត្តិចរ, រាត្រីចរ។

**នីនើរ** *កិ.* រួញរា, អល់អែក, ញញើតញញើម, ស្ទាក់ស្ទើរ, ស្ទើរទៅស្ទើរមក :

❖ ខ្ញុំនៅទីទើរពុំទាន់បានសម្រេចថាជាយ៉ាងណានៅឡើយ។

**ទុរាចារ** (បា.សំ.) *ន.* ដំណើរប្រព្រឹត្តអាក្រក់, មារយាទអាក្រក់, សណ្ដាប់ធ្នាប់អាក្រក់, ទំនៀមទម្លាប់អាក្រក់។

❷ **មនុស្សទុរាចារ** : មនុស្សដែលមានដំណើរប្រព្រឹត្តអាក្រក់...។

**ទូន័រ** ឬ **ទ្ធន័រ** *កិ.* ឬ *កិ.វិ.* ឮសូរខ្ទ័រទូទៅ, ឮសុសសាយ :

❖ កិត្តិសព្ទរបស់អ្នកប្រាជ្ញអាចលេចឮទូទ័រសព្វទិសទី។

**ទូរ** *កិ.* ផ្ទៀបគ្នា, សាកគ្នា, ផ្ទឹមគ្នាដើម្បីឱ្យឃើញណាប្រសើរជាង :

❖ របស់ខ្ញុំថ្លៃតែប្រាំពាន់រៀលទៅទូរនឹងរបស់អ្នកដែលថ្លៃដល់ទៅដប់ម៉ឺនរៀលដូចម្ដេចបាន!។

**ទើរ** *កិ.* ជាប់នៅពីខាងលើដោយមានអ្វីទ្រមិនឱ្យធ្លាក់មិនឱ្យជ្រុះមកដល់ផ្ទៃខាងក្រោម :

❖ ផ្លែព្រីងទុំជ្រុះមកទើរលើប្រគាប។

☞ ដាក់ថ្កល់ឱ្យជាប់នៅខាងលើ :

❖ ទើររម្យូរកន្ទេលលើធ្នើរ។

**ទេរ** *គុ.* ដែលទ្រេត, ជ្រេ, ជ្រាល :

❖ ច្រាំងទេរ

❖ ដើមត្នោតទេរ។

**ទេសចរ** (បា.) *ន.* ជនអ្នកធ្វើដំណើរលម្ហែកម្សាន្ត :

❖ ប្រាសាទនគរវត្តជាទីចាប់អារម្មណ៍នៃពួកទេសចរបរទេស។

**ទោរ** *កិ.វិ.* ឬ *គុ.* ដែលទ្រេតឈោងទៅខាងនាយឬមកខាងអាយ :

❖ មែកឈើទោរទៅរកផ្លូវ។

☞ ទោរទន់ដែលអនុលោមតាម; ទន់ភ្លន់ :

❖ មានចិត្តទោរទន់ទៅរក...។

**ទំនើរ** *ន.* ទីសម្រាប់បន្ទើរ, ផ្ទើរ (ច្រើនប្រើ ឆ្នើរ ជាង)។

**ទំនេរ** *កិ.វិ.* ឬ *គុ.* ឥតមានរវល់, ឥតមានជំពាក់ដោយហេតុអ្វីមួយ :

❖ ពេលទំនេរ

❖ កន្លែងទំនេរ។

**ទំព័រ** *ន.* ប៉ែកមួយចំហៀងសន្លឹក (និយាយបានតែស្លឹករឹតឬក្រដាសដែលសម្រាប់ចារ, សម្រាប់សរសេរ)។

**ទំពាំងបាយជូរ** *ន.* ឈ្មោះវល្លិមានផ្លែជាចង្កោមប្រើជាអាហារបាន។

**ទ្រនើរ** *ន.* ទីសម្រាប់បន្ទើរ, ផ្ទើរ (ច្រើនប្រើ ឆ្នើរ ជាង)។ ប្រើជា ទំនើរ ក៏មាន។

**ទ្រឹស្តិស្នេរ** (សំ.ភ្ល.) *គុ.* ឬ *ន.* ដែលប្រកាន់ទិដ្ឋិព្រមទាំងមានចិត្តស្នេរផង :

❖ មនុស្សទ្រឹស្តិស្នេរ។

☞ ច្រើនយកសេចក្តីថា កំណាញ់ស្វិត គឺកំណាញ់ក្រៀតម្រា។

**ទ្វារ** (បា.សំ.) *ន.* ច្រកមានសន្ទះឬរនាំងសម្រាប់បើកបិទចេញចូល :

❖ ទ្វារផ្ទះ

❖ ទ្វាររបង។

☞ ច្រកឬប្រហប់ដែលមានភ្នំអមទាំងពីរខាងឬឈូងសមុទ្រជាដើម ទោះមានកោះឬភ្នំអមទាំងពីរខាងក្ដីមានតែដីគោកអមក្ដីក៏ហៅថា ទ្វារ ដែរ :

❖ ទ្វារកំពត

❖ ទ្វារសមុទ្រ។

**ទ្វេហារ** (បា.សំ.) *ន.* ការនាំ; អ្នកនាំ, អ្នកនាំយក, អ្នកដែលនាំ, អ្នកដែលបញ្ជូនរបស់អ្វីៗទៅទាំងពីរនាក់ជាមួយគ្នា; អ្នកសែងអ្វីៗ។ សព្ទនេះអ្នកប្រាជ្ញតែងកាព្យយកមកប្រើមានន័យថាពីរនាក់, ទាំងពីរប្រាណ។

**ធនសារ** (បា.សំ.) *ន.* ទ្រព្យមានខ្លឹម, ខ្លឹមទ្រព្យ :

❖ មាសប្រាក់ជាធនសាររបស់មនុស្ស។

**ធនាករ** (បា.) *ន.* ទីជាកន្លែងកើតធនធាន គឺទីកើតវត្ថុធាតុជាប្រភេទនៃទ្រព្យសម្បត្តិដូចជាប្រេងកាតនិងលោហធាតុជាដើម :

❖ ប្រទេសកម្ពុជាមានធនាករដែកនៅក្នុងខេត្តកំពង់ធំ។

**ធនាគារ** (បា.សំ.) *ន.* ឃ្លាំងដាក់ទ្រព្យ, ឃ្លាំងប្រាក់ :

❖ ផ្ញើប្រាក់ក្នុងធនាគារ។

**ធម្មធរ** (បា.) *ន.* អ្នកទ្រទ្រង់ធម៌, អ្នកកាន់ធម៌, អ្នកប្រតិបត្តិត្រឹមត្រង់តាមគន្លងធម៌។

**ធរណីទ្វារ** *ន.* មេទទឹងទ្វារដែលដាក់ផ្ទាល់នឹងផែនដីឬនិងផ្ទៃខាងក្រោម។

**ធារ** (បា.សំ.) *ន.* ពំនូកស្រូវ, អង្ករឬគ្រាប់អ្វីៗដែលចាក់បង្គររគរទុក :

❖ ធារស្រូវ

❖ ធារទឹក។

☞ ការទ្រទ្រង់, ការទប់ទល់, ការធន់ទ្រាំ, ការឋិតនៅ :

❖ មើលទៅប្រហែលជាមិនធារទេដឹង។

**ធ្ងរ** *គុ.* ទីទៃពីតឹង គឺងាយ, ទូលាយ។

*កិ.* ស្រាក, ស្បើយ (ជំងឺ) :

❖ ជំងឺជីតាខ្ញុំថ្ងៃនេះបានធូរបន្តិច។

**ធ្ងន់ធ្ងរ** *គុ.* ដែលមានចិត្តធ្ងន់, ដែលចេះអត់ចេះទ្រាំ, ដែលមានអំណត់, ប៉ុនអត់ប៉ុនទ្រាំ :

❖ ចិត្តធ្ងន់ធ្ងរ

❖ មនុស្សធ្ងន់ធ្ងរ (និយាយចំពោះតែចិត្ត, អធ្យាស្រ័យប៉ុណ្ណោះក្រៅពីនេះពាក្យដែលផ្សំជាមួយនឹង ធ្ងន់ នេះមានច្រើនត្រូវផ្សំតាមគួរដល់ដំណើរសេចក្ដី)។

**ធ្លារ** *ន.* ផ្លូវឬទីជាសាធារណៈដែលមានជនានុជនទៅមកមិនដាច់ :

❖ ផ្លូវនេះជាធ្លារនៃអ្នកផង។

☞ ផ្លូវទឹក, ផ្លូវខ្យល់ :

❖ ធ្លារទឹក

❖ ធ្លារខ្យល់។

**ធ្នើរ** *ន.* ថ្នាក់ខ្ពស់សម្រាប់បន្ទើរវត្ថុផ្សេងៗ :

❖ ដាក់កន្ទេលលើធ្នើរ។

**ធ្មេញកណ្ដុរ** *ន.* ឈ្មោះគ្រឿងវណ្ណយុត្តិមួយប្រភេទ ( ៉ ) សម្រាប់សម្គាល់ខ្យល់អក្សរ៩តួគឺ ង, ញ, ន, ម, យ, រ, ល, វ បំបែរសូរឱ្យខុសពីសំឡេងប្រក្រតីគឺ ង៉, ញ៉, ន៉, ម៉, យ៉, រ៉, ល៉, វ៉; ប៉ុន្តែបើមានស្រៈឬនិគ្គហិតនៅពីលើត្រូវយកធ្មេញកណ្ដុរមកដាក់ខាងក្រោមវិញ ដូចយ៉ាង ឱ្យកង់, ញ៉ុំញ៉ើ, ប៊ិនប៉ោ...។

**ឆ្លេរ** *កិ.វិ* ឬ *គុ.* ឆ្អែល, ពាក្យសម្រាប់ចម្រើនពាក្យលៀនឱ្យឃើញជាក់ស្ដែង :

- **លៀនឆ្លេរ** : លៀនខ្លាំង។

**នគរ** (បា.សំ.) *ន.* បុរី, ក្រុង :

- ***អ្នកនគរ*** : អ្នកក្រុង។

**នមស្ការ**(សំ.) *ន.* កិរិយាថ្វាយបង្គំ, ការបង្អោនកាយក្រាបប្រណិប័ត; គំនាប់ :

❖ សូមនមស្ការចំពោះព្រះរតនត្រ័យ គឺ ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ!។

**នរេស្វរ** (សំ.ភ្ល.) *ន.* អ្នកដែលជាធំជាងអស់ជន (ក្សត្រទ្រង់រាជ្យ)។ ផ្លាស់ ស្វរ ជា សូរ។

**នារ** *កិ.វិ.* ឬ *គុ.* ដែលមានអាការៈទេរដោយដំណើររត់ឬដោយជ្រាលស្រួលមិនចោត :

- ***រត់នារ*** ឬ ***រត់ខ្នងនារ*** : រត់បន្ទេរខ្នងបន្តិច។
- **ដីនារ** : ដីដែលមានសណ្ឋានជ្រាលស្រួល។

**និករ** (បា.សំ.) *ន.* ពួក,ហ្វូង។

៦. **សត្តនិករ** : ពួកសត្វ, ពួកសត្វលោក។

**និន្នាការ** (បា.) *ន.* អាការៈដែលទ្រេតទេរទៅឬអាការៈដែលលម្អៀងទៅម្ខាងៗ :

❖ ប្រទេសនេះមាននិន្នាការទៅខាងឆ្វេង

❖ ប្រទេសនោះមាននិន្នាការទៅខាងស្តាំ

❖ ប្រទេសអព្យាក្រឹតឋិតនៅត្រង់កណ្តាលឥតមាននិន្នាការទៅខាងឆ្វេង ឬទៅខាងស្តាំឡើយ។

**និរន្តរ** (បា.) *កិ.វិ.* ដែលឥតមានចន្លោះ, ជានិច្ច, ឥតស្រាក, ឥតឈប់,ឥតល្ហែ :

❖ សូមលោកបានប្រកបដោយសេចក្តីសុខជានិច្ចនិរន្តរ!។

**និវត្តនាការ** (បា.) *ន.* អាការៈដែលវិលត្រលប់វិញ, ដំណើរប្រុងនឹងវិលត្រឡប់វិញ :

❖ ធ្វើនិវត្តនាការទៅវិញ។

**និសាករ** (បា.) *ន.* ព្រះចន្ទ។

**និសាចរ** (បា.) *ន.* អ្នកត្រាច់ទៅមកក្នុងវេលាយប់ :

❖ ព្រាយអាកាស

❖ បិសាចដើរយប់។

*គុ.* ដែលត្រាច់ទៅមករកស៊ីក្នុងវេលាយប់ :

❖ មៀម

❖ ទីទុយ

❖ ខ្លែងស្រាក។

**និសីទនាការ** (ឈ.) *ន.* អាការៈនៃកិរិយាអង្គុយ, ការសម្រេចឥរិយាបថអង្គុយ។

**បង្ការ** *កិ.* រារាំង, ប្រុងប្រយត្នការពារសេចក្ដីអន្តរាយឬការខ្វះខាតក្រែងនឹងមានទៅខាងមុខ :

- ដាក់ថ្នាំសង្កូវខ្លះបង្ការផង
- ដាក់បាយបង្ការតាមផ្លូវ។

*ឮ.* ពាក្យបរិវាររបស់ពាក្យ បន្លែ :

**បន្លែបង្ការ** : បន្លែនិងបន្លែរាយរងដែលត្រូវឱ្យមានទុកបម្រុងការខ្វះខាតឬបន្លែច្រើនមុខនេះខ្លះនោះខ្លះ។

**បង្កៀរ** *ឮ.* ពាក្យបរិវាររបស់ពាក្យ បង្គោះ :

**បង្គោះបង្កៀរ** : គោះកៀរយកទាល់តែអស់មិនឱ្យសល់។

**បង្គរ** *កិ.* ធ្វើឱ្យជាគំនរ :

**បង្គរឧស** ឬ **បង្គរភ្លើង** : ដាក់ឧសគរថែមឱ្យភ្លើងឆេះខ្លាំង។

**បង្គួរ** *គុ.* ដែលសមគួរ, ដែលមធ្យម, យ៉ាងកណ្ដាល :

- ក្នុងឆ្នាំនេះដើមឆ្នាំមានភ្លៀងបង្គួរ។

**បង្វែរ** *កិ.* ធ្វើឱ្យវេរ, ធ្វើឱ្យបែរ, បំបែរត្រឡប់ឱ្យវិញ; លើកផ្ដែកវេរឱ្យទៅលើតែមួយៗ។

**បង្ហូរ** *កិ.* ធ្វើឱ្យហូរ :

- បង្ហូរទឹក
- បង្ហូរទឹកភ្នែក។

☞ បំបោលឱ្យជញ្ជ្រំជើងត្រឹកៗ :

❖ បង្ហួរគោ។

**បង្ហួរ** *ន.* តួអង្គជាតរបស់បុរស :

❖ ដងបង្ហួរ។

*កិ.* ធ្វើឱ្យហួរ។

**បង្ហើរ** *កិ.* ធ្វើឱ្យហើរដោយអំណាចខ្យល់ :

❖ បង្ហើរខ្លែងតាមវាលស្រែ។

**បង្ហៀរ** *កិ.* ធ្វើឱ្យហៀរ :

❖ បង្ហៀរទឹក។

*ន.* គ្រឿងសេះសម្រាប់បង្ខាំមាត់ដឹកនាំឱ្យដើរឬជិះកាន់ទាញទប់ :

❖ ទាញបង្ហៀរសេះ។

**បង្អរ** *កិ.* ធ្វើឱ្យអរ, នាំឱ្យអរ។

☞ ច្រើននិយាយថា បង្អួតបង្អរ គឺបង្អួតឱ្យអរ, បង្អួតឱ្យស្ងើច, បង្អួតឱ្យស្រលាញ់។

**បង្អុរ** *កិ.* ធ្លាក់ភ្លៀង, និយាយក្លាយជា បង្អោរ ក៏មាន, កុំសរសេរតាមពីព្រោះពាក្យ បង្អោរ នេះដូចជា ឆ្នាំក្អុរ, អណ្ដុរ, ខ្ទុរ, សម្បុរ និយាយថា ឆ្នាំក្អោរ, អណ្ដោរ, ខ្ទោរ, សម្បោរ ដូច្នោះដែរ, បើគ្រាន់តែនិយាយជាពាក្យសាមញ្ញក៏មិនជាអ្វីឡើយ, កុំសរសេរតាមហ្នឹង។

**បង្ឆោរ** *កិ.* ធ្វើឱ្យចរ, បណ្ដើរឱ្យចរ។

**បញ្ចោរ** *កិ.* កាន់ខ្សែដឹកចេញឱ្យដើរមុន :

❖ បញ្ចោរគោ ។

☞ ធ្វើឧបកិច្ចឱ្យចេញទៅកាន់ទីឯទៀត ដោយយកអង្គុរជាដើម គ្រវាសពោលពាក្យថា មួយ ពីរ បី...ចេរទៅ! (ប្រើក្នុងបែបសែនព្រេនឬអបទេស)។

☞ និយាយពន្យល់ចង្អុលឱ្យចៀសទៅរកអ្នកដទៃឬឱ្យទៅកាន់ទីឯទៀត :

❖ បញ្ចោរឱ្យទៅរកគេឯទៀត។

**បញ្ជរ** (បា.សំ.)*ន.* កម្រោង, រាងរៅ, ទ្រង់ទ្រាយ; បង្អួចដែលមានទ្រង់ទ្រាយជារង្វង់; ...។

☙ **សីហបញ្ជរ** : បង្អួចដែលមានរង្វង់ស្រដៀងនឹងជំហរនៃសត្វសីហៈ។

**បញ្ជោរ** *កិ.* ធ្វើឱ្យជោរ; និយាយលើកជើង, និយាយលើកសរសើរឱ្យឡើងទឹកចិត្តហាក់ដូចជាទឹកជោរ។

☙ **ឡើងបញ្ជោរ** : ដែលឡើងទឹកចិត្តចេញអាការៈរីករាយដោយសារគេបញ្ជោរ។

☙ **ស៊ីបញ្ជោរ** : ដែលបានតែគេបញ្ជោរទើបគាប់ចិត្ត។

**បញ្ជាការ** *ន.* ការបង្គាប់; អ្នកបង្គាប់ :

❖ អ្នកបញ្ជាការ

❖ ធ្វើតាមបញ្ជាការ។

**បញ្ឈរ** *កិ.* ធ្វើឱ្យឈរ :

❖ បញ្ឈរជង្គង់។

*ឧ.* ដែលឈរ។

២ **បញ្ឈរភ្នែក** : ធ្វើភ្នែកទាំងពីរស្ទឹង។

❖ លុះឮគេប្រាប់រឿងហ្នឹងស្រាប់តែបញ្ឈរភ្នែកស្ទឹងតែម្ដង។

**បដិការ** (បា.) *ន.* ការតបវិញ, អំពើតបតវិញ; ដំណើរធ្វើកិច្ចតបគុណ, ការតបស្នងសងគុណ។

**បណីតាហារ** (បា.) *ន.* អាហារដ៏ប្រណីត, ម្ហូបចំណីដែលមានឱជារសឆ្ងាញ់ពិសាដែលគេរៀបតាក់តែងក្នុងពិធីមង្គលផ្សេងៗ :

❖ អ្នកខ្លះដែលមិនសូវធ្លាប់បានបរិភោគប្រណីតាហារ, លោតែបានជួបម្ដងៗបរិភោគទាល់តែតឹងពោះហេលហាល ចាក់ច្រាសក៏សឹងមានព្រោះជាអាហារចំពើបមាត់។

**បណ្ដើរ** *កិ.* ធ្វើឱ្យដើរ, នាំឱ្យដើរ, នាំដើរជាមួយគ្នា :

❖ មេមាន់បណ្ដើរកូន

❖ បណ្ដើរគ្នាទៅលេងផ្សារ។

*កិ.១.* ជាបណ្ដោះអាសន្នសិន :

❖ សុំអ្នកយកសៀវភៅ៥០ក្បាលនេះ ទៅចែកផ្សាយបណ្ដើរៗសិនទៅចាំដល់ថ្ងៃខានស្អែកខ្ញុំនឹងជូន៥០ក្បាលទៀតបង្គ្រប់ជា១០០ក្បាល។

☞ ដែលធ្វើនេះផងនោះផងជាមួយគ្នា :

❖ ស៊ីបណ្ដើរ និយាយបណ្ដើរ។

**បណ្ណាភារ** (បា.) *ន.* ជំនូន, ភស្តុភារ, តង្វាយ; ច្រើននិយាយក្លាយជា បណ្ដាការ (គួរប្រើ បណ្ណាការ វិញទើបត្រឹមត្រូវតាមប្រភពនៃពាក្យ)។

**បណ្ណាគារ** (បា.) *ន.* ផ្ទះជាវសៀវភៅ, ផ្ទះជាវសាស្ត្រា, ផ្ទះជាវក្បួន។

**បណ្ណាធិការ** (បា.)*ន.* អធិការនៃសារពត៌មាន, អ្នកកាន់កាប់ឬទទួលខុសត្រូវខាងកាសែតឬទស្សនាវដ្ដីផ្សេងៗ។

**បន្ថើរ** *កិ.១.* សើៗ, ស្រាលៗ, សន្សឹមៗ, ថ្នមៗ :

❖ ស្ទាបបន្ថើរ

❖ និយាយបន្ថើរ។

**បន្ទរ** *កិ.* ធ្វើឱ្យឮខ្ទរ គឺទះដៃ, វាយក្រាប់ឬពោលពាក្យទទួលចង្វាក់ចម្រៀង។

✍ **ជួយបន្ទរថែម** : ជួយលើកឱ្យបានចិត្ត។

**បន្ទាយឆ្មារ** *ន.* ឈ្មោះប្រាសាទសិលាបុរាណមួយរបស់បុព្វបុរសខ្មែរក្នុងខេត្តបាត់ដំបង (ឥឡូវស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ)។

**បន្ទារ** *ន.* ប៉ែកទទឹងបន្ទះក្ដារ, ប៉ែកទទឹងបន្ទះឈើឬបន្ទះអ្វីៗ :

✍ **បន្ទារពីរតឹក** : ទោលពីរហ៊ុនកន្លះ។

**បន្ទើរ** *កិ.* ធ្វើឱ្យទើរ, ឱ្យអ្នកដទៃយកទៅទើរ, ដាក់លើធ្នើរ :

❖ បន្ទើរខោអាវលើធាងដូង។

**បន្ទេរ** *កិ.* ធ្វើឱ្យទេរ, ធ្វើឱ្យជ្រេ, ធ្វើឱ្យទ្រេត។

**បន្ធូរ** *កិ.* ធ្វើឱ្យធូរ គឺធ្វើមិនឱ្យតឹងមិនឱ្យចង្អៀតពេក :

❖ បន្ធូរខ្សែក្រវាត់។

✍ **បន្ធូរបន្ថយ** : ធ្វើឱ្យធូរឱ្យថយ, ធ្វើឱ្យទូលាយ។

**បន្លែបង្ការ** *ន.* បន្លែច្រើនមុខឬបន្លែវាយរងដែលទុកបង្ការក្រែងខ្វះខាត។

៣.ប្រ. *កិ.* ឬ *កិ.វិ.* និយាយអធិប្បាយផ្សែផ្សំដោយបរិយាយផ្សេងៗ :

❖ និយាយបន្លែបង្ការពីនេះពីនោះ...។

**បន្សារ** *ន.* មុខស្នាមដែលផ្សារ :

❖ មុខបន្សារ។

☞ ទឹកក្រុតដែលបន្សាបសម្រាប់ផ្សារ :

❖ ទឹកបន្សារ។

**បបរ** *ន.* អាហាររាវធ្វើដោយអង្ករស្ងោរ។ បបរមានឈ្មោះច្រើនយ៉ាង :

❖ បបរគ្រឿង

❖ បបរប្រុង

❖ បបរ-ស...។

✍ **បបរឈ្មោល** : បបរគោកខាប់ស្រដៀងនឹងបាយជ្រាយរមួត។

**បបូរ** *ន.* ឈ្មោះសំពត់សូត្រមួយប្រភេទមានរឹមជាក្បាច់ក្បូរផ្សេងៗ :

❖ សំពត់បបូរ។

☞ រឹមមាត់ :

❖ បបូរមាត់។

✍ **ត្រូវប្រយត្នបបូរ** : ត្រូវប្រយត្នមាត់។

**បរ** ***កិ.*** ដឹក, នាំ, បញ្ជូន, បណ្ដោញឱ្យទៅមុខដោយជិះ, ដោយដើរកាល់, ដើរអម, ដើរតាម, តម្រង់ឱ្យត្រង់តាមលំអានតាមផ្លូវដែលត្រូវការ :

❖ បររថ

❖ បររទេះ

❖ បរដំរី។

✍ **បរពល** : លើកកងទ័ពត្រួតពលបណ្ដើរ...។

✍ **លលកបរ** : សត្វលលកដើរបណ្ដើរបញ្ចេញសំឡេងញាប់រន្ថាន់រនៗបណ្ដើរ។

**បរិក្ខារ** (**បា.**) ***ន.*** គ្រឿងប្រដាប់, គ្រឿងប្រដាប់សម្រាប់ប្រើប្រាស់ :

❖ គប្បីថែទាំសម្អាតគ្រឿងបរិក្ខារផ្សេងៗមានសំពត់ខោអាវជាដើមឱ្យស្អាតជានិច្ច។

**បរិបូរ** (**បា.សំ.**) ***គុ.*** ដែលគ្រប់គ្រាន់, ដែលពេញគ្រប់គ្រាន់, ដែលពេញលេញ, ដែលសម្បូរ; ដែលឆ្អែតហើយ :

❖ ម្ហូបចំណីបរិបូរ

❖ ទ្រព្យធនបរិបូរ។

☞ ប្រើជា ***កិ.*** ក៏បាន :

❖ ណ្ហើយ, ប៉ុណ្ណឹងចុះបរិបូរហើយ!។

☞ ប្រើជា **កិ.ឧ.** ក៏បាន :

❖ ខ្ញុំទទួលទានបរិបូរហើយ!។

**បរិពារ** (បា.សំ.ក្ល.) *ន.* អ្នកចោមរោមកំដរ, អ្នកហែហមជាកិត្តិយស; អ្នកត្រៀមខ្លួនរង់ចាំបម្រើ, អ្នកបម្រើ, បរិវារ។

**បរិវារ** (បា.សំ.) *ន.* អ្នកចោមរោមកំដរ, អ្នកហែហមជាកិត្តិយស; អ្នកត្រៀមខ្លួនរង់ចាំបម្រើ, អ្នកបម្រើ, បរិពារ។

**បរិហារ** (បា.សំ.) *ន.* ការពោលដោះស្រាយ, ការពោលដោះប្រស្នា; ការរក្សា, ការថែទាំ :

❖ ធ្វើបរិហារ។

*កិ.* ឬ *កិ.វិ.* ដើរបរិហារ, និយាយបរិហារ គឺនិយាយផ្សាយសេចក្ដីឱ្យឮសុសសាយ (ច្រើនប្រើតែខាងការនិយាយអាក្រក់ពីគេ) :

❖ កុំបរិហារកេរ្តិ៍គេ។

**បវរ** (បា.) *គុ.* ប្រសើរ, លើសលែង, ថ្លៃថ្លា :

❖ ធម៌ដ៏បវរ

❖ ទ្រព្យដ៏បវរ។

**បាចសរ** *ន.* ឈ្មោះល្បែងលេងទឹកមួយប្រភេទសម្រាប់ពួកក្មេងលេងបាចទឹកមុជទឹកចាប់ញៀចគ្នា គឺក្មេងម្នាក់បាចទឹកទៅរកក្មេងម្នាក់ដោយស្រែកថាបាចសរ! ហើយមុជគេចក្នុងទឹក, ក្មេងម្នាក់ដែលមិនមុជទឹកនោះប្រុងចាប់ញៀច, បើឃើញងើបត្រង់ជិតខ្លួនក៏ស្ទុះទៅចាប់ស្លឹកត្រចៀកជាប់ស្រែកថាញៀច!, បើអ្នកមុជងើបនោះគេចរួចក៏ខានញៀច :

❖ លេងបាចសរ

❖ ល្បែងបាចសរ (ល្បែងបាចទឹកសររកគ្នា)។

**បាទចារ** (បា.សំ.) *ន.* ការដើរដោយជើងឥតមានយានជំនិះ។

**បាយបត្តបូរ** (បា.) *ន.* បាយបំពេញបាត្រ (បាយរាប់បាត្រ) ឬបាយសម្រាប់បំពេញបាត្រ គឺបាយដែលទាយកគេទុកបម្រុងនឹងថែមក្រែងភិក្ខុសង្ឃខ្វះខាតឆាន់មិនគ្រាន់។ ហៅម្យ៉ាងថា បាយបិតបូរ “បាយសម្រាប់បំពេញផលឱ្យប្រេត” គឺបាយដែលទាយកប្រគេនភិក្ខុសង្ឃហើយឧទ្ទិសផលបុណ្យជូនទៅបុគ្គលដែលចែកឋានទៅកាន់បរលោកហើយ។

**បារ** *ន.* បិសាចដែលបន្លាចកូនក្មេងឱ្យមមាលឃើញអ្វីៗដែលគួរខ្លាច :

❖ បារបន្លាច។

*កិ.* កាយយកចេញ :

❖ បារអាចម៍ដី។

**បិតរ** ឬ **បិដរ** *ន.* បិតា (ឪពុក)។ ពាក្យនេះខ្មែរយើងប្រើជាឈ្មោះព្រះរាជពិធីមួយមានចាក់ទឹកដូងច្រូចសែនរំព្ញកដល់ពួកបុព្វបុរសក្នុងរាជត្រកូល ហៅថា ថ្វាយព្រះបិតរ ឬ ថ្វាយព្រះបិដរ គឺសែនរំព្ញកទៅព្រះញាតិវង្សានុវង្សដែលស្ដេចទៅកាន់បរលោកហើយ។

**បុប្ផាកេសរ** (បា.) *ន.* កេសរផ្កា (លម្អងផ្កា)។ **ព.ប្រ.** ពាក្យសម្រាប់ហៅលើកស្ត្រីដែលជាទីស្រលាញ់ថាមានលម្អដូចជា កេសរផ្កា។

**បួរ** *ន.* ថែបធ្វើដោយមែកឈើទាំងស្លឹកសម្រាប់ឱ្យដង្កូវនាងតោងវារពន្លសំបុក (ហៅតាមទម្លាប់ស្រុក, អ្នកស្រុកខ្លះហៅថែបនាង)។

*៤.* សរីរាវយវៈរបស់ពួកសត្វខ្លះមានគោជាដើមនៅត្រង់ក្រោម-កមាន សណ្ឋានយារចុះស្រដៀងនឹងផ្គិតឃ្មុំ :

❖ ប្ញូរគោ។

☞ ឈ្មោះក្បាច់ឬកម្រងមានសណ្ឋានស្រដៀងនឹងប្ញូរដាក់ស៊ែមសំយុង ជាលម្អដោយខ្សែក :

❖ ក្បាច់ប្ញូរ

❖ ដាក់ប្ញូរស៊ែម។

**បែរ** *កិ.* ងាកប្រែមុខទៅខាងឬមកក្រោយ; ងាកចេញឃ្លាតពីប្រក្រតីដើម; ត្រឡប់ :

❖ បែរមុខ

❖ បែរខ្នង

❖ បែរចិត្ត។

*១.* **បែរបែក** : ងាកបែកឃ្លាតចេញពីគ្នា។

*២.* បែរជា... ត្រឡប់ជា... បែរជាខានទៅវិញ។

**បោរ** *គុ.* ដែលពើង, ដែលរមួល, ដែលវៀច :

❖ ក្តារបោរ

❖ មេទ្វារបោរ។

**បំបរ** *កិ.* កំចោកឱ្យខ្ចាត់ចេញឆ្ងាយ :

❖ បណ្តេញបំបរបណ្តេញកំចោកដោយកំហែង, ដោយបង្ខំ។

**បំបែរ** *កិ.* ធ្វើឱ្យបែរ, ធ្វើឱ្យងាក, ធ្វើឱ្យរេ :

❖ បំបែរសេចក្តី

❖ បំបែរមុខរទេះ។

**បំបោរ** *កិ.* ធ្វើឱ្យបោរ គឺធ្វើឱ្យពើង, ធ្វើឱ្យរមួល, ធ្វើឱ្យវៀច។

✍ **បំបះបំបោរ** : ធ្វើឱ្យបះបោរ។

**បំផូរ** *កិ.* ធ្វើឱ្យឡើងប៉ផូរ; ធ្វើឱ្យឡើងដោរស្រុះស្មើគ្នា :

❖ បំផូរអុតឬបំផូរផ្កាឈើ។

**បំពារ** *កិ.* ធ្វើឱ្យពារលើ, ពារទាំងបំពាន; រំលោភដាក់, រំលោភលើ :

❖ បរសេះបំពារលើដំណាំគេ

❖ ជិះសេះបំបោលបំពារលើគេ។

✍ **បំពារបំពាន** : ឱ្យពានពារលើ។

✍ **បំប៉ះបំពារ** : បំពារឱ្យប៉ះលើ។

**បំពួនស្នួរ** *ន.* ឈ្មោះនំស្រស់មួយប្រភេទធ្វើដោយម្សៅដំណើបលញ់ស្រោប បំពួនដុំស្ករបំបាំងបាត់មើលមិនឃើញ :

❖ នំបំពួនស្ករ, ហៅនំផ្លែអាយក៏បាន; ជួនកាលមានអ្នកខ្លះហៅថា នំកើតក្តី ក៏បានដែរ។

**បំពោរ** *កិ.* ធ្វើឱ្យពោរ គឺធ្វើឱ្យពោរឡើង, ធ្វើឱ្យមានពោរពាស :

❖ បំពោរទឹក

❖ បំពោរភោជនាហារ។

✍ **បដិការគុណ** : គុណដែលត្រូវធ្វើកិច្ចតបស្នងវិញ។

**ចាំងស្មើរ** ***កិ.វិ.*** ឬ ***គុ.*** ដែលនៅស្នាក់ស្មើរមិនទាន់ស៊ប់ឬដែលនៅស្នាក់ស្មើរមិនទាន់ដាច់ស្រេច, ដែលនៅក្នុងការរារែក :

❖ សម្ដីបាំងស្មើរ

❖ គំនិតបាំងស្មើរ

❖ និយាយបាំងស្មើរ។

**ប្ដូរ** ***កិ.*** ផ្លាស់ពីមួយឱ្យទៅមួយ, ផ្លាស់យកមួយមកឱ្យមួយទៅ, ផ្លាស់ពីនេះដាក់ទៅនោះ, ដូរ។

✍ **ប្ដូរជីវិត** : ប្រថុយស្លាប់ជួស។

✍ **ប្ដូរផងប្ដូរថ្លៃ** : ហ៊ានតស៊ូតតញញើត។

✍ **ប្ដូរផ្ដាច់** : ដាច់ចិត្តប្រថុយស្លាប់រស់ជាមួយគ្នា។

✍ **ប្ដូរស្លាប់ប្ដូររស់** : ហ៊ានប្ដូរជីវិតឱ្យស្លាប់ខ្លួនទុកគេឱ្យរស់ឬស៊ូស្លាប់រស់ផងគ្នា...។

**ប្រការ** ***ន.*** ប្រភេទ, វិធី, បែប, បែបយ៉ាង; ទំនង; សេចក្ដីដោយឡែក :

❖ សូមអ្នកបានប្រកបដោយសុខសួស្ដីកុំបីឃ្លាតក្លាយទៅជាបការៈដទៃឡើយ។

☞ ប្រការ១, ប្រការ២, ខ១, ខ២,...។

✍ **ច្រើនប្រការ** : ច្រើនយ៉ាង។

**ប្រគរ** *កិ.* គរលើគ្នាច្រើនជាន់ច្រើនតម្រួត :

❖ ប្រគរខស

❖ ប្រគរបាវស្រូវ។

**ប្រណីតាហារ** (សំ.) *ន.* អាហារដ៏ប្រណីត, ម្ហូបចំណីដែលមានឱជារសឆ្ងាញ់ពីសាដែលគេរៀបតាក់តែងក្នុងពិធីមង្គលផ្សេងៗ :

❖ អ្នកខ្លះដែលមិនសូវធ្លាប់បានបរិភោគប្រណីតាហារ, លោតែបានជួបម្ដងៗបរិភោគទាល់តែតឹងពោះហៀលហាល ចាក់ច្រាសក៏សឹងមានព្រោះជាអាហារចំពើបមាត់។

**ប្របេរ** *ន.* រឹមបបូរមាត់; ពពីរមាត់ជាដើម :

❖ ប្របេរមាត់។

**ប្រភស្សរ** (សំ.) *ន.* សម្បុរភ្លឺផ្លេកៗ :

☙ **ពន្លឺចិត្តប្រក្រតី** : ពន្លឺចិត្តដែលមិនទាន់មានគ្រឿងសៅហ្មងប៉ះពាល់។

*គុ.* ដែលភ្លឺផ្លេក, ដែលភ្លឺចាំង, ពណ៌គ្រាប់ភ្លៀង :

❖ មានកាលខ្លះ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ចេញដោយឈានឫទ្ធិនូវរស្មី ៦ពណ៌ឱ្យផ្សាយចេញអំពីព្រះសរីរកាយគឺ រស្មីពណ៌ខៀវ, លឿង, ក្រហម, ស, ហង្សបាទ, ប្រភស្សរ ហៅថា ឆព្វណ្ណរង្សី ឬ ឆ័ព្វណ៌រស្មី ឬក៏ ឆព្វណ៌រស្មី។

**ប្រភាករ** (សំ.) *ន.* អ្នកធ្វើពន្លឺគឺ ព្រះអាទិត្យ, ព្រះចន្ទ, ភ្លើងៗ

**ប្រយូរ** *ន.* ពូជពង្ស, ត្រកូល, ផៅ, ផៅពង្ស, ផៅសន្ដាន។

☙ **ប្រយូរញាតិ** : ញាតិដែលជាប់វង្សត្រកូលជាមួយគ្នាមក។

**ប្រសើរ** *គុ.* ល្អកន្លង, ប្រពៃពេក, ត្រកាល, ថ្លៃថ្លា, គួរសរសើរ, គួរស្ងើច :

❖ ទ្រព្យប្រសើរ

❖ ចំណីប្រសើរ

❖ មនុស្សប្រសើរ។

**ប្រហារ** (**សំ.**) *ន.* ការទះ, ការតប់, ការវាយ, ការសំពង, ការកាប់, ...។

☞ ខ្មែរយើងច្រើនប្រើជា *កិ.* សំដៅសេចក្ដីថា "កាប់, សម្លាប់"។

**ប្រហារជីវិត** : សម្លាប់។

**ប្រហារដោយដំបង** : វាយនឹងដំបង។

**ប្រហួរ** *កិ.* ដណ្ដើមគ្នាហួរ, ហួរប្រជែងគ្នា, ហួរខ្ទេចខ្ទី។

*គុ.* ដែលរហែករយះរយាយឬដែលចាស់រយាក។

*ឲ.* ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ ប្រហែក ថា :

❖ ប្រហែកប្រហួរ។

**ប្រហើរ** *ន.* ឈ្មោះសម្លមួយបែបបង់គ្រឿងមានស្លឹកគ្រៃនិងមើមខ្ញីជាប្រធានមានក្លិនប្រហើរ :

❖ សម្លប្រហើរ (ទីទៃពីសម្លម្ជូរ)។

*គុ.* ឈ្ងុយស្មើយ៉ាងដូចក្លិនស្លឹកតើយ, ស្លឹកម្ទេសជាដើម :

❖ ក្លិនប្រហើរ

❖ ធុំប្រហើរ។

**ប្រាការ** (**សំ.**) *ន.* កំពែង; បន្ទាយ, រាជវ័តិ។

**ផ្សាំពីរ** (**ប.សំ.**) ចំនួនប្រាំនិងពីរ(៧)។

**ប៊ីយេរ** *ន.* ឈ្មោះមេរ័យមួយប្រភេទមានប្រភពឯបរទេស (**បារ.** Biére) ខ្មែរភាគច្រើនហៅមេរ័យប្រភេទនេះថា ស្រាបៀរ (**អង.** Beer), អ្នកខ្លះហៅ ឡាប់យេរ, ខ្លះហៅ ឡាបយ៉េរ ក្លាយសំឡេងមកពី **បា.** La biére នុះឯង។

**ផស្សាហារ** (**បា.**) *ន.* អាហារ គឺ ផស្សៈដែលទុកជាអាហារមួយប្រភេទ សំដៅយកការប៉ះប្រសព្វគ្នានៃអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅ ដែលមានវិញ្ញាណជា បច្ច័យ...។

**ផុរ** ឬ **ផុល** *កិ.* ពុះហៀរ, ខ្ពុរ, ខ្សុលចេញ, រសោះចេញ :

- ❖ បបរផុរឬបបរផុល
- ❖ ស្លូត្រផុរឬស្លូត្រផុល។

**ផេរ** *កិ.វិ.* ឬ *គុ.* ដែលល្អិតស្មេញក្រាស់ :

- ❖ ល្អិតផេរ
- ❖ ចេញផេរ
- ❖ កន្ទេលផេរ។

**ផែនការ** *ន.* គម្រោងការដែលត្រូវធ្វើ, គោលការដែលត្រូវធ្វើ :

- ❖ ធ្វើតាមផែនការ
- ❖ ផែនការ៥ឆ្នាំ។

**ផ្កាចារ** *ន.* ឈ្មោះទូកតូចមួយបែបមានទ្រង់ទ្រាយលំនាំត្របកផ្កាចារ :

- ❖ ទូកផ្កាចារ។

**ផ្គុរ** *ន.* សូរលាន់រំពងឮខ្ទ័រវ័ងៗឯអាកាស :

❖ ផ្គរលាន់

❖ ផ្គរលាន់ឆ្លើយឆ្លង។

**ផ្ងារ** *កិ.* ឬ *កិ.វិ.* ប្រែយកពោះមកខាងលើ យកខ្នងទៅខាងក្រោមឬយកមុខ មកខាងលើយកក្រោយទៅខាងក្រោម :

❖ ដាក់ផ្ងារ

❖ ដេកផ្ងារ។

✍ **ផ្ងារចង្ក្រាង** : ផ្ងារច្រងាង។

✍ **ផ្ងារស្រទាង** : ផ្ងារដូចគេត្រដាង។

**ផ្ទារ** *កិ.* ធ្វើឱ្យមានបន្ទារ :

✍ **អារផ្ទារ** : អារឈើឱ្យបានជាបន្ទារ។

**ផ្ទុរ** *ន.* ដំបូលរទេះ (ហៅក្លាយជា ផ្ទុល ឬ ផ្ទូរ ក៏មាន)។

**ផ្ទូរ** *ប.* ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ ផ្ទេរ ថា :

✍ **ផ្ទេរផ្ទូរ** : ផ្ទេរចុះផ្ទេរឡើងសម្រួលការ។

**ផ្ទេរ** *កិ.* ផ្លាស់ចំណុះ, ផ្លាស់បន្ទុកពីមួយដាក់ទៅលើមួយដើម្បីឱ្យមួយនៅទំនេរ :

❖ ផ្ទេរអង្ករ

❖ ផ្ទេរស្រូវ។

**ផ្នូរ** *ន.* ពំនូកដីដែលពូនលើរណ្ដៅសាកសព :

❖ ផ្នូរខ្មោច។

**ផ្ទៀវ** *ន.* បន្ទោះឫស្សីដែលរែងជាផ្ទាំងដាក់អបនឹងធ្នង់ក្រោមទ្រូពងរទេះ :

❖ ផ្ទៀវរទេះ។

**ផ្សារ** *ន.* ទីប្រជុំលក់ទិញរបស់ផ្សេងៗ គឺប្រជុំផ្ទះឬរានតូចធំដែលគេដាក់ទំនិញលក់ដូរ។

*កិ.* ភ្ជាប់ភ្ជិតដោយទឹកបន្សារ :

❖ ផ្សារផ្ទាំងស្ពាន់

❖ ផ្សារឡូតស័ង្កសី។

**ផ្សួងផ្សារ** *កិ.* ឬ *កិ.វិ.* អរង់, បង្អែបង្អង់, រ៉ែរ៉ៃ។

**ផ្អុរ** *ន.* ឈ្មោះត្រសក់មួយប្រភេទ ដើមវារផ្ទាល់នឹងដី ផ្លែប្រើជាអាហារបានច្រើនបែប :

❖ ញាំត្រសក់ផ្អុរ

❖ អន្លក់ត្រសក់ផ្អុរ។

**ផ្អួរ** *គុ.* ដែលខូចរសជាតិប្រក្រតីព្រោះអាប់អួ, ដែលខូចរសជាតិប្រក្រតីព្រោះទុកយូរហួសកាលកំណត់ :

❖ អង្ករផ្អួរ។

☞ ដែលមានក្លិនក្តិះបន្តិចៗព្រោះអាប់អួ :

❖ ធុំផ្អួរ

❖ ក្លិនផ្អួរ។

**ពង្សាវតារ** (បា.ស្ក.) *ន.* រឿងរ៉ាវតាមលំដាប់នៃវង្សត្រកូល, ប្រវត្តិដែលឆ្លងពីសង្កាត់មួយមកសង្កាត់មួយ, ដំណើរសេចក្ដីសម្ដែងអំពីតំណនៃវង្សត្រកូល :

- ពង្សាវតារលោក
- ពង្សាវតារកម្ពុជរដ្ឋ។

**ពនេចរ** (បា.ស្ក.) *ន.* អ្នកត្រាច់ទៅក្នុងព្រៃ (ព្រានព្រៃ)។

**ពាក្យកាព្យ**

| | |
|---|---|
| គ្រានោះពនេចរ | មានអំណរពន់ពេកក្រៃ |
| រិះរកឧបាយថ្មៃ | បាញ់ដំរីឱ្យបានងាយ។ |

**ពន្ធនាការ** (បា.សំ.) *ន.* អាការៈចង, អាការៈដែលជាប់, អាការៈដែលជំពាក់នៅ :

- មានពន្ធនាការរូបរឹត។

**ពន្ធនាគារ** (បា.សំ.) *ន.* ផ្ទះសម្រាប់ឃុំឃាំង, គុក :

- ជាប់ពន្ធនាគារ
- នាយកពន្ធនាគារ។

**ពន្យារ** *កិ.* ធ្វើឱ្យយារ, ទាញទម្លាក់ឱ្យយារចុះ :

- ពន្យារខ្សែ
- ពន្យារពេល។

**ពពារ** *ន.* អាការៈសម្បើមរបស់ពស់ដែលប្រឹងដំឡើងកឱ្យរីកធំជាងប្រក្រតី :

- ពស់ដកពពារ។

**ពពីរ** *ន.* រឹមបបូរមាត់, ហាមបបូរមាត់ :

❖ ពពីរមាត់។

**ពពុះ** ឬ **ពពុល** *គុ.* ដែលពុរខ្លាំង គឺដែលពុលដោយបែកឬដោយជោរខ្លាំង, ដោយហើមខ្លាំង :

❖ ដីបែកភក់ពពុរ

❖ ហើមសាច់ពពុរ។

☞ ប្រើជា *ន.* ផងក៏បាន :

❖ ពពុរដី

❖ ពពុរផេះឬពពុលដី។

**ពរ** (**បា.សំ.ភ្ល.**) *ន.* គុណជាតដ៏ប្រសើរ; គុណជាតឬអ្វីៗដែលគួរប្រាថ្នា, គុណជាតគួរចង់បាន, គុណជាតគួរជ្រើសរើសយកតាមគាប់ចិត្ត :

❖ ឱ្យពរ

❖ ទទួលពរ។

☞ ពាក្យនេះប្រើជា *គុ.* ក៏បាន ប្រែថា “ប្រសើរ, ដែលគួរប្រាថ្នា, ដែលគួរចង់បាន, ដែលគួរជ្រើសរើសយកតាមគាប់ចិត្ត”; ខ្មែរប្រើក្លាយមកជា ព្រះ ក៏មាន។

*កិ.* លាបបូកព្រលាំងដោយជ័រឱ្យក្រាស់ជិតសាច់ពុំឱ្យជ្រាបទឹកបាន :

❖ ពរទូក

❖ បិទពរ។

**ព័រ** *ន.* មនុស្សចុងស្រុកមួយពួកកើតនៅក្នុងអាណាខេត្តកម្ពុជរដ្ឋមានភាសាសម្ដីផ្សេងពីខ្មែររាប់បញ្ចូលក្នុងពួក គួយ, រដែ, ស្ទៀង :

❖ ជាតិព័រ

❖ ពួកព័រ (ក្នុងសម័យឥឡូវរាប់ថាជាខ្មែរដូចគ្នា ស្មើគ្នាទាំងអស់)។

**ពលក្ការ** ឬ **ពលាត្ការ** (**បា.** ឬ **សំ.**) *ន.* ការកំហែង, ការគំរាម :

❖ វាហ៊ានធ្វើពលក្ការតាមអំពើចិត្តឥតកោតក្រែងច្បាប់។

**ពលិការ** (**បា.សំ.**) *ន.* កិរិយាធ្វើនូវពលី, ការធ្វើពលី :

❖ ធ្វើពលិការ

❖ តាំងពលិការ។

☞ ខ្មែរយើងច្រើននិយាយតាមស្រួលមាត់ថា ព្លិការ ឬ ព្លីការ; ច្រើនសំដៅចំពោះការបូជា, ច្រើនសំដៅចំពោះការបួងសួង, ច្រើនសំដៅចំពោះការតាំងហោមពិធីផ្សេងៗ។

**ពាឌីរ** (**សំ.**) *ន.* កម្មករ គឺអ្នកធ្វើការឈ្នួល, កូនឈ្នួល។

**ពាណិជ្ជការ** (**បា.ភ្ល.**) *ន.* អ្នកធ្វើជំនួញ។

✍ **ក្រសួងពាណិជ្ជការ** ឬ **ក្រសួងពាណិជ្ជកម្ម** : ក្រសួងត្រួតត្រាលើពួកអ្នកធ្វើជំនួញ, ក្រសួងខាងជំនួញ។

**ពានរ** (**បា.សំ.ភ្ល.**) *ន.* សត្វមានរូបរាងស្រដៀងនឹងមនុស្ស (ស្វា)។

**ពារ** (**បា.សំ.ភ្ល.**) *កិ.* (**វារ** "ឃាត់, រារាំង, ទទឹងទាស់") ប៉ះលើឬប៉ះត្រូវទាំងស្រុង :

❖ ពារបង

❖ ដើរពារគល់ឈើ។

*ន.* (វារ) ថ្ងៃ :

✍ **ពារពុធ** : ថ្ងៃពុធ។

**ពិការ** (**បា.សំ.ក្ល.**) ***គុ.*** ដែលខូចអវយវៈណាមួយប្រើការមិនកើតដូចបាក់ដៃ, បាក់ជើងជាដើម :

❖ មនុស្សពិការ។

**ពិជិតមារ** (**បា.សំ.ក្ល.**) *ន.* លោកអ្នកឈ្នះមារ (ព្រះសម្មាសម្ពុទ្ធ) :

❖ ព្រះពិជិតមារ (ព្រះឈ្នះមារ)។

**ពិដោរ** ***គុ.*** ដែលមានក្លិនក្រអូបល្អ, ដែលក្រអូបសាយ :

❖ ក្លិនពិដោរ

❖ ពិដោរក្លិនសីល។

**ពិទ្យាធរ** (**សំ.ក្ល.**) *ន.* អ្នកទ្រទ្រង់វិជ្ជា; ភូតពួកមួយអាស្រ័យនៅនាហិមវន្តប្រទេសមានវិជ្ជាអាចឱ្យសម្រេចប្រយោជន៍បាន; បើស្ត្រីហៅថា ពិទ្យាធរិណី។

**ពិធុរ** (**សំ.បា.ក្ល.**) *ន.* សេចក្ដីលំបាក, សេចក្ដីទុក្ខម្ហេញ; ការព្រាត់ប្រាស, ការបែកចិត្តពីគ្នា។

☞ នាមអ្នកប្រាជ្ញម្នាក់ (អន្តពោធិសត្វ) មានតំណាលក្នុង **វិធុរជាតក** :

❖ សាស្ត្រាព្រះពិធុរ

❖ រឿងព្រះពិធុរ (ហៅថា វិធុរបណ្ឌិត ក៏បាន)។

**ពិម្ពិសារ** (បា.) *ន.* ព្រះនាមព្រះមហាក្សត្រមគធរដ្ឋមួយព្រះអង្គក្នុងពុទ្ធកាល មានរឿងតំណាលជាញឹកញយក្នុងគម្ពីរពុទ្ធសាសនា; ទ្រង់បានសាងវត្តឈ្មោះ វេឡុវ័នជាដំបូងបំផុតថ្វាយព្រះសក្យមុនីសម្មាសម្ពុទ្ធ។

**ពិស្ដារ** (សំ.ភ្ល.) *ន.* សេចក្ដីទូលាយ, សេចក្ដីវែង; ដំណើរយឺតយូរ :

❖ និយាយដោយពិស្ដារ។

☞ ខ្មែរប្រើជាឈ្មោះធម៌ព្រះអភិធម្មបាលីដែលលោកអ្នកប្រាជ្ញពីជាន់មុនបានដកស្រង់ពី ព្រះអភិធម្មបិដក និង អដ្ឋកថាព្រះអភិធម្ម យកមករួបរួមចារឹកទុកក្នុងភាណវារបាលី សម្រាប់ព្រះភិក្ខុសង្ឃសូត្រដារជាធម៌វែងជាងសត្តប្បករណ៍ ឬ សម្ពុទ្ធប្បករណ៍ :

❖ និមន្តលោកសូត្រពិស្ដារ។

☞ ប្រើជា *កិ.វ. ឬ គុ.* ក៏បាន :

✍ **សេចក្ដីពិស្ដារ** : សេចក្ដីវែង, សេចក្ដីទូលាយ។

✍ **និយាយពិស្ដារ** : និយាយរៀបរាប់ដោយសព្វគ្រប់។

**ពិស្ណុករ** *ន.* ពាក្យហៅឃ្លាតក្លាយមកអំពី **បា.** វិស្សុកម្ម, **សំ.** វិឝ្វកម៌ន៑ ដែលជានាមនៃទេវតា អ្នកមានចំណេះខាងការជាងជាអ្នកសម្រេចកិច្ចការថ្វាយព្រះឥន្ទ្រដែលធ្លាប់ហៅថា ព្រះវិស្សុកម្ម។ ពួកជាងពីបុរាណច្រើនជឿថាទេវតា

នោះជាគ្រូធំលើជាងទាំងឡាយ, ព្រោះហេតុនោះបានជាហៅរណ្ដាប់ជាទ្រនឹបជាងឬទ្រនឹបគ្រូថា រៀមព្រះពិស្ណុការ។

**ពិឡារ** (បា.) *ន.* ឆ្មា; បើញីជា ពិឡារី ឬ ឱឡារី។

**ពីរ** (ប.សំ.) មួយគូបគ្នា គឺមួយនិងមួយ (២)។

**ពុរ** *កិ.* ដែលជោរជ្រាយសាច់ដោយទង្គិច, ប៉ះ, ច្របាច់ :

❖ ពុរសាច់

❖ ផ្លែឈើពុរ

✍ **ពុរពង** : ពងដោរឡើងសាច់ជោរជ្រាក។

✍ **ពុរចិត្ត** : ជ្រោកចិត្ត, ខ្វល់ចិត្តខ្លាំង។

**ពួរ** *ន.* ខ្សែធំៗសម្រាប់ចងក្រៀកអ្វីៗដែលធំ, ដែលធ្ងន់ :

❖ ពួរផ្ទៃ

❖ ពួរជក់ដូង។

✍ **ពួរចាំង** : ពួរផ្ទៃខ្នាតធំបំផុត។

☞ ឈើពួកខ្លះដែលដុះចេញជាឫសសំយុងចុះមកក្រោមឬថ្មដែលដុះជាសាច់ត្រង់គល់ផតទាំងពីរខាងខ្ពស់កណ្ដាលទ្រនុង :

❖ ពួរជ្រៃ

❖ ពួរស្រឡៅ។

✍ **សរសៃពួរ** : សរសៃធំដែលមានសណ្ឋានស្រដៀងនឹងខ្សែពួរ។

**ព្យេរ** *ឧ.* ចំណងចិត្តក្រោធដែលចងដោយព្យាបាទបម្រុងនឹងសងសឹកវិញ, ចំណងចិត្តជាសត្រូវ :

- ❖ ចងពៀរ
- ❖ មនុស្សមានពៀរ។

**ពោរ** *ឧ.* ដែលជន់ជោរឡើង, ដែលឡើងកំពុង :

- ❖ ពពឹកភ្នែកពោរ
- ❖ ទឹកពោរមាត់ច្រាំង។

**ពុំចេរ** *ឧ.* សូមឱ្យតែ, តាមតែ។

**ពាក្យភាព្យ**

| | |
|---|---|
| ខ្ញុំសូមក្រាបលាទៅ | ផ្ញើរាជ្យនៅក្បូត្រថ្ងៃថ្លា |
| ពុំចេរទ្រង់មេត្តា | អត់ទោសប្រោសសត្វជាខ្ញុំ។ |

☞ មួយយ៉ាងទៀត ពុំចេរ ថា ពុំដឹង, ពុំចេះ, ពុំស្គាល់។

**ពាក្យភាព្យ**

| | | |
|---|---|---|
| ប្រើដឹងតុលហាប | ប្រើដឹងខ្ពស់ទាប | មានភ្នែកយល់ល្អ |
| ទោះដឹងទឹកមាស | ពុំចេរនូវថ្ម | ទោះដឹងដី-ស |
| | ពុំចេរសំបុត្រ។ | |
| ផ្ញើស្រែមើលស្មៅ | សន្តានមើលផៅ | បម្រើមើលពុត |
| ទោះដឹងពុតជា | ពុំចេរពុតត្បុត | ដឹងចិត្តបរិសុទ្ធ |
| | ពុំចេរតវិឃា។ | |

**ពំនៀរ** *ន.* ពៀរ, ដំណើរចងពៀរ :

❖ ខំអត់ទ្រាំទៅ កុំធ្វើឱ្យមានពំនៀរទៅខាងមុខ!

**ព្យតិហារ** (**សំ.ភ្ល.**) *ន.* ការឈ្លោះប្រកែកប្រដែកតបតឬការវាយដំច្រំធាក់, ដាល់, តប់, ទះ, ទាត់គ្នា :

❖ ធ្វើព្យតិហារ។

**ព្យាករ** (**បា.**) *កិ.* ធ្វើឱ្យប្រាកដ, ធ្វើឱ្យជាក់ច្បាស់; ពោលអួត; ទាយ :

❖ ហោរព្យាករថា ឆ្នាំនេះមានទឹកភ្លៀងច្រើន។

**ព្យាបារ** (**បា.**) *ន.* កិច្ចការ; ដំណើរទទួលធ្វើកិច្ចការផ្សេងៗ, ការទទួលធុរៈ, ការទទួលរ៉ាប់រង; សេចក្តីខ្វល់ខ្វាយ, ការខ្នះខ្នែង; ឧបាយ :

❖ ធ្វើព្យាបារ

❖ ទទួលព្យាបារ។

**ព្យួរ** *កិ.* ពាក់, ផ្តក់, ចងបន្តោក, បន្តោង :

❖ ព្យួរសម្លៀតនឹងនាគទណ្ឌ

❖ ព្យួរសម្ពាយនឹងមែកឈើ។

🙞 **ព្យួរទោស** : កាត់ទោសផ្អាកទុកមានកំណត់កាល។

🙞 **ព្យួរក្រពះ** : ក្រពះដែលញាត់ឡើងលើមិនធ្លាក់ចុះក្រោមបណ្តាលឱ្យក្អួតចង្អោរឬឱ្យបរិភោគអាហារពុំបាន។

**ព្យោការ** (**សំ.ភ្ល.**) *ន.* ជាងដែក។

**ព្រានរ** *កិ.* ពដោយខ្នងទាំងមូលឬដាក់ពាក់ពីលើខ្នងទាំងមូល :

- ព្រនរកូន
- ព្រនរមនុស្សឈើ។

**ព្រមរ** *ន.* ជ័រដែលស្លលាយវត្ថុស្អិតផ្សេងៗមានកាកលក្តឬក្រមួនឃ្មុំជាដើម សម្រាប់បិទពរឬចាក់បញ្ចូលក្នុងក្រហូងគ្រឿងរចនា ដោយប្រាក់ឬចាក់ក្នុងដោះគងធំជាដើម :

- ស្លព្រមរ
- ចាក់ព្រមរ
- ដាក់ព្រមរ។

**ព្រវារ** *គុ.* ដែលពិការដើរបានតែវារឬដែលពិការទន់ជើងទន់ដៃល្វីតល្វែតដើរបានតែតោងគេឬដោលទប់នឹងដំបង, ឈើច្រត់ :

- ពិការព្រវីព្រវារ
- មនុស្សព្រវីព្រវារ
- ដំណើរព្រវីព្រវារ។

*កិ.វិ.* ដើរព្រវីព្រវារ; និយាយត្រឹមតែ ព្រវារ ប៉ុណ្ណោះក៏មាន :

- មនុស្សព្រវារ។

**ព្រៃខារ** *ន.* ជនជាតិវេស្សៈឬវៃស្សៈ (ក្នុងកម្ពុជប្រទេសមានតែក្នុងរជ្ជកាលអំពីដើម)។

**ព្រៃឈរ** *ន.* ឈ្មោះស្រុកមួយក្នុងខេត្តកំពង់ចាម។

**ព្រៃនគរ** *ន* ឈ្មោះក្រុងជាទីប្រជុំកិច្ចការនៃរដ្ឋការធំនៅក្នុងដែនកម្ពុជាក្រោម។

**ព្រៃអន្ទរ** *ន.* ឈ្មោះព្រៃនៅជិតមាត់បឹងមានច្រើនតំបន់ក្នុងខេត្តក្រៅរបស់ប្រទេសកម្ពុជា, គេហៅបឹងខ្លះថា បឹងព្រៃអន្ទរ។

**ភក្ខាហារ** (សំ.) *ន.* ចំណីអាហារ, អាហារជាចំណី :

❖ ពួកម្រឹគបក្សីចេញស្វែងរកភក្ខាហារ។

**ភណ្ឌាគារ** (បា.) *ន.* ឃ្លាំង, ឃ្លាំងដាក់ទ្រព្យ។

✎ **រាជភណ្ឌាគារ** : ឃ្លាំងដាក់ព្រះរាជទ្រព្យ (ឃ្លាំងហ្លួង)។

✎ **សង្ឃភណ្ឌាគារ** : ឃ្លាំងដាក់របស់សង្ឃ (ឃ្លាំងសង្ឃ) ។

**ភតការ** (បា.) *ន.* អ្នកធ្វើការឈ្នួល, អ្នកស៊ីឈ្នួល, កម្មករ, គូលី :

❖ ពួកភតិការ; បើស្ត្រីជា ភតិការិកា។

*ទេស.* កម្មករ,កម្មការី, ភតិការ, ភតិការី; កម្មការិកា,កម្មការិនី, ភតិការិកា។

**ភត្តការ** (បា.) *ន.* អ្នកធ្វើភត្ត, អ្នកចម្អិនភត្ត, អ្នកគ្រួ, ចុងភៅ។

(រ.ស.) អ្នកពិសេស, ពួកពិសេស, បើស្ត្រីជា ភត្តការិកា ឬ ភត្តការិនី។

**ភត្តាភិហារ** (បា.) *ន.* អ្នកចាត់ចែងភោជន, អ្នករៀបចំភោជនាហារ, អ្នកលើកភត្តបម្រើភ្ញៀវ។

**ភត្តាហារ** (បា.) *ន.* ភោជនាហារ; អាហារទូទៅ។

**ភយង្ករ** (សំ.បា.) *គុ.* ដែលធ្វើឱ្យខ្លាច, ដែលគួរឱ្យខ្លាច, ដែលសម្បើមខ្លាំង :

❖ ទឹកភយង្ករ

❧ **ព្រៃភយង្ករ** : ទីឬព្រៃដែលមានអ្វីមួយធ្វើឱ្យខ្លាច, ដែលគួរខ្លាច។

**ភរ** *កិ.* ពោលពាក្យមិនពិត, កុហក។

*កិ.វិ.* ឬ *គុ.* ដែលមិនពិត, កុហក :

❖ មនុស្សនិយាយភរ។

❧ **ភរភាយ** : ភររបោចរបាតាមតែរួចពីមាត់។

❧ **ភូតភរ** : ភរទាំងស្រុង; ដែលសុទ្ធតែភរ។

**ភស្មការ** (បា.សំ.) *ន.* អ្នកបោកគក់សំពត់, អ្នកបោកគក់គ្រឿងស្លៀកពាក់, អ្នកធ្វើការស៊ីឈ្នួលបោកអ៊ុត; បើស្ត្រីជា ភស្មការិកា។

**ភាណវារ** (បា.) *ន.* វារៈនៃការសូត្រ, ដំណើរសូត្រមួយចប់យ៉ាងវែង គឺប្រវែងធម៌ដែលល្មមសូត្រមួយលើកៗបាន; ឈ្មោះគម្ពីរដែលរួបរួមធម៌ពុទ្ធសាសនាសម្រាប់ពួកបព្វជិតទន្ទេញឱ្យចាំមាត់សូត្រតាមលំដាប់ថ្ងៃ។

**ភារ** *ឧ.* ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ ភស្តុ ថា :

❧ **ភស្តុភារ** : វត្ថុជាអាករ, វត្ថុជាតង្វាយ, វត្ថុជាជំនូន។

❧ **ភស្តុភារបណ្ណាការ** : អាករជាជំនូនផ្សេងៗដែលគេផ្ញើមកជូនឬដែលគេយកមកឱ្យ។

**ភិន្នោទរ** (បា.សំ.) *ន.* បងប្អូនដែលកើតអំពីមាតាផ្សេងគ្នា តែរួមបិតាមួយគឺបងប្អូនឪពុកជាមួយម្ដាយទីទៃ បងភិន្នោទរ, ប្អូនភិន្នោទរ។

**ភូធរ** (បា.សំ.) *ន.* អ្នកទ្រទ្រង់នៅលើផែនដី (ភ្នំ)។ អ្នកទ្រទ្រង់ផែនដី (ព្រះរាជា) :

❖ ព្រះភូធរ។

**ភោជនាគារ** (បា.សំ.) *ន.* ផ្ទះលក់ភោជន។

**ភោជនាហារ** (បា.សំ.) *ន.* អាហារសម្រាប់បរិភោគ។

**ភោជនីយាហារ** (បា.) *ន.* អាហារគួរបរិភោគ, អាហារសម្រាប់បរិភោគ។

**ភ្ជារ** *កិ.* ភ្ជាក់មួយភាំងពីដេកលក់, ភ្ញាក់ស្ដុងស្មារតីដឹងខ្លួនមួយស្របក់តូច :

- ❖ ភ្ជារឡើង
- ❖ ភ្ជារដឹងខ្លួន។

**ភ្ជុំ** *ឧ.* ពាក្យសាមញ្ញសម្រាប់និយាយផ្សំនឹងពាក្យ ភ្ជុំ ថា :

ᨀ **ភ្ជុំភ្ជុរ** : ប្រជុំគ្នាធ្វើបុណ្យនៅទីវត្តអារាមក្នុងថ្ងៃភ្ជុំបិណ្ឌ (ថ្ងៃ១៥រោច ខែភទ្របទ)។

**ភ្ជួរ** *កិ.* ដាក់ស៊កភ្ជាប់ដោយជ័រ, ដាក់ស៊កភ្ជាប់ដោយកាកល័ខជាដើម :

- ❖ ភ្ជ័រកាំបិត។

**ព.ប្រ.** រួមចូលគំនិតមួយដោយប្ដេជ្ញាគ្នាយ៉ាងមាំ :

- ❖ ភ្ជ័រគំនិតគ្នា
- ❖ ភ្ជ័រមេត្រី។

**ភ្ជួរ** *កិ.* រំលើងដីដោយនង្គ័លឱ្យរបើកជាអាចម៍បំណះ :

- ❖ ភ្ជួរស្រែ
- ❖ ភ្ជួរដីចម្ការ។

**ភ្នាក់ងារ** *ន.* បង្អែកការងារ, អ្នកព្រនាក់ការងារគឺអ្នកជាជំនួយការបន្ទាប់អធិបតី, អ្នកកាន់ការរងផ្ទាល់អំពីអធិបតីក្នុងមុខក្រសួងនីមួយៗ :

❖ មន្ត្រីភ្នាក់ងារ

❖ ភ្នាក់ងាររាជការ។

**ភ្នែកគោរ** *ន.* ឆ្អឹងជាអវយវៈនៃមនុស្សមានសណ្ឋានជាពកនៅត្រង់ខាងក្រោមកជើង (ហៅថា ភ្នែកគោល ក៏មាន)។

**ភ្រមរ** (សំ.) *ន.* ភមរជាតិ។ គ្រឿងវិល, គ្រឿងក្រឡឹង។

**មករ** (បា.សំ.) *ន.* ឈ្មោះត្រីសមុទ្រមួយប្រភេទមានខ្លួនធំក្បាលខ្លីក្រមុបធ្មេញនឹងចង្កូមស្វាញគួរស្ញើម (មានតំណាលក្នុងរឿងរ៉ាវពីព្រេងនាយ); ខ្មែរហៅសំដៅត្រីថ្កុរក៏មាន, ច្រើននិយាយថា ឆ្លាមមករ។

*ន.* មករឬមកររាសី គឺឈ្មោះខែទី១០នៃសុរិយគតិ, មាន៣១ថ្ងៃ, ត្រូវគ្នានឹងខែយ៉ាំងវិយេរ (ខែទី១) បារាំង :

❖ ខែមករឬមកររាសី។

☞ សព្វថ្ងៃប្រើជា មករា ជាខែទី១ដែរ។

**មជ្ជារ** (បា.) *ន.* ឆ្មាឈ្មោល។ (ប្រើជា មជ្ជារៈ ឬ មជ្ជារោ ក៏បាន)។

**មជ្ជារី** : ឆ្មាញី, មេឆ្មា។

**មធុរ** (បា.សំ.ភ្ល.; បា.សំ. មធុរ) *គុ.* ផ្អែម, ពីរោះ, ឆ្ងាញ់។

*ន.* រសផ្អែម, រសឆ្ងាញ់; សម្ដីពីរោះ។

**មនសិការ** (បា.) *ន.* ការធ្វើទុកក្នុងចិត្ត, ការកំណត់ទុកក្នុងចិត្ត, ដំណើរយកចិត្តទុកដាក់ :

❖ ធ្វើមនសិការ

❖ មានមនសិការ

❖ រៀនសូត្រដោយមនសិការ។

**មនស្ការ** (សំ.) *ន.* ដំណើរតាំងចិត្ត, ការផ្គងចិត្ត :

❖ ធ្វើមនស្ការ

❖ មានមនស្ការ។

**មនោសារ** (សំ.) *គុ.* ឬ *ន.* ដែលមានធម៌ខ្លឹមក្នុងចិត្ត, ដែលមានចិត្តខ្ជាប់ខ្ជួន, នាមឥសីម្នាក់ជាផៅពង្សនៃព្រះបាទមនុ, ជាអ្នកបង្កើតគម្ពីរឬច្បាប់ធម្មសាស្ត្រមុនដំបូងបំផុតក្នុងខាងដើមនៃ ភទ្ទកប្ប មានជាប់ដរាបមកដល់សព្វថ្ងៃនេះ :

❖ មនោសារជាឥសីគ្រូច្បាប់ធម្មសាស្ត្រ។

**មន្ទារ** (សំ.) *ន.* ឈ្មោះឈើសួគ៌មួយប្រភេទ។ ខ្មែរហៅឈើតូចមួយប្រភេទពួកយីហ៊ុបស្លឹកនិងផ្កាធំជាងយីហ៊ុបផ្កាក្លិនក្រអូបឈ្ងប់។

**មន្ទីរ** (បា.សំ.) *ន.* គ្រឹហា, ផ្ទះ, វិហារ...។

☞ ខ្មែរច្រើនហៅគ្រឹហាធំៗដូចយ៉ាង ធម្មមន្ទីរ, សារមន្ទីរ ជាដើម។

**មមង្ការ ឬ មមំការ** (បា.) *ន.* សេចក្ដីយល់ឬប្រកាន់ថាជារបស់ផងអញគឺសេចក្ដីយល់ឃើញឬប្រកាន់ថា សព៌ាង្គកាយឬអ្វីៗដែលបានមកទាំងប៉ុន្មានសុទ្ធតែជារបស់ផងអញដូចយ៉ាងប្រកាន់ថា "*សក់របស់អញ, ធ្មេញរបស់អញ*"។

**មមៀរ** *ក.* ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ សសៀរ ថា :

✍ **ដើរសសៀរមមៀរ** : ដើរសសៀរសំរៀមៗក្បែរខាង។

**មយូរ** (បា.សំ.) *ន.* ក្ងោក។

  ☙ **មយូរី** : ក្ងោកញី។

  ☙ **មយូរា** : ក្ងោកទាំងឡាយ, ពួកក្ងោក។

  ☙ **មយូរគតិ** : ដំណើរក្ងោក; ដំណើរមានលំនាំស្រដៀងនឹងក្ងោក។

  ☙ **មយូរសព្ទ** : សូរសំឡេងក្ងោក; សូរសព្ទស្រដៀងនឹងសំឡេងក្ងោក។

**មរ** (បា.) *កិ.* ស្លាប់ (សម្រាប់ប្រើចំពោះតែក្នុងកាព្យដែលកវីត្រូវការប្រើខ្លះ កុំឱ្យខ្វះដូចជា) :

❖ ព្រឹកមិញគាត់ត្រាច់ចរល្ងាចគាត់មរឥតដឹងខ្លួននេះ គឺការគាប់ជួន នាំឱ្យខ្លួនមានគ្រោះកាច។

*ន.* ភក់ដែលកើតអំពីទឹកត្រាំដើមត្រុំព្រមទាំងស្លឹកត្រុំស្រស់ផងឱ្យរលួយ ហើយកូរឱ្យខះកកមានសម្បុរខ្មៅខៀវទៅជាផ្លះសម្រាប់ប្រើជាគ្រឿងជ្រលក់ :

❖ គាត់ភ័យស្លុតឡើងមុខខ្មៅប៉ៃដូចជាមរ។

**មរុកន្តារ** (បា.) *ន.* ផ្លូវឆ្ងាយដាច់ស្រយាលប្រកបដោយខ្សាច់, វាលខ្សាច់ល្ហល្ហេវវែងឆ្ងាយគ្មានដើមឈើដុះ, សមុទ្រខ្សាច់។

**មហន្ធការ** (បា.) *ន.* ងងឹតធំ, ងងឹតខ្លាំង។

*គុ.* ដែលមានងងឹតខ្លាំង :

❖ ទីមហន្ធការ។

**មហិន្ទត្ថេរ** (បា.) *ន.* នាមមហាថេរជាព្រះអរហន្តមួយអង្គ ជាព្រះរាជបុត្ររបស់ព្រះបាទ អសោក ឬ ធម្មាសោក, ជាអ្នកនាំព្រះពុទ្ធសាសនាពីមជ្ឈិម

ប្រទេសទៅប្រតិស្ឋានឯលង្កាទ្វីប ក្នុងរាជ្យក្សត្រកោះលង្កាទ្រង់ព្រះនាមព្រះបាទ ទេវានម្បិយតិស្សៈ ក្នុងខាងដើមនៃសតវត្សរ៍ទី៤នៃពុទ្ធសករាជ (ហៅថា មហាមហិន្ទត្ថេរ ក៏បាន)។

**មហោឡារ** (បា.) *គុ.* ដែលធំលើសលែង, ប្រសើរបំផុត, ដែលហ៊ឹកហ៊ាក់ឬ អធិកអធមក្រៃពេក; ដែលអស្ចារ្យខ្លាំង (ប្រើជា មហោឡារិក ក៏បាន) :

- ❖ រៀបក្បួនហែជាមហោឡារ
- ❖ រៀបពិធីធ្វើបុណ្យជាមហោឡារ។

**មាន់នោរ** *ន.* សត្វបក្សីមួយប្រភេទមានជើងវែងចំពុះស្រួចសម្បុរក្រហម នៅអាស្រ័យលើត្រើបឬបឿន។

**មារ** (បា.សំ.) *ន.* ដំណើររារាំង; ការសម្លាប់; សេចក្ដីស្លាប់; ...។ អ្នករារាំង, អ្នកជំទាស់មិនឱ្យអ្នកដទៃធ្វើបុណ្យធ្វើកុសលកើត; ឈ្មោះទេវបុត្រ ដែលជាសត្រូវចំពោះព្រះពុទ្ធ។

- **មារជិ** : អ្នកឈ្នះមារ (ព្រះពុទ្ធ)។
- **មារជិត** : អ្នកឈ្នះមារ (ព្រះពុទ្ធ)។
- **មារជិន** : អ្នកឈ្នះមារ (ព្រះពុទ្ធ)។

**មាលាការ** (បា.សំ.) *ន.* អ្នកក្រងផ្កា, អ្នកលក់ផ្កាកម្រង; បើស្ត្រីជា មាលាការិកា។

**មិគសិរ** (បា.) *ន.* ឈ្មោះខែទី១នៃចន្ទគតិមាន២៩ថ្ងៃ :

- ❖ ខែមិគសិរ។

**មិរ** *គុ.* ច្រើន, តាន់តាប់, កកកុញ, ត្រៀបត្រា; ផេរ :

❖ មនុស្សមីរ

❖ ក្បាលមីរ

❖ មីរដេរដាស។

*ក.១.* ឈរមីរ, កន្ទុំរុយហើរមីរ។

*ខ.* ទូទឹមល្អប់, ងងឹតល្អប់រកកល់ភ្លៀង (ប្រើចំពោះតែមេឃ) :

❖ មេឃមីរ។

**ម្ទូរ** *ក.* ចាប់បង្វិលឱ្យកើតជារបុំ :

❖ មូរកន្ទេល

❖ មូរត្បាញ។

☞ ប្រមូលផ្ទាំងជក់ឱ្យកើតជាបារី :

❖ មូរបារី។

☞ ចាប់សំពត់លាត់ត្រឡប់មុខប្រមូលចូលក្នុងច្រើនស្រទាប់ :

❖ មូរដៃអាវ

❖ មូរជើងខោ។

*ខ.* ឈ្មោះក្តារជាគ្រឿងតម្បាញសម្រាប់មូរអន្ទង :

❖ ក្តារមូរ។

**ម្ទូរ** *ខ.* ស្រូវដែលដុះពីគ្រាប់ជ្រុះក្នុងស្រែតាំងពីខែចម្រូត :

❖ ស្រូវម្ទូរ

❖ ដកម្ទូរស្ទូងត្រពាំង។

**ម្ជូរ** *ន.* វត្ថុដែលមានរសជូរ, ស្លឹកឬផ្លែសម្រាប់ប្រើជាគ្រឿងជូរ :

❖ ម្ជូរអម្ពិល

❖ ម្ជូរក្រូចឆ្មារ

❖ ម្ជូរសណ្តាន់...។

☞ ឈ្មោះសម្លដែលបង់ម្ជូរ :

❖ សម្លម្ជូរ។

**យ៉័រ** *ឧ.* សម្តីបន្លឺឡើងដោយសើច, សម្តីបន្លឺឡើងដោយប្លែកចិត្ត :

✍ **យ៉័រ**! : អីដល់ម្ល៉ឹងម៉ឹងហ្ន៎! (ប្រើតាមទម្លាប់, ដូចគ្នានឹង យី!, យើ!, យីអើ!, ដែរ)។

**យារ** *គុ.* ដែលស្តួយ, ដែលស្រុងចុះ, ដែលយុលចុះ, ដែលសំយាកចុះ; ដែលជ្រុលចុះក្រោម :

❖ ក្បិនយារ

❖ សង្រែកយារ។

*កិ.* ងាដាប :

❖ យារដៃនឹងទះ

❖ យារជើងនឹងធាក់។

*ន.* ឈ្មោះសេកមួយប្រភេទមាឌស្រដៀងនឹងសេកសោមតែមានចំពុះខ្មៅ :

❖ សេកយារ។

**យុគន្ធរ** (បា.សំ.) *ន.* ប្រដាប់ទ្រទ្រង់នូវគូ (ទូករទេះ; ចន្ទាសរថ; ដងរ៉ែក)។ ភ្នំដែលទ្រទ្រង់នូវគូនៃព្រះអាទិត្យនិងព្រះចន្ទ (ឈ្មោះភ្នំមួយនៅក្នុងពួកភ្នំសត្តបរិភណ្ឌ) :

❖ ភ្នំយុគន្ធរ។

**យុរ** *កិ.* ឬ *គុ.* យុល, ទន់ដាបស្តុបចុះ, សំយាកដាបចុះ :

❖ មែកឈើយុរគ្របផ្លូវ។

➣ **យុរយារ** *គុ.* ដែលយុររយីករយាក :

❖ ចាស់ជរាសាច់ស្បែកឡើងយុរយារ។

**យូរ** *កិ.វិ.* ឬ *គុ.* ដែលមិនឆាប់, យឺត, អង្វែង :

❖ កាលយូរ

❖ យប់យូរ

❖ យូរណាស់។

**យ៉ើរ** ឬ **យ៉ើល** *កិ.វិ.* ដែលឆក់ឬទាញកន្ត្រាក់ឡើងខ្ពស់ត្រដែត :

❖ ឆក់យ៉ើរ

❖ កន្ត្រាក់យ៉ើរ (និយាយថា យ៉ឺរ ឬ យ៉ឺល ក៏មានតាមទម្លាប់ប្រើ)។

**យោគាវចរ** (បា.) *ន.* អ្នកតាំងចិត្តឱ្យចុះស៊ប់ក្នុងការភាវនា, អ្នកចម្រើនកម្មដ្ឋាន។

**រងោរ** *កិ.វិ.* ដែលផ្អើលជ្រួលឆោឡោជ្រួលច្របល់ដូចទឹកជោរ។

**រដ្ឋបការ** (ធា.) *ន.* ការគ្រប់គ្រងរាជ្យ, ការទំនុកបម្រុងផែនដី។ ប្រើសំដៅសេចក្ដីថា "ប្រាក់សម្រាប់ទំនុកបម្រុងផែនដី" ក៏មាន។

**រណារ** *ន.* បន្ទះដែកសំប៉ែតស្ដើងមានធ្មេញមានគ្រឿងភ្ជាប់សម្រាប់កាន់ជាប្រដាប់សម្រាប់អារឈើជាដើមមានច្រើនប្រភេទ :

- ❖ រណារយក្ស
- ❖ រណារច្រៀក
- ❖ រណារកន្ទុយត្រី។

**របរ** *ន.* អម្រស់; អម្រស់ដែលរកបានដោយកម្លាំងកាយ :

- ❖ របរពោត
- ❖ របរសណ្ដែក
- ❖ របរចិញ្ចឹមគោ។

**របារ** *ន.* មេដែកគាបរបង, ជញ្ជាំង, ថែប ជាដើម :

- ❖ របាររបង
- ❖ របារជញ្ជាំង។

**រប៉ើរ** *ន.* អាហារនៅក្នុងក្រពះនៃបុគ្គលទើបធ្វើមរណកាលមិនទាន់យូរប៉ុន្មានដែលដល់ពេលកំណត់ ក៏រើផ្សាយក្លិនស្អុយជូរចេញមកតាមមុខទ្វារធំឆ្លូលភាយៗម្ដងៗ :

- ❖ រើរប៉ើរ
- ❖ ធុំរប៉ើរ។

☞ ខណៈប្រមាណប្រហែលមួយវេលារើរបើរនៃរូបបុគ្គលស្លាប់ :

❖ និយាយគ្នាប្រហែលមួយរបើរ។

**របែររបោរ** *គុ.* ដែលបោររៀចរមួល :

❖ ក្តាររបែររបោរ។

ព.ប្រ. ដែលបោររៀចរេរ, ដែលរបិញរបុញក្រៃពេក :

❖ គំនិតរបែររបោរ។

**របេះរបោរ** *គុ.* ដែលបះបោរក្រៃពេក, ដែលចេះតែបះបោររឿយៗ :

❖ ស្រុករបះរបោរ។

**រមូរ** *ន.* សំណុំដែលមូររួចហើយ, សំណុំដែលប្រមូល, រប៉ុ :

❖ រមូរសំពត់

❖ សំពត់មួយរមូរ

❖ កន្ទេលមួយរមូរ។

**រលរ** *គុ.* ដែលសើមរលើប, គគុល :

❖ ដីសើមរលរ

❖ សើមមាត់រលរ។

**រលាប្អៀរ** *ន.* ឈ្មោះស្រុកមួយក្នុងខេត្តកំពង់ឆ្នាំង :

❖ អភិបាលស្រុករលាប្អៀរ។

**រហៀរ** *គុ.* ដែលក្រីក្រលំបាកតោកយ៉ាកក្រៃពេក :

❖ ក្ររហៀរ

❖ មនុស្សរហៀរ។

**រាមសូរ** *ន.* ឈ្មោះយក្សម្នាក់ក្នុងរឿងបុរាណ។

**រុករ** *ន.* ឈ្មោះវល្លិរីងមួយប្រភេទ សំបកខាងក្រៅលឿងចាស់ សំបកខាងក្នុងនិងសាច់លឿងខ្ចី មានរសហឹររមាស់ឆៀបៗប្រើជាថ្នាំកម្ចាត់រោគ :

❖ វល្លិរុករ។

**រុចិរ** (បា.សំ.) *គុ.* រុងរឿង; ល្អ, សមរម្យ; ជាទីពេញចិត្ត; ពីរោះ។

✍ **រុចិរបុស្ប** ឬ **រុចិរបុប្ផ** : ផ្កាដែលមានពណ៌រុងរឿង។

✍ **រុចិរពណ៌** ឬ **រុចិរវណ្ណ** : ពណ៌, សម្បុរដ៏រុងរឿង។

✍ **រុចិរភាសា** ឬ **រុចិរវាចា** : សម្ដីពីរោះ។

✍ **រុចិរសព្ទ** : សូរពីរោះ, សំឡេងពីរោះ។

**រំហូរ** *ន.* ការហូរ :

✍ **រំហូរទឹក** : ការហូរនៃទឹក។

**លិបិការ** (បា.សំ.) *ន.* អ្នកធ្វើអក្សរ គឺស្មៀន, ស្មេរ; ជាងឆ្លាក់អក្សរ; បើស្ត្រីជា លិបិការិកា។

✍ **លិបិការកម្ម** : មុខការរបស់ស្មៀន។

✍ **លិបិការកិច្ច** : ការរវល់របស់ស្មៀន។

✍ **លិបិការដ្ឋាន** : ទីធ្វើការរបស់ស្មៀន, កន្លែងស្មៀន។

**លោមសារ** (សំ.) *ន.* កែវមរកត, ត្បូងមរកត :

❖ ត្បូងលោមសារ។

**វញ្ចនាការ** (បា.) *ន.* អាការៈបញ្ឆោត; អាការៈបោក, អាការៈបោកប្រាស់ :

❖ ធ្វើកលល្បិចដោយវញ្ចនាការ។

**វនេចរ** (បា.សំ.) *ន.* អ្នកត្រាច់ទៅក្នុងព្រៃ (ព្រានព្រៃ)។

**ពាក្យកាព្យ**

គ្រានោះវនេចរ មានអំណរពន់ពេកក្រៃ

រិះរកឧបាយថ្មៃ បាញ់ដំរីឱ្យបានងាយ។

**វរ** *កិ.* ទាស់ការ, ទាស់ទំនង; នាំឱ្យមានរវល់ឥតប្រយោជន៍; នាំឱ្យទាស់ដំណើរ។

✍ ***កុំវរ!*** : កុំរវល់!។

✍ ***នាំវរ*** : នាំរវល់។

✍ ***វរហើយ!*** : ទាស់ហើយ!។

✍ ***វឹកវរ*** : ច្របូកច្របល់; ធ្វើឱ្យច្រឡំបល់, ធ្វើឱ្យទាស់ការ។

☞ (**បា.សំ.**) *គុ.* ប្រសើរ, ខ្ពង់ខ្ពស់, លើសលន់, ថ្លៃថ្លា; ជាចម្បង; ដែលគួរប្រាថ្នា, ដែលគួរចង់បាន, ដែលគួរជ្រើសយក, ដែលគួរសូម, ...។

✍ ***វរគុណ*** : គុណដ៏ប្រសើរ, គុណគាប់។

✍ ***វរចក្រ*** : ចក្រដ៏ប្រសើរ។

✍ ***វរជន*** : ជនប្រសើរ។

✍ ***វរជ័យ*** : ជម្នះដ៏ប្រសើរ។

✍ ***វរញ្ញូ*** : អ្នកដឹងធម៌ដ៏ប្រសើរ (ព្រះពុទ្ធ)។

✍ **វរទាន** : ការឱ្យទាន; ការឱ្យរង្វាន់។

✍ **វរនាថ** : ពំនាក់ដ៏ប្រសើរ។

✍ **វរបិតា** : បិតាដ៏ប្រសើរ។

✍ **វរបុរស** : បុរសប្រសើរ, ប្រុសថ្លៃ។

✍ **វរមន្ត្រី** : មន្ត្រីប្រសើរ។

✍ **វរមាតា** : មាតាប្រសើរ។

✍ **វរមិត្ត** : មិត្តប្រសើរ។

✍ **វររាជ** : ស្ដេចប្រសើរ។

✍ **វរវង្ស** : វង្សដ៏ប្រសើរ; ដែលមានវង្សខ្ពង់ខ្ពស់។

**វរូថ** (សំ.) *ន.* គ្រឿងរាំងកូនសរ, គ្រឿងរាំងព្រួញ; អាវក្រោះសម្រាប់ការពារសស្ត្រាវុធ។

**វាមលូរ** (សំ.) *ន.* ដំបូក។

## ពាក្យកាព្យ

| | | |
|---|---|---|
| វីវាមលូរ | កើតមាននៅយូរ | សឹងមានប្រយោជន៍ |
| យកដីធ្វើជី | ដំណាំដំណោច | មានផលមិនហោច |

ចម្រើនធនធាន។

**វាសរ** (សំ.) *ន.* ថ្ងៃ, វេលាថ្ងៃ។

✍ **វាសរសង្គៈ** : អរុណោទ័យ, វេលាព្រះអាទិត្យរះ។

**វាសាគារ** (បា.សំ.) *ន.* ល្វែងសម្រាប់នៅ, បន្ទប់សម្រាប់នៅ; បន្ទប់ដេក។

**វិការ** (សំ.) *ន.* រោគ, ជំងឺ។

**វិការ** (បា.សំ.) *ន.* ការធ្វើប្លែកចាកប្រក្រតីដើម; ការផ្លាស់ប្រែ; ការផ្លាស់រូប, ការផ្លាស់ទំនង; ការប្រែប្រួលចាកភាពប្រក្រតី, ការប្រែប្រួលខុសធម្មតា; ដំណើរពិការ; រោគ។

**វិឃាសាហារ** (បា.សំ.) *ន.* អាហារដែលសេសសល់ពីគេ, អាហារដែល :

❖ រស់ដោយវិឃាសាហារ។

**វិចារ** (បា.សំ.) *ន.* ការពិចារណា; ការត្រួតត្រា; ការដើរចរច្រប់។ សេចក្ដីរំពឹងពិចារណាអារម្មណ៍ដែលកំពុងភាវនា។

**វិចារបញ្ញា** : ប្រាជ្ញាដែលផុលផុសឡើងព្រោះការពិចារណា; ប្រាជ្ញាសម្រាប់ពិចារណា។

**វិជិតមារ** (បា.សំ.) *ន.* លោកអ្នកឈ្នះមារ, វិជិតមារ (ព្រះសម្មាសម្ពុទ្ធ) :

❖ ព្រះវិជិតមារ (ព្រះឈ្នះមារ)។

**វិត្ថារ** (បា.) *គុ.* ទូលាយ; រលុង; វែងឆ្ងាយ។

**វិត្ថារកថា** : ពាក្យពិស្ដារ។

**វិត្ថារន័យ** : ន័យពិស្ដារ។

**វិត្ថារវាទ** : ពំនោលពិស្ដារ។

**វិធុរ** (បា.សំ.) *ន.* សេចក្ដីលំបាក, សេចក្ដីទុក្ខម្នេញ; ការព្រាត់ប្រាស, ការបែកចិត្តពីគ្នា។

☞ នាមអ្នកប្រាជ្ញម្នាក់ (អង្គពោធិសត្វ) មានតំណាលក្នុង **វិធុរជាតក** :

❖ សាស្ត្រាព្រះវិធុរ

❖ រឿងព្រះវិធុរ (ហៅថា វិធុរបណ្ឌិត ក៏បាន)។

**វនិការ** (សំ.) *ន.* សេចក្ដីមើលងាយគេ; ការធ្វើទុក្ខបុកម្នេញគេ; ដំណើរប្រកាន់ទោស, ការចាប់ទោសកំហុសគេ :

❖ ធ្វើវិនិការ។

**វប្បការ** (បា.) *ន.* សេចក្ដីមើលងាយ, ការមាក់ងាយ មាក់ថោក; ការធ្វើឱ្យគេប្រទះអន្តរាយ, ការធ្វើឱ្យគេបានសេចក្ដីទុក្ខពិបាក; សេចក្ដីព្យាបាទ; ការធ្វើអាក្រក់ទៅរក; អំពើអាក្រក់ :

❖ ធ្វើវិប្បការ

❖ មានវិប្បការ។

**វប្រការ** (សំ.) *ន.* សេចក្ដីមើលងាយ, ការមាក់ងាយ មាក់ថោក; ការធ្វើឱ្យគេប្រទះអន្តរាយ, ការធ្វើឱ្យគេបានសេចក្ដីទុក្ខពិបាក; សេចក្ដីព្យាបាទ; ការធ្វើអាក្រក់ទៅរក; អំពើអាក្រក់ :

❖ ធ្វើវិប្រការ

❖ មានវិប្រការ។

**វប្រតិការ** (សំ.) *ន.* ការជជែកតវ៉ា, ការនិយាយតទល់, ការតបត; ដំណើរតទល់ :

❖ ធ្វើវិប្រតិការ។

**ទិវាករ** (បា.សំ.) *ន.* អ្នកធ្វើនូវពន្លឺ (ព្រះអាទិត្យ)។

**វិស្វករ** (សំ.ស.) *ន.* អ្នកធ្វើការទូទៅ។

☞ ប្រើដោយសន្មតិសំដៅសេចក្តីចំពោះ "អធិបតីអ្នកសម្រេចការហត្ថកម្មទូទៅនិងការបច្ចេកទេសផ្សេងៗមានការសង់ផ្ទះ, សង់ស្ពាន, លើកថ្នល់, ធ្វើផ្លូវជាដើម សម្រាប់រាជការគ្រប់ប្រទេស" :

❖ ទីវិស្វករ

❖ សញ្ញាបត្រវិស្វករ

❖ វិស្វករក្រសួងសាធារណការ...។

**វិហារ** (បា.សំ.) *ន.* ការនៅ, ការនៅអាស្រ័យ។ លំនៅ, កុដិធំ, ទីវត្ត (ទាំងមូល) សម្រាប់ពួកបព្វជិតពុទ្ធសាសនិក។ ខ្មែរហៅតាមទម្លាប់ចំពោះតែឧបោសថាគារ (រោងឧបោសថ) ថា "**វិហារ**" :

❖ សង់វិហារ

❖ បុណ្យឆ្លងវិហារ។

✍ **វិហារកម្ម** : ការសាងវត្ត; ការធ្វើវិហារ។

✍ **វិហារបាល** : អ្នករក្សាទីវត្ត, អ្នកថែវត្ត។

✍ **វិហារបាលិនី** : ស្ត្រីអ្នកថែទីវត្ត; ដូនជី, យាយជី។

✍ **វិហារភណ្ឌ** : របស់សម្រាប់កុដិធំ; របស់សម្រាប់វត្ត, ទ្រព្យវត្ត។

✍ **វិហារវត្ថុ** : អ្វីៗដែលមានក្នុងទីវត្តមានដើមឈើ, ដំណាំជាដើម។

**វីរ** (បា.សំ.) *គុ.* ដែលខ្ជាប់ខ្ជួន, មាំមួន, រឹងប៉ឹង, អង់អាច, ក្លាហាន, ក្លៀវក្លា, មោះមុត, ខ្លាំងពូកែ; ដែលមានព្យាយាមខ្ជាប់ខ្ជួន។

*ន.* អ្នកអង់អាច, អ្នកក្លៀវក្លា; អ្នកចម្បាំង; អ្នកប្រាជ្ញ។

- **វីរជន** : ជនអង់អាច; ...។
- **វីរបុរស** : បុរសអង់អាច; ...។
- **វីរភ័ជ** : អមាត្យអង់អាច; មេទ័ព។
- **វីរភាព** : ភាពដែលអង់អាច, ដំណើរអង់អាច។
- **វីរសេនា** : សេនាមោះមុត, សេនាខ្លាំងពូកែ...។

**វីវរ** *កិ.* ឬ *កិ.វិ.* ធ្វើឱ្យទាស់ការ, ធ្វើឱ្យទាស់ដំណើរ, ធ្វើឱ្យទាស់ទំនង; ដែលនាំឱ្យវីវក់, ដែលនាំឱ្យវរវីក, ដែលនាំឱ្យច្របូកច្របល់ :

- ❖ កុំវីវរអី!
- ❖ ធ្វើវីវរខូចអស់!។

**វីកវរ** *កិ.* ឬ *កិ.វិ.* ធ្វើឱ្យច្រលំបល់, ធ្វើឱ្យទាស់ការ; ដែលធ្វើច្របូកច្របល់ :

- ❖ នាំវឹកវរ
- ❖ ធ្វើវឹកវរ។

**វេគសរ** (សំ.) *ន.* សេះ, លា។

**វេរ** *កិ.* ប្រគល់ឬប្រគេនអ្វីៗឱ្យដោយបញ្ចេញវាចាថាតាមគ្នា :

- ❖ វេរភត្ត
- ❖ វេរកុដិ

❖ វេរសាលាប្រគេនជំនុំសង្ឃ។

*កិ.* ងាកបែរទ្រេត, ងាកបែរបញ្ឆៀង, ងាកបែររេ :

❖ សសរវេរ

❖ ដើមឫស្សីត្រូវខ្យល់ខ្លាំងវេរមកលើផ្លូវ។

*ន.* ដំណើរយកវេនគ្នា, ដំណើរធ្វើការឱ្យគ្នាទៅវិញទៅមក :

❖ យកវេរ

❖ ជំពាក់វេរគេ

❖ សងវេរគេ (និយាយតាមទម្លាប់ដោយស្រុក, អ្នកស្រុកខ្លះនិយាយថា យកដៃ, ជំពាក់ដៃគេ, សងដៃគេ)។

**វេរប្បដិវេរ** (បា.) *ន.* ដំណើរចងពៀរតបពៀរ, ការចងពៀរម្ដងម្នាក់គឺ ការដែលអ្នកមួយចងពៀរទៅរកហើយអ្នកមួយត្រឡប់ចងពៀរមករកវិញ :

❖ វេរប្បដិវេរជាអំពើនាំឱ្យបានសេចក្ដីទុក្ខវិនាសម្ដងម្នាក់មួយមុនមួយ ក្រោយ...។

**វេស្សន្តរ** (បា.) *ន.* ចន្លោះ; រវាងពាក់កណ្ដាល; រវាងឬទីពាក់កណ្ដាលផ្លូវ ពួកវេស្សៈ។ ព្រះនាមពោធិសត្វក្នុងមហាវេស្សន្តរជាតក (បានជាថ្វាយព្រះ នាមដូច្នេះព្រោះទ្រង់ប្រសូតក្នុងពាក់កណ្ដាលទីប្រជុំផ្លូវពួកវេស្សៈ)។

**វោការ** (បា.សំ.ក្ល.) *ន.* ចំណែកនៃរាងកាយ, ខន្ធ :

✍ **បញ្ចវោការ** : ខន្ធប្រាំ។

*ន.* លាមក, អាក្រក់, ថយថោក។

**វោហារ**(បា.) *ន.* ពាក្យ, ពាក្យពេចន៍; សំនួនសម្ដី :

❖ បានវោហារ

❖ បញ្ចេញវោហារ។

**វោហារកោសល** : អ្នកឈ្លាសវៃខាងវោហារ, អ្នកប៉ិនប្រសប់ខាងវោហារ, អ្នកប៉ិនប្រសប់ខាងពាក្យសម្ដីថ្វីមាត់។

**វោហារកោសល្យ** : ការឈ្លាសវៃ, ការប៉ិនប្រសប់ស្ទាត់ជំនាញក្នុងវោហារ, ការចេះនិយាយថ្លែងសេចក្ដីយ៉ាងពីរោះឥតមានរអាក់រអួល។

❖ វោហារកោសល្យជាឧបនិស្ស័យមានប្រចាំក្នុងសន្ដានរបស់បុគ្គលខ្លះ។

**វោហារទេសនា** : ការសម្ដែងវោហារ, ការសម្ដែងធម៌អធិប្បាយបញ្ចេញវោហារឱ្យទូលាយងាយស្ដាប់ងាយយល់។

*ន.* ទំនៀម, ទំនៀមទម្លាប់; ធម្មសាស្ត្រ, ច្បាប់បញ្ញត្តិ; វិវាទ, ក្ដី; ការលក់ដូរ, ជំនួញ។

**វោហារវិធី** : វោហារកម្ម, ដំណើរក្ដី។

**វោហារវិជ្ជា** : វិជ្ជាឬសាស្ត្រខាងច្បាប់សម្រាប់ប្រទេស, ធម្មសាស្ត្រ។

**សង្ករ** (បា.សំ.) *ន.* ការច្របូកច្របល់, ការច្រឡូកច្រឡំ, ការច្រលំបល់; ដំណើរសាន់វ៉ាន់; សេចក្ដីខ្វល់ខ្វាំង។

**សង្ករភាព** : ភាវៈច្របូកច្របល់, ...។

**សង្ករការណ៍** : ហេតុឬដំណើរដែលនាំឱ្យច្របូកច្របល់, ...។

**សង្ខារ** *ន.* សង្ខារ;...។ ខ្មែរប្រើសំដៅសេចក្ដីថា "*ការលើកសពធ្វើឈាបនកិច្ច, ការគាស់ខ្មោចដុត, ការលើកខ្មោចស្រោចឆ្អឹង*" និយាយបានតែជាមួយនឹងពាក្យថា "*លើកសព*" :

❖ លើកសពសង្ការ (លើកសពសង្ខារ); បើឱ្យត្រឹមត្រូវគួរនិយាយថា លើកសពសំស្ការ។

*ន.* សំរាម។

✍ **សង្ការកូដ** : គំនរសំរាម, ពំនូកសំរាម។

✍ **សង្ការច្ឆឌ្ទក** : អ្នកចាក់សំរាម, អ្នកស៊ីឈ្នួលចាក់សំរាម។

✍ **សង្ការដ្ឋាន** : កន្លែងចាក់សំរាម។

**សង្កៀរ** *កិ.* ឬ *គុ.* រអាខ្លាំងឬរអាមខ្លាំង :

❖ សង្កៀរសាច់

❖ សង្កៀរជើងធ្មេញ។

✍ **សង្កៀរចិត្ត** : រអាចិត្ត, ជ្រេញចិត្ត, ទ្រាន់ចិត្តខ្លាំង។

✍ **សង្កៀរត្រចៀក** : រអាមឬខ្ញ័រត្រចៀកគឺឮសូរសព្ទខ្លាំងជិតត្រចៀកឬឮសម្ដីពុំគួរគាប់នាំឱ្យខ្ញ័រឬរអាមស្រោតប្រសាទ។

**សង្ខារ** (ឆា.) *ន.* ការតាក់តែង, គ្រឿងប្រកប, គ្រឿងតាក់តែង; គ្រឿងប្រុង; ភ្ជុំ, ការប្រមូលផ្សំ; សព៌ាង្គកាយ; ជីវិត; គំនិត; អ្វីៗទាំងពួងក្នុងលោក; ...។

✍ **សង្ខារក្ខន្ធ** : គំនរឬកងនៃគំនិត (រាប់ជាខន្ធទី៤ក្នុងខន្ធទាំង៥)។

📎 **សង្ខារទុក្ខ** : សេចក្ដីព្រួយលំបាករបស់ជីវិតឬព្រោះជីវិត។

📎 **សង្ខារធម៌** : ធម៌សង្ខារឬសង្ខារដែលរាប់ថាធម្មតា។

📎 **សង្ខារនិរោធ** : ដំណើររលត់សង្ខារ, ដំណើរលែងមានសង្ខារតទៅ។

📎 **សង្ខារបច្ច័យ** : ធម៌ជាបច្ច័យឱ្យកើតវិញ្ញាណ។

📎 **សង្ខារុបេក្ខា** : ដំណើរដើយព្រងើយចំពោះអ្វីៗទាំងពួង។

**សង្ក័រ** *ន.* ឈើតូចមួយប្រភេទមានបន្លាខុបៗផ្លែតូចៗវេលាទុំឡើងសម្បុរក្រមៅមានរសជូរអែមបរិភោគបាន :

❖ ផ្លែសង្ក័រទុំគេអាចទុកបានយូរថ្ងៃ។

**សង្វរ (បា.សំ.ក្ល.)** *ន.* ការសង្រួម :

❖ មានសង្វរ។

**សង្វារ (ស.)** *ន.* ខ្សែវិចិត្រមួយបែបសម្រាប់ពាក់ឆៀង ប្រើជាគ្រឿងប្រដាប់កាយ :

❖ ពាក់សង្វារ។

**សង្សារ (បា.សំ. សំសារ)** *ន.* ដំណើរអន្ទោលទៅមក, ដំណើរអន្ទោលកើតស្លាប់មិនឈប់មិនស្រាក :

❖ សង្សាររបស់ពួកពាលវែងឆ្ងាយឥតអ្វីប្រៀប។

☞ ខ្មែរប្រើសំដៅសេចក្ដីថា "ស្ត្រីជាគូកម្សត់; ស្ត្រីជាសហាយស្មន់" ក៏មាន :

❖ ស្រីនុ៎ះជាសង្សាររបស់គេ។

🙠 **សង្សារចក្រ** : ដំណើរអន្ទោលកើតស្លាប់ៗកើតវិញដូចជាកង់។

🙠 **សង្សារទុក្ខ** : ទុក្ខក្នុងសង្សារ, ទុក្ខព្រោះដំណើរអន្ទោលកើតស្លាប់។

🙠 **សង្សារភព** : ភពសម្រាប់អន្ទោលកើតស្លាប់។

🙠 **សង្សារភ័យ** : ភ័យអំពីដំណើរអន្ទោលកើតស្លាប់។

🙠 **សង្សារវដ្ត** : ដំណើរវិលកើតវិលស្លាប់។

**សង្ហរ (បា.សំ. សំហរ)** *កិ.* នាំ, ដឹកនាំ; បណ្ដាល, បណ្ដាលឱ្យឃើញឬឱ្យយល់, បញ្ចូលចិត្ត, នាំចិត្ត :

❖ ទេវតាសង្ហរឱ្យយល់។

**សង្ហារ (បា.សំ. សំហារ)** *ន.* ការនាំយក; ការបំប្រួញ, សង្ខេប; ការរួបរួម; ការទម្លាយបង់; ការបំផ្លាញ, ការបំបាត់បង់, ការផ្ដាច់ផ្ដិល។

*កិ.* សំដៅសេចក្ដីថា "បំផ្លាញ, បំបាត់បង់, ផ្ដាច់ផ្ដិល, សម្លាប់" :

🙠 **សង្ហារជីវិត** : ផ្ដាច់ផ្ដិលជីវិត។

(**រ.ស.**) *ន.* ត្រាសម្រាប់ក្សត្រ, ត្រាផែនដី, ព្រះលញ្ឆករ :

❖ បោះព្រះសង្ហារ។

**សន្ទរ** *ន.* សុខុមសត្វ ពួកស្រមោច, សម្បុរខ្មៅមានទ្រនិចនៅត្រង់គូទ, ទិចឈឺក្ដៅពើត, ចេះរូងដីធ្វើជារន្ធនៅដោយពួកៗ។

**សញ្ចារ (បា.សំ.)** *ន.* ការត្រាច់ចរ, ការត្រាច់ទៅមក; ផ្លូវចង្អៀត; ច្រករហក។

*កិ.* ដើរត្រាច់ចរ, ដើរប្ដើកចុះប្ដើកឡើង; ដើរស្វែងរកប្រយោជន៍ស្ងាត់ៗ (របស់ស្រីពេស្យាជាដើម) :

➣ **សញ្ចរដ្ឋាន** : ទីសញ្ចរ។

➣ **សញ្ចររោគ** : រោគដែលកើតដោយឆ្លងអំពីស្រីអ្នកសញ្ចរ។

**សញ្ចារ (បា.សំ.)** *ន.* ការត្រាច់ចរទៅមក; ការដើរលេងមិនមានកំណត់ទី :

❖ ធ្វើសញ្ចារមួយថ្ងៃទាល់ល្ងាច។

**សណ្ឋាគារ (បា.)** *ន.* ផ្ទះឬរោងសម្រាប់ទទួលភ្ញៀវ, ផ្ទះរាជការសម្រាប់ទទួលភ្ញៀវមកពីចម្ងាយឬមកពីនានាប្រទេស; សាលារៀនយុទ្ធសាស្ត្រ :

❖ សណ្ឋាគារសម្រាប់ក្រុង (សរសេរជា សន្ថាគារ ក៏មាន; ហៅសណ្ឋាគារដ្ឋាន)។

**សន្ធរ (បា.សំ.)** *គុ.* ដែលចងចាំដោយប្រពៃ។ ខ្មែរច្រើនប្រើជាបានន្តរសម្រាប់មន្ត្រីថ្នាក់ស្មៀនជាដើម :

❖ សន្ធររោហារ

❖ សន្ធរមេធា។

**សមន្ធការ (បា.សំ.)** *ន.* ភាពឬសភាពដែលធ្វើឱ្យងងឹតសូន្យដូចជាខ្វាក់, ដំណើរងងឹតសូន្យឈឹង :

❖ នៅក្នុងសមន្ធការ។

**ពាក្យកាព្យ**

សមន្ធការ ជាអន្ធពាល ប្រដូចនឹងខ្វាក់

ងងឹតសូន្យសុង រិងស៊ុងទើសទាក់ លុះតែមានអ្នក

នាំផ្លូវទើបកើត។

**សមភិហារ** (បា.សំ.) *ន.* ដំណើរផ្ទួន, ដំណើរច្រំដែល; ការធ្វើអ្វីផ្ទួនៗ; ការនិយាយដដែលៗ។

✍ **សមភិហារកិច្ច** : កិច្ចការដែលត្រូវធ្វើដដែលៗ។

✍ **សមភិហារភាព** : ភាពនៃការដដែលៗ, ដំណើរនៃការច្រំដែល។

**សមរ** (បា.សំ.) *ន.* សង្គ្រាម, ទ័ព។

✍ **សមរកម្ម** : ការច្បាំងគ្នា។

✍ **សមរប្រកាសន៍** : ការប្រកាសសង្គ្រាម។

✍ **សមរភូមិ** : ទីបោះទ័ព, ទីចម្បាំង។

✍ **សមរភូមិជ័យ** : ទីចម្បាំងមានជ័យ, ទីច្បាំងឈ្នះបច្ចាមិត្ត។

(បា.សំ.) *ន.* ការរលឹក, ការចងចាំ, ដំណើរនឹកឃើញមិនចេះភ្លេច; សេចក្ដីស្រលាញ់អស់ពីចិត្ត។

*គុ.* ជាទីស្រលាញ់ជាប់ចិត្ត; ដែលស៊ូស្លាប់ស៊ូរស់ជាមួយ (ប្រើក្នុងពាក្យកាព្យចំពោះតែទៅលើស្ត្រី) :

- សមរថ្ងៃ
- សមរមិត្ត
- មាសសមរ...។

## ពាក្យកាព្យ

ហៃកែវសមរមិត្ត ចូរកុំគិតពីក្ដីក្រ
ព្រោះយើងប្រព្រឹត្តល្អ តំណាសុខមុខតែមាន។

**សមាចារ** (បា.សំ.) *ន.* មារយាទល្អ, មារយាទត្រឹមត្រូវ, មារយាទរៀបរយ; មារយាទមាន៣យ៉ាង :

១- កាយសមាចារ

២- វចីសមាចារ

៣- មនោសមាចារ។

**សមុទាចារ** (បា.សំ.) *ន.* សេចក្ដីតាំងចិត្ត; ហេតុ, ការណ៍; ការស្រែកហៅ; ការពោលអួត។

🙞 **សមុទាចារសព្ទ** : សូរស្រែកហៅ។

**សមោសរ** (បា.) *ន.* ទីប្រជុំ :

❖ ក្នុងសមោសរ។

*កិ.* ប្រជុំ, ភ្ជុំគ្នា, ជួបជុំ :

❖ មកសមោសរក្នុងទីមួយ។

**សម្នារ** *កិ.* ឬ *កិ.វិ.* ដែលស្រែកលឺខ្ទរខ្ទារ, ស្រែកខ្លាំង :

❖ ដំរីសម្នារកោញ្ចនាទ

❖ ស្រែកសម្នារពេញសំឡេង។

**សម្បហារ** (បា.) *ន.* ការតយុទ្ធគ្នា, ការចូលប្រលូកកាប់សម្លាប់គ្នា; សង្គ្រាម :

🙞 **ស្រុកកើតសម្បហារ** : ស្រុកកើតចម្បាំង។

🙞 **សម្បហារភូមិ** : សមរភូមិ...។

**សម្បុរ** *ន.* ពណ៌ (សម្រាប់ប្រើចំពោះមនុស្សនិងសត្វនិករទាំងពួង) :

❖ ខ្ញុំដើរអម្បាញ់មិញ ប្រទះមនុស្សកំលោះម្នាក់រាងស្ដើងសម្បុរសណ្ដែកបាយដឹកគោកម្រៀវមួយសម្បុរត្នោត (កុំនិយាយថាមនុស្សពណ៌សណ្ដែកបាយ, គោពណ៌ត្នោតឡើយ, ...)។

**សម្បូរ** (បា.សំ.) *កិ.* ឬ *គុ.* គ្រប់ព្រម; ពេញ, ពាសពេញ; បរិបូរក្រៃពេក :

❖ ស្រុកសម្បូរ

❖ ទឹកភ្លៀងសម្បូរ។

🙞 **សម្បូរហូរហៀរ** : សម្បូរគរគោក។

🙞 **សម្បូរពោរពាស** : សម្បូរសល់ផល...។

**សម្បួរ** ឬ **សំបួរ** *ន.* ឈ្មោះឈើមួយពួកមាន៣ប្រភេទ :

១- **សម្បួរកក់** : សម្បួរដើមស្មើរជាវល្លិមានបន្លាផ្លែមានរសជូរ, ប្រើជាគ្រឿងកក់សក់ឬលាងជម្រះ, គេច្រើនយកផ្លែទុំក្រៀមមកដាក់ត្រាំក្នុងទឹកផ្ដិលលាយជាមួយនឹងចំណិតផ្លែក្រូចសើច ហៅថាទឹកសម្បួរប្រើជាទឹកមង្គលសម្រាប់ជជុះរលាស់ប្រោះព្រំជម្រះចង្រៃ។

២- **សម្បួរទេស** ឬ **សម្បួរព្រាក់** : សម្បួរស្លឹកល្អិតៗ ផ្កាសណ្ឋានស្រដៀងនឹងផ្កាក្ដុម្ពកាលណារីកមានពណ៌ស, ត្រួយផ្កាផ្លែខ្ចីប្រើជាអន្លក់ឬរបោយបាន, គេច្រើនដាំធ្វើជារបងភូមិលំនៅ។

៣- **សម្បួរមាស** : សម្បួរដើមតូចផ្កាតូចៗ ពណ៌លឿង ក្លិនក្រអូបឆ្អិត, គេច្រើនដាំប្របមាត់ទ្វាររបងផ្ទះឬដាំធ្វើជារបងផ្ទះក៏មាន។

**សម្ពរ** (បា.សំ.) *ន.* ការសង្រួម, ការស្ងប់ស្ងៀម, ការស្រគត់ស្រគំ, ការរម្យទម។

**ពាក្យកាព្យ**

វីអ្នកត្រេកអរ ចំពោះសីលធម៌ ត្រូវមានសម្ពរ
ឥន្ទ្រិយប្រាំមួយ ជាត្រួយសំវរ ទើបមានអំណរ
ទាំងខ្លួនទាំងគេ។

**សម្ភារ** (បា.សំ.) *ន.* ការសន្សំ, ការសាងសន្សំកុសល; ការសាងសន្សំបន្ទុំបារមី (របស់ពោធិសត្វ); តេជះ, អំណាច; សេចក្ដីទំនុកបម្រុង; ការស្រោចស្រង់, សេចក្ដីសង្គ្រោះ; ការរួបរួម; របស់ដែលត្រូវរួបរួម, របស់ដែលត្រូវផ្សំជាមួយគ្នា; គ្រឿងផ្សំ; គ្រឿងផ្គុំ; អង្គ; ចំណែក; ពួក; ទ្រព្យ; របស់ដែលត្រូវតែមានខានពុំបាន, គ្រឿងប្រើប្រាស់; ...។

- **គ្រឿងសម្ភារ** : គ្រឿងផ្សំ; គ្រឿងប្រើប្រាស់។
- **ម្លប់សម្ភារ** : ម្លប់តេជះ, ម្លប់បុណ្យ។

❖ សូមជ្រកកោនក្រោមម្លប់សម្ភារព្រះបាទម្ចាស់។

**សម្ភោរ** *ន.* ឈ្មោះគ្រឿងភ្លេងពិណពាទ្យមួយប្រភេទរាងមូលជ្រលមខាងដើមធំជាងខាងចុងដាសស្បែកទាំងពីរ ខាងមានចម្រៀកស្បែករឹតពន្លស្រោបតួ, ដាក់ផ្ដេកភ្ជាប់លើជើងទ្រពីក្រោម, កាលណារៀបនឹងទះលេងភ្លេងត្រូវកិនបាយលាយផេះបិទចំកណ្ដាលស្បែកដាសដើម្បីឱ្យលាន់សូរធំតូចក្រអួន, ប្រើទះនឹងបាតដៃទាំងពីរខាង :

❖ ស្គរធំជាគូទទួលចង្វាក់សម្ភោរ។

**សរ** (**បា.**) *ន.* ព្រួញ, កាំ, កាំធ្នូ, កាំស្នា :

❖ ត្រូវសរ

❖ ស្ដេចផ្លែងសរ។

✍ **សរជ័យ** : សរមានជ័យ។

✍ **កូនសរ** : ព្រួញ; គ្រាប់កាំភ្លើង។

(**បា.**) *កិ.* រលឹក, រលឹកឃើញ, នឹកឃើញ, សាដឹងឡើងវិញ។

✍ **សរជាតិ** : ដឹងជាតិ។

✍ **សរញាណ** : ពិចារណាឬរំពឹងដឹងហេតុច្បាស់ទៅខាងអតីតកាលឬខាងអនាគតកាល។

❖ ព្រះពុទ្ធទ្រង់សរញាណ... ញាណជាគ្រឿងរលឹកឃើញ, ប្រាជ្ញាជាគ្រឿងរលឹកឃើញ។

**សរសើរ** *កិ.* និយាយលើក, លើកតម្កើង, និយាយស្ញើច, ពោលពណ៌នាគុណ :

❖ សរសើរចំណេះ

❖ សរសើរមារយាទ។

**សរសេរ** *កិ.* គូស, វាសឱ្យដិតជាតួអក្សរឬលេខឬក៏ឱ្យដិតអក្សរកើតបានជាសេចក្ដី :

❖ សរសេរអក្សរ

❖ សរសេរសំបុត្រ។

**សសៀរ** *កិ.* ឬ *កិ.វ.* សៀរសំរៀមៗ :

❖ សសៀរតាមជញ្ជាំង

❖ ដើរសសៀរតាមមាត់ត្រពាំង។

*និ.* ជិតនឹង, រកកល់នឹង :

❖ សសៀរនឹងបាន។

**សហារ** ឬ **សាហារ** (**បា.សំ. សហសា** "រហ័ស, រួសរាន់, ដោយប្រញាប់)

*គុ.* កាច, សហាវ; ព្រហើន; រហ័សខឹង, ហៃខឹង; ដែលច្រណែន, ឫស្យា។

**សហិចសហារ** *គុ.* ដែលសង្វាត, ដែលវាតអាទ្យ, ដែលស្រវាស្រទេញ; ដែលវវះវវាមកាម :

❖ មនុស្សសហិចសហារ

❖ ចិត្តសហិចសហារ (និយាយថា ស្វាហិចស្វាហារ ក៏មាន)។

**សាកសួរ** *កិ.* សួរសាកមើលឱ្យជាក់, សួរសង្កេតពីមួយទៅមួយឬពីនេះទៅនោះឱ្យជាក់សេចក្ដី :

❖ សាកសួរឱ្យច្បាស់ការ (និយាយថា សួរសាក ក៏បាន)។

**សាគរ** (**បា.សំ.**) *ន.* សមុទ្រ។ មានសេចក្ដីតំណាលក្នុងរឿងរាមាយណៈថា សមុទ្របានជាហៅ សាគរ ព្រោះកើតអំពីពួកព្រះរាជបុត្ររបស់ព្រះបាទ សគរៈ កែនពលឱ្យជីក។

**សាជូរ** ឬ **សាច់ជូរ** *ន.* ធាតុផ្សំមានបែបភាពជាអំបិលជូរ សាច់រឹងជាដុំសម្រាប់ប្រើកូរលាយទឹកជ្រលក់ឱ្យជិតស្រស់ពណ៌ជាដើម។ សាច់ជូរមាន២ប្រភេទគឺ

➣ **សាច់ជូរ-ស** : មានសាច់ពណ៌ស។

➣ **សាច់ជូរខៀវ** : មានសាច់ពណ៌ខៀវស្ទើរបៃតងចាស់។

**សាទរ** (បា.សំ.) *គុ.* ឬ *ន.* សេចក្តីអើពើ, សេចក្តីគោរព, ការយកចិត្តទុកដាក់, ការសម្តែងសេចក្តីអើពើ, ការគោរព; រាក់ទាក់, រួសរាយ :

❖ មានសាទរ

❖ ទទួលភ្ញៀវដោយសាទរ។

**សាមណេរ** (បា.) *ន.* បព្វជិតពុទ្ធសាសនិកអ្នកកាន់សីល១០ (លោកនេន); បើស្ត្រីជា សាមណេរី (តែសម័យឥឡូវមិនមាន)។

➣ **សាមណេរសិក្ខា** : សិក្ខាសម្រាប់សាមណេរ។

➣ **សាមណេរគ្រោង** : សាមណេរធំ, សាមណេរបួសឯចាស់។

**សារ** (បា.សំ.) *ន.* ខ្លឹម; សេចក្តីខ្ជាប់ខ្ជួន, សេចក្តីមាំមួន, ការរឹងប៉ឹង; ការសំខាន់, របស់សំខាន់; គោល, គោលចារឹក, ហ្ល័កឋាន; កម្លាំង; អំណាច, សេចក្តីអង់អាច, សេចក្តីក្លាហាន; សំណាង, បុណ្យភព្វ; តម្លៃ, ទ្រព្យ, សម្បត្តិ; របស់សុទ្ធ; សេចក្តីពិត; ប្រយោជន៍, ផលប្រយោជន៍; ធាតុសុទ្ធ ឬធាតុផ្សំណាមួយ; សំបុត្រ, ចុតហ្មាយ; ពាក្យសង្ខេប, សេចក្តីបំប្រួញ។

*គុ.* រឹង, រឹងប៉ឹង, ខ្ជាប់ខ្ជួន, មាំមួន; ខ្លាំង, ដែលមានកម្លាំង; ដែលក្លាហាន, អង់អាច, អាចប៉ាន; ដែលពិត, ប្រាកដ; មានតម្លៃ; ថ្លៃ, ថ្លៃថ្លា, ប្រសើរ, ខ្ពង់ខ្ពស់; សំខាន់; គ្រប់, គ្រប់សព្វ; ...។

✍ **ខ្លឹមសារ** : ខ្លឹមរឹង, ខ្លឹមសំខាន់; ប្រយោជន៍ថ្លៃថ្លា។

✍ **មានសារមកដល់** : មានសំបុត្រមកដល់។

✍ **ឥតសារ** : ឥតខ្លឹម; ឥតតម្លៃ; ឥតប្រយោជន៍។

*ន.* ដំរីស្ទាវឬដំរីមានភ្លុកដែលធំអស់ទំហំហើយ :

❖ ដំរីសារ។

**(ព.ឆ.ចុ.) ដំរីសារស្លាប់យកចង្អេរបាំង** : ការអាក្រក់យ៉ាងធំខំប្រឹងបិទបាំងដោយហេតុឬដោយឧបាយបន្តិចបន្តួចធ្វើម្ដេចនឹងកំបាំង។

**សិរ** (**បា.**) *ន.* ក្បាល។ (**រ.ស.**) :

❖ ព្រះសិរ។

✍ **វង់ព្រះសិរ** : ខ្សែយសម្រាប់ក្សត្រកើយ។

☞ ខ្មែរហៅសាច់ដែលដុះ (តាមសញ្ជាតិ) ជាពកឬជាបន្ទះលើក្បាលសត្វពួកខ្លះមានមាន់ជាដើមថា សិរ ដែរ :

❖ សិរមាន់។

**សុករ (បា.សំ. សូករ)** *ន.* ជ្រូក។

**សុធីរ** (**បា.សំ.**) *ន.* គំនិតរឹងប៉ឹង, គំនិតខ្ជាប់ខ្ជួន។ អ្នកមានចំណេះខ្ពស់, អគ្គបណ្ឌិត (បើស្ត្រីជា សុធីរា)។

**សុន្ទរ** (បា.សំ.) *គុ.* ល្អ, ប្រពៃ; ពីរោះ, ដែលគួរចង់ឮគួរចង់ស្ដាប់, ពីរោះចាប់ចិត្ត; ដែលគួរស្រលាញ់; ដែលគួររីករាយ។

✍ **សុន្ទរកថា** : សម្ដីពីរោះ, សម្ដីគួរចង់ស្ដាប់។

☞ ខ្មែរហៅសម្ដីសូត្រថ្លែងសេចក្ដីក្នុងទីប្រជុំជនថា សុន្ទរកថា ដែរ :

❖ សូត្រសុន្ទរកថាក្នុងមហាសន្និបាត។

✍ **សុន្ទរកម្ម** : អំពើល្អ; ការងារល្អ។

✍ **សុន្ទរភាព** : ភាពល្អ, សេចក្ដីល្អ។

✍ **សុន្ទរមតិ** : គំនិតត្រូវ។

✍ **សុន្ទរយាត្រា** : ដំណើរល្អ, ដំណើរមានសុខស្រួល។

✍ **សុន្ទរយាន** : យានល្អ, យានស្រួលជិះ។

✍ **សុន្ទរវាចា** : ពាក្យពីរោះ។

✍ **សុន្ទរវាទិន** : អ្នកដែលមានសម្ដីពីរោះ (បើស្រ្តីជា សុន្ទរវាទិនី)។

✍ **សុន្ទរសម្បត្តិ** : សម្បត្តិល្អ; សម្បត្តិរបស់អ្នកល្អ (ការប្រព្រឹត្តល្អ)។

✍ **សុន្ទរោវាទ** : ឱវាទល្អ, ដំបូន្មានត្រូវ។

**សុភរ** (បា.) *គុ.* ដែលងាយចិញ្ចឹម, ដែលគេស្រណុកចិញ្ចឹម។

✍ **សុភរបុគ្គល** : បុគ្គលដែលគេស្រណុកចិញ្ចឹម, អ្នកមិនរើសអើង។

✍ **សុភរបុត្ត** : បុត្រដែលមាតាបិតាស្រណុកគេចិញ្ចឹម។

✍ **សុភរភាព** : ភាពជាអ្នកងាយគេចិញ្ចឹម។

**សុរ** (**បា.សំ.**) *ន.* ទេវតា។

🙞 **សុរចាប** : ធ្នូទេវតា។

🙞 **សុរជន** : ជនជាទេវតា។

🙞 **សុរកុល** : រោងប្រតិស្ឋានទេវរូប, អាស្រមប្រតិស្ឋានទេវរូប។

**សូរ** (**សំ.ភ្ន.**) *ន.* សព្ទ, សំឡេង; សំឡេងលាន់ឮ :

❖ សូរផ្គរ

❖ សូរភ្លេង។

🙞 **សូរសព្ទ** : សូរសំឡេងឬសំឡេងកំភ្លៀវក្លា, សំឡេងខ្លាំង។

❖ សូរសព្ទសំនៀងនៃព្រះសម្មាសម្ពុទ្ធប្រកបដោយអង្គ៨ ហៅថា អដ្ឋង្គុបតសរៈ ឬ អដ្ឋង្គិកសរៈ គឺ

១- ស្រលះស្រឡះស្មើៗ

២- ស្រទន់ពីរោះ

៣- ឱ្យអ្នកស្តាប់ងាយដឹងងាយយល់

៤- គួរឱ្យអ្នកស្តាប់ចង់ស្តាប់មិនធុញទ្រាន់

៥- ក្បោះក្បាយមិនស្អកស្អា

៦- មានសូរនិគ្គហិតមូលក្រឡង់

៧- មានសូរជ្រៅក្នុងទ្រូង

៨- ក្រាងក្រអៅ។

*គុ.* ក្លៀវក្លា, អង់អាច, ក្លាហាន, អាចហ៊ាន, ដែលមានចិត្តមុត។

*ន.* អ្នកក្លៀវក្លា, អ្នកអង់អាច, អ្នកចម្បាំង។

✍ **ស្ទូរចិត្ត** : ចិត្តក្លាហាន។

✍ **ស្ទូរបុរស** : បុរសក្លៀវក្លា; អ្នកចម្បាំង។

✍ **ស្ទូរពាក្យ** : សម្ដីក្លៀវក្លា, សម្ដីក្អេងក្អាង; សម្ដីអ្នកក្លៀវក្លា។

✍ **ស្ទូរភាព** : ភាពក្លៀវក្លា, សេចក្ដីអង់អាច។

✍ **ស្ទូរយុទ្ធ** : ចម្បាំងខ្លាំងក្លា។

**សួរ** *កិ.* ពោលពាក្យឆ្ពោះទៅរកអ្នកដទៃឱ្យគេឆ្លើយតប, ឱ្យគេប្រាប់ :

✍ **សួរចំណើង** : សួរឱ្យដឹងការណ៍។

✍ **សួរនាំ** : សួរឱ្យណែនាំ។

✍ **សួរសុខទុក្ខ** : សួរឱ្យដឹងអំពីសុខទុក្ខ...។

**សៀរ** *កិ.* ឬ *កិ.វិ.* ដើរតាមក្បែរទីប្របេះឬទីផុតមានក្បែរជញ្ជាំង, ក្បែរមាត់ព្រែកជាដើម :

- សៀរតាមជញ្ជាំង
- ដើរសៀរតាមមាត់ស្ទឹង។

**សេតម្ពរ** (ឆា.) *ន.* សំពត់, សម្លៀក, សំពត់ស្លៀកដណ្ដប់; សំពត់ស, សំពត់ស្លៀកដណ្ដប់មានពណ៌ស។ អ្នកដែលប្រកាន់ស្លៀកដណ្ដប់ចំពោះតែសំពត់មានពណ៌សតមមិនប្រើប្រាស់សំពត់ពណ៌ឯទៀត; អ្នកស្លៀកដណ្ដប់សកាន់សីល។

**ពាក្យភាព្យ**

ពួកសេតម្ពរ កាន់សីលសង្វរ និងធម៌សុចរិត

លះបង់អំពើ ដែលទាញនាំចិត្ត ឱ្យលង់គំនិត

ប្រព្រឹត្តធម៌ខ្មៅ។

**សេរ** *គុ.* ឬ *ន.* ដែលមានសិទ្ធិលើខ្លួនឯង, ដែលធ្វើអ្វីបានតាមចិត្ត, ការប្រព្រឹត្តទៅបានតាមទំនើងខ្លួន, ការធ្វើអ្វីបានតាមអំពើចិត្ត, អំណាចលើខ្លួន។

✍ **សេរជន** : អ្នកដែលមានសិទ្ធិលើខ្លួន។

✍ **សេរកថា** : សម្ដីឥតក្រែង, សម្ដីឥតញញើត។

✍ **សេរប្បទេស** : ប្រទេសឯករាជ្យដែលមានអំណាចលើខ្លួនឯង។

**សោទរ** (សំ.) *ន.* បងប្អូនប្រុសរួមឧទរមួយ, បងប្អូនប្រុសពោះមួយ។

**សំណួរ** *ន.* ពាក្យសួរ; សេចក្ដីសួរសុខទុក្ខដោយសរសេរសំបុត្រឬផ្ដាំនឹងអ្នកដទៃ :

❖ កូនខ្ញុំតែងមានសំណួរមករឿយៗប្រាប់ថាសុខសប្បាយទេ។

**សំទារ** *កិ.* ឬ *កិ.វិ.* ដែលស្រែកឮខ្ទរខ្ទារ, ស្រែកខ្លាំង :

❖ ដំរីសំទារកោញ្ចនាទ

❖ ស្រែកសំទារពេញសំឡេង។

**សំបារ** *ន.* ចម្រៀកស្រទបចេកដែលច្រៀកធ្វើជាចំណងចងអ្វីៗ, ច្រើនហៅពេញថា សំបារចេក។

**សំបោរ** *ន.* ធាតុទឹករាវឬខាប់ដែលហូរចេញមកតាមរន្ធច្រមុះដោយមានរោគផ្ដាសាយឬកើតឫសដូងច្រមុះ, ត្រូវចំហាយក្ដៅជាដើម :

❖ ហៀរសំបោរ។

☞ រំអិលដែលធ្លាក់មកតាមឧច្ចារមគ្គ :

❖ កើតរោគមួលធ្លាក់សុទ្ធតែសំបោរ។

**សំស្ការ (សំ.)** *ន.* សង្ខារ; ...។ ខ្មែរប្រើសំដៅសេចក្ដីថា ការលើកសពធ្វើឈាបនកិច្ច, ការគាស់ខ្មោចដុត, ការលើកខ្មោចស្រោចផ្អឹង និយាយបានតែជាមួយនឹងពាក្យថា “លើកសព”។

**ស្ករ** *ន.* វត្ថុមានរសផ្អែមកើតអំពីទឹកអំពៅ, ទឹកត្នោតជាដើមដែលរំងាស់ឱ្យបានសាច់។

- **ស្ករក្រាម** : ស្ករអំពៅមានសាច់រឹងជាដុំៗសណ្ឋានក្រួស។
- **ស្ករដូង** : ស្ករកើតពីទឹកផ្កាដូង។
- **ស្ករត្នោត** : ស្ករកើតពីទឹកផ្កាត្នោត។
- **ស្ករទន្សែ** : ស្ករកើតពីទឹកផ្កាទន្សែ។
- **ស្ករផែន** : ស្ករដែលចាក់ជាផែន។
- **ស្ករ-ស** : ស្ករអំពៅមានសាច់ស។
- **ស្ករអំពៅ** : ស្ករបន្ទះដែលកើតពីទឹកអំពៅ។

**ស្កាវ** *ន.* សត្វចតុប្បាទមួយប្រភេទមុខស្រួចឆ្អឹមជើងខ្លីៗសម្បុរត្នោត, ស្រដៀងនឹងកំប្រុកតែមាឌធំជាង, ជាពួករន្ធកសត្វ។

**ស្គរ** *ន.* គ្រឿងទូងវាយដំឱ្យលាន់ឮសូររំពងដាសដោយស្បែកតែម្ខាងឬទាំងពីរខាង, មានច្រើនបែប :

🖎 **ស្គរខ្មែរ** ឬ **ស្គរអារក្ស** : ស្គរមានរាងធំម្ខាងតូចម្ខាងធ្វើដោយដីដុតដាសតែម្ខាងដោយស្បែកពស់ប្រមោយដំរីឬស្បែកពស់ឯទៀតក៏បានខ្លះ។

🖎 **ស្គរជ័យ** : ស្គរសម្រាប់ទូងយកជ័យ, ស្គរទ័ព។

🖎 **ស្គរធំ** : ស្គរមានរាងធំធ្វើដោយឈើលុងដាសស្បែកគោទាំងពីរខាងសម្រាប់វាយប្រាប់យាម, វាយឱ្យសញ្ញាគ្នាឬប្រើក្នុងវង់ភ្លេងពិណពាទ្យ។

**ស្ដារ** *កិ.* ធ្វើមេថុនសេវនៈ (ចំពោះតែ ខ្វះគសត្វ ឬ នីចជាតិ) :

❖ ពស់ស្ដារគ្នា (ប្រើជាពាក្យប្រៀបសម្រាប់សត្វឯទៀតឬមនុស្សក៏បាន)។

**ស្ងោរ** *កិ.* រំងាស់អ្វីៗក្នុងទឹកពុះឱ្យឆ្អិន, រំងាស់អ្វីៗក្នុងទឹកពុះឱ្យរលួយ, រំងាស់អ្វីៗក្នុងទឹកពុះឱ្យចេញរសជាតិជាដើម :

❖ ស្ងោរត្រី

❖ ស្ងោរដំឡូង

❖ ស្ងោរសំពត់។

*គុ.* ដែលស្ងោររួចហើយ, ដែលឆ្អិនឬរលួយព្រោះស្ងោរ :

❖ ត្រីស្ងោរ

❖ មាន់ស្ងោរ

❖ ពោតស្ងោរ។

**ស្ទុរ** *កិ.* ស្ទុល, សំកុកសំកុលជ្រប់ដោយមានជំងឺ, សំកុកសំកុលជ្រប់ដោយមិនស្រួលខ្លួន (ចំពោះតែបក្សី) :

❖ មាន់ស្ទុល

❖ លលកស្ទុល។

**ស្ថាពរ** *គុ.* មាំមួន, មាំទាំ; ខ្ជាប់ខ្ជួន; រឹងប៉ឹង; ឋិតថេរ, ដែលទុកជាបានការស្រេចឥតរើរុះ :

❖ របស់ស្ថាពរ។

**ស្ថិរ** (សំ.) *គុ.* ដែលឋិតនៅបានយូរ, ឋិតថេរ, មាំមួន, មាំទាំ; ខ្ជាប់ខ្ជួន; រឹងប៉ឹង។

✍ **ស្ថិរចិត្ត** : ចិត្តខ្ជាប់ខ្ជួន, ចិត្តរឹងប៉ឹង។

✍ **ស្ថិរប្រាជ្ញា** : ប្រាជ្ញាខ្ជាប់ខ្ជួន។

✍ **ស្ថិរភាព** : ភាពឋិតថេរ...។

**ស្ទុកស្ទុរ** *ន.* ឈ្មោះឈើធំមួយប្រភេទសំបកក្រាស់, ផ្លែតូចៗ មូលៗជាចង្កោមៗ អ្នកស្រុកខ្លះប្រើស្ងោរបរិភោគ (ហៅក្លាយជា ស្ទុកស្ទោរ ក៏មាន)។

**ស្ទូរ** *កិ.វិ.* ដែលមើលទៅឃើញស្ទុងវែងដោយទុលខ្ពស់ឡើងដូចគេទទូរ :

❖ ត្រីរ៉ស់រត់ស្ទូរ។

**ស្មើរ** *គុ.* ដែលមិនពេញ, មិនល្មម, មិនគ្រប់គ្រាន់; មិនទាន់ដល់កំណត់ :

❖ ទុំស្មើរ

❖ របស់ស្មើរ។

*កិ.វិ.* ដែលមិនដាច់ស្រេច, ដែលនៅរារែក :

❖ ស្ទើរទៅស្ទើរនៅ។

**ស្ទើរចិត្ត** : មិនល្មមដល់ចិត្ត, តិចនឹងចិត្ត។

**ស្ទើរដៃ** : មិនពេញដៃ, មិនអស់ពីដៃ។

*និ.* រកកល់តែ, រកកល់នឹង :

❖ ស្ទើរតែមិនបាន

❖ ស្ទើរនឹងមិនកើត។

**ស្នូរ** *ន.* សូរ, សូរសព្ទ។

**ស្នុរ** ឬ **ស្នុល** *ន.* ប្រភេទសាច់សំពត់ដែលត្បាញវែងកើនទៅខាងមុខត្រឹមចុងដៃ ឈោងដៃត្បាញទៅទៀតមិនកើត ត្រូវមូរដាក់ផ្សំម្តងឱ្យខើចខ្លីសិនហើយទើបត្បាញតទៅទៀត (ច្រើននិយាយថា ស្នុល ជាង) :

❖ ថ្ងៃនេះត្បាញបានតែមួយស្នុល។

**ស្ប៉ុរ** ឬ **ស្ប៉ុល** *គុ.* ដែលឡើងសាច់ស្ប៉ុល, ស្តុរ :

❖ មុខហើមស្ប៉ុល

❖ ឡើងសាច់ស្ប៉ុល។

**ស្តុរ** *កិ.វិ.* ឬ *គុ.* ដែលឡើងសាច់ជ្រោកពពុរ, ស្ប៉ុរ :

❖ សាច់ស្តុរ

❖ ហើមស្តុរ។

**ស្តោរ** *គុ.* ដែលហើមពោរឡើង, ស្តុរ :

❖ មុខស្ពោរ

❖ ហើមស្ពោរ។

**ស្មូរ** *ន.* អ្នកដែលនាំពត៌មានពីសាក្សីមកប្រាប់ដល់អ្នកមានខ្លួន, សាក្សីបន្ត។

**ស្អូរ** *គុ.* កំណាញ់រឹតត្បិតឥតអៀនខ្មាស :

❖ ចិត្តស្អូរ

❖ មនុស្សស្អូរ។

*កិ.វិ.* ដែលហៃទទូចឥតខ្មាស :

❖ ស្អូរសុំ។

**ស្មេរ** *ន.* អ្នកសរសេរ (ស្មៀន) :

❖ **ស្មៀនស្មេរ** : ស្មៀនអ្នកសរសេរ, ស្មៀនធម្មតា។

**ស្មោះខារ** *កិ.វិ.* ឬ *គុ.* ខ្ជីខ្ជាតាមតែរួចពីដៃ, ខ្ជីខ្ជាតាមតែរួចពីមាត់, ខ្ជីខ្ជាតាមតែប្រទះ, ខ្ជីខ្ជាតាមតែបាន :

❖ ការស្មោះងារ

❖ សម្តីស្មោះងារ

❖ ធ្វើការស្មោះងារ។

**ស្មោះសរ** *ន.* សេចក្តីរីករាយរាក់ទាក់, សេចក្តីរួសរាយ, សាទរ :

❖ ទទួលភ្ញៀវដោយស្មោះសរ។

**ស្រករ** *កិ.វិ.* ឬ *គុ.* ស្របាក់ស្របាលគ្នា, មុនក្រោយគ្នាបន្តិចបន្តួច :

❖ អាយុស្រករគ្នា

❖ មកដល់ស្រុករគ្នា

❖ ពួកក្មេងស្រុករៗគ្នា។

**ស្រីង្គារ** (**សំ.**) *ន.* សេចក្ដីស្រលាញ់; តម្រេក; គ្រឿងប្រលោមចិត្ត។

✍ **ស្រីស្រីង្គារ** : ស្រីដែលមានលម្អគួរឱ្យកើតសេចក្ដីស្រលាញ់។

**ហារ** (**បា.សំ.**) *ន.* ការនាំយកអ្វីៗទៅ; អ្វីៗដែលល្មមនាំយកទៅបាន។ ខ្សែជាគ្រឿងប្រដាប់ក។

*កិ.* ចែក, បែងជាចំណែក, រកឱ្យឃើញជាចំណែក :

❖ ហារលេខ។

✍ **លេខហារ** : លេខចែក។

**ហីរ** (**សំ.**) *ន.* ពេជ្រ។

✍ **ហីរការ** : ជាងច្នៃពេជ្រ (បើស្ត្រីជា ហីរការិកា)។

**ហឹរ** *គុ.* ដែលមានរសផ្សាក្ដៅឆ្លួល (ដូចយ៉ាងរសម្ទេសខ្លាំង, ម្រេច) :

❖ រសហឹរ

❖ សម្លហឹរ។

**ហូរ** *កិ.* រអិលជ្រុលទៅឯងនៃទឹកឬវត្ថុរាវ, រអិលជ្រុលទៅឯងនៃខ្សាច់ជាដើម :

❖ ទឹកហូរ

❖ ឈាមហូរ

❖ ទឹកភ្នែកហូររហាម។

*កិ.១.* ឬ *គុ.* រអិលឥតទើសទាក់, រអិលមិនរអាក់រអួល :

❖ និយាយហូរ

❖ មើលសំបុត្រហូរ។

**ហួរ** *កិ.* ស្រូបរាវដោយចំពុះ (ចំពោះតែសត្វពួកទាពួកក្ងាន) :

❖ ទាហួរ

❖ ប្រវឹកហួរ។

**ហើរ** *កិ.* ទៅឯអាកាសដោយកម្លាំងស្លាបជក់ខ្យល់ :

❖ សត្វហើរព្រាតរសាត់ឡើងដោយកម្លាំងខ្យល់

❖ ស្លឹកឈើហើរឡើងទៅឯអាកាសដោយជក់ខ្យល់។

*គុ.* ដែលលូតវែងខ្ពស់ឡើង (ចំពោះតែទំពាំង) :

❖ ទំពាំងហើរ

❖ ហោះហើរ។

*គុ.* ដែលថយខ្សោយពណ៌, សៅសម្បុរព្រោះត្រូវកម្តៅថ្ងៃជាដើម :

❖ សំពត់ហើរពណ៌។

**ហៀរ** *កិ.* កំពប់ហូរចេញព្រោះពេញខ្លាំងហួសប្រមាណ, កំពប់ហូរចេញព្រោះខ្ពុរឡើង, កំពប់ហូរចេញព្រោះធ្លាក់រអិលជ្រុលចុះមក :

❖ ទឹកត្នោតហៀរពីមាត់បំពង់

❖ ទឹកបបរពុះហៀរពីមាត់ឆ្នាំង។

៦ **ទឹកហៀរភ្លឺ** : ទឹកច្រើនពេកហៀរលើភ្លឺ។

*៣.* ដែលច្រើនពេកចង្អៀតអង្គុយឬឈរមិនអស់គ្នា :

❖ មនុស្សច្រើនហៀរសាលា។

**ហៀរហូរ** (ព.ប្រ.) សម្បូណ៌គរគោក (ច្រើនប្រើ ហូរហៀរ ជាង) :

❖ ម្ហូបចំណីសម្បូណ៌ហូរហៀរ។

**ហោរ** *ន.* អ្នកចេះហោរាសាស្ត្រ, អ្នកចេះតារាសាស្ត្រ, ហិណ្ឌិក :

❖ ក្បួនហោរ

❖ ទំនាយហោរ។

**ហ្វារ** (បារ.)*ន.* ចង្កៀងមានពន្លឺចាំងខ្លាំងសម្រាប់រថយន្តជាដើម។

✍ **ហ្វារសមុទ្រ** : ហ្វារបញ្ចាំងពន្លឺភ្លែតៗប្រាប់ផ្លូវនាវាសមុទ្រ។

**អក្សរ** (សំ.) អក្ខរៈ។

✍ ***អក្សរខម*** : អក្សរខ្មែរ (ហៅតាមសៀមដែលយកអក្សរខ្មែរទៅប្រើ, លុះចំណេរកាលតមកខ្មែរហៅអក្សរមូលដែលមានសណ្ឋានតួរាងខ្លាំងៗបន្តិចបែបភាពខុសគ្នាអំពីអក្សរមូលធម្មតាខ្លះថាអក្សរ ខម ឬ តួខម, បើចារឬសរសេរតួរាងបែបនោះប៉ុន្តែតូចៗហៅថា ភ្ជខម)។

✍ ***អក្សរខ្សៀក*** : អក្សរខ្មែរមានសណ្ឋានតួរាងជាចំហៀងៗសម្រាប់សរសេរខ្សៀកៗរំហ័សការ។

✍ ***អក្សរត្រវាត់*** : អក្សរដែលមានជើងរគ្រវាត់ឬក្រវាត់ពទ្ធពីក្រៅគឺអក្សរដែលផ្សំជាមួយនឹងជើង រ ឬផ្ញើជើង រ ដូចជា ក្រ, គ្រ, ច្រ, ជ្រ ជាដើម។

❧ **អក្សរជ្រៀង** : អក្សរខ្មែរមានសណ្ឋានត្រូវាងទ្រេត ៗ។

❧ **អក្សរបំបែក** : ព្យញ្ជនៈដែលផ្សំជាមួយនឹងស្រៈតាមលំដាប់, ដូចជា កកាកិកីកឹកឺ...។

❧ **អក្សរប្រកប** : អក្សរដែលសរសេរពីខាងចុងពាក្យឥតចេញសំឡេង, ខ្មែរដូចជា កក, កង, ចក, ចង ជាដើម។

❧ **អក្សរប្រយោគ** : អក្សរផ្ញើជើងឬអក្សរគ្រវាត់ (ហៅ អក្ខរប្បយោគ ក៏បាន)។

❧ **អក្សរផ្ញើជើង** : អក្សរដែលផ្សំជាមួយនឹងអក្សរឯទៀត (អក្សរប្រយោគ), ដូចជា ក្ង, ក្ន, ខ្ង, ខ្ន ជាដើម។

❧ **អក្សរពុម្ព** : អក្សរដែលសិតជាតួរាងសម្រាប់បោះពុម្ពឬស្នាមអក្សរដែលបោះពុម្ពហើយ។

❧ **អក្សរលក្ខណ៍** : សំបុត្រសម្គាល់។

❧ **អក្សរសព្ទ** : អក្សរល្អិត ៗដែលសរសេរដាក់សព្ទប្រែនៅប៉ែកខាងលើក្បៀរភាសាដទៃ។

❧ **អក្សរសាស្ត្រ** : វិជ្ជាអក្សរ; ក្បួនប្រាប់វិធីអក្សរ, ការសរសេរត្រឹមត្រូវក្នុងភាសាណាមួយ; មុខការខាងនិពន្ធ, ...។

**អគារ** (បា.សំ.) *ន.* មន្ទីរ, ផ្ទះ; រោង។

❧ **អគារដ្ឋាន** : ទីផ្ទះ។

✍ **អគារភូមិ** : ជាន់នៃផ្ទះ, ថ្នាក់នៃផ្ទះ។

✍ **អគារសិក្សា** : មន្ទីរសម្រាប់រៀនសូត្រ, សាលារៀន...។

**អគោចរ** (បា.សំ.) *ន.* ទីដែលមិនគួរទៅ; ទីដែលបព្វជិតពុំគួរទៅ :

❖ លំនៅពេស្យា

❖ លំនៅស្ត្រីមេម៉ាយ

❖ លំនៅស្ត្រីក្រមុំចាស់

❖ លំនៅភិក្ខុនី

❖ លំនៅបណ្ឌក

❖ ទីប្រជុំផឹកសុរាឬរោងលក់សុរា។

**អគ្គិសាលា** *ន.* រោងភ្លើង :

❖ ក្នុងវត្តមួយៗត្រូវមានអគ្គិសាលាសម្រាប់ដាំទឹកក្តៅ, ក្នុងវត្តមួយៗត្រូវមានអគ្គិសាលាសម្រាប់ស្ងោរក្រាក់ខ្នុរជ្រលក់ចីវរ។

**អង្ករ** *ន.* គ្រាប់ស្រូវឬគ្រាប់ធញ្ញជាតិដែលបុកឬកិនយកអង្កាមឬយកសំបកចេញហើយ :

❖ អង្ករពោត

❖ អង្ករខ្សាយ

❖ អង្ករដំណើប។

✍ **អង្ករដើម** : អង្ករដែលសម្រាំងយកសុទ្ធតែល្អឥតបាក់គ្រាប់។

✍ **អង្ករលីង** : អង្ករដែលលីងឱ្យខ្លោចប្រើជាគ្រឿងផ្សំអាហារ។

ᩍ **អង្គរសម្រិត** : អង្គរដែលស្រិតរួចហើយ។

ᩍ **អង្គរសម្រូប** : អង្គរដែលគ្រាន់តែបុកឬកិនយកអង្កាមចេញនៅមិនទាន់ស្រិត។

**ពាក្យកាព្យ**

អសារក្តីបី　　បណ្ដាំមេជី　　ព្រេងព្រឹទ្ធប្រដៅ
អង្ករ-សសុទ្ធ　　ចម្អិនឱ្យឆៅ　　ពិសីហើយខ្មៅ
ប្រាជ្ញឥតមារយាទ។

**អង្គរ** (សំ.) *ន.* ពន្លក; ទំពាំង; លំពង់; ខ្នែងខ្ចី។

**អង្គរ** *ន.* ពាក្យប្រើឃ្លាតក្លាយមកពី នគរ "ក្រុង, រាជធានី" ហៅចំពោះតែក្រុងនិងប្រាសាទសិលាបុរាណខ្លះឬទីតំបន់ជាដើមខ្លះក្នុងកម្ពុជរដ្ឋ :

ᩍ **អង្គរធំ** : នគរធំ (មហានគរបុរាណក្នុងខេត្តសៀមរាប)។

ᩍ **អង្គរបុរី** : ឈ្មោះទីក្រុងចាស់តូចមួយក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ។

ᩍ **អង្គររាជ** : ឈ្មោះអាណាខេត្តមួយរបស់ខ្មែរនៅខាងទិសឧត្តរបានទៅអាណាខេត្តរបស់សៀមយូរអង្វែងហើយ។

ᩍ **អង្គរវត្ត** : ឈ្មោះសិលាប្រាសាទបុរាណមួយកន្លែងនៅក្នុងខេត្តសៀមរាបជាមហាប្រាសាទរុងរឿងដោយលម្អគ្មានពីរ។

ᩍ **សៀតប្រាអង្គរ** : ត្រីងៀតឬងៀតប្រាដែលនាំមកពីទន្លេសាបប៉ែកខាងខេត្តសៀមរាប។

✍ **ទឹកអង្គរធាក់** : ទឹកថ្លាដែលហូរត្រឡប់ចេញពីទន្លេសាបនិងបឹងនានាចុះមកវិញក្នុងរដូវសម្រក...។

*ន.* ទីដីជាទួលធំប៉ុន្តែទាបទេរនៅជិតមាត់បឹងធំជ្រៅមានដើមឈើធំៗខ្ពស់ៗជាព្រៃស្ងាត់គេហៅព្រៃនិងបឹងនោះថាព្រៃអង្គរ, បឹងអង្គរទោះបីចំណេរកាលតមកគេកាប់ព្រៃនោះ ធ្វើជាចម្ការទៅហើយក៏គេនៅតែហៅថាចម្ការព្រៃអង្គរ, បឹងអង្គរ ឬ បឹងព្រៃអង្គរ តាមឈ្មោះដើមនោះដែរ។

**អង្គារ** (បា.សំ.) *ន.* ធ្យូង។ (រ.ស.) ព្រះអង្គារ ធ្យូងដែលសល់ពីការថ្វាយព្រះភ្លើងព្រះបរមសពព្រះសម្មាសម្ពុទ្ធឬព្រះរាជា។

✍ **អង្គារដ្ឋាន** : កន្លែងដាក់ធ្យូង។

✍ **អង្គារទារុ** : ឈើដែលប្រើការដុតធ្យូងបាន។

✍ **អង្គារធានិការ** : ជើងក្រាន; ជើងក្រានធ្យូង។

✍ **អង្គារធាត្រី** : ជើងក្រានដុតធ្យូង, ឡដុតធ្យូង។

✍ **អង្គារពាណិជ** : អ្នកលក់ធ្យូង។

✍ **អង្គារពាណិជ្ជ** : ការងារលក់ធ្យូង, របរលក់ធ្យូង, ជំនួញធ្យូង។

(បា.សំ.) *ន.* ឈ្មោះផ្កាយព្រះគ្រោះទី៣ :

❖ ផ្កាយអង្គារ។

✍ **ថ្ងៃអង្គារ** : ឈ្មោះថ្ងៃទី៣នៃសប្តាហ៍។

☞ ឈ្មោះយាមទី៣នៃត្រៃយាម :

❖ ព្រះសក្យមុនីទ្រង់ចូលបរិនិព្វាននៅថ្ងៃអង្គារយាមអង្គារក្នុងបច្ចូស-សម័យថ្ងៃពេញបូណ៌មីខែពិសាខឆ្នាំម្សាញ់...។

**អង្វរ** *កិ.* ពោលពាក្យលំអុតទទូចបន្ទន់ចិត្តឱ្យអាណិត, ពោលពាក្យលំអុតទទូចបន្ទន់ចិត្តឱ្យចុះសម្រុង, ពោលពាក្យលំអុតទទូចបន្ទន់ចិត្តឱ្យយល់ព្រមតាមបំណងរបស់ខ្លួន :

❖ អង្វរឱ្យយល់ព្រមតាម

❖ អង្វរឱ្យលែងប្រកាន់ទោស។

**អង្វរករ** *កិ.* លើកដៃសំពះអង្វរឱ្យគេអាណិត; អង្វរងោចៗរឿយៗ :

❖ ឯងខុសហើយត្រូវអង្វរករគេទៅ!។

**អចិរ** (**បា.សំ.**) *គុ.* ដែលមិនយូរ, ឆាប់, ភ្លាមៗ; ដែលមិនឋិតថេរ។

**អចិរកាល** : កាលមិនយូរ, ពេលខ្លី, ដែលតាំងនៅមិនយូរ។

**អចិរដ្ឋិតិ** : ការឋិតនៅមិនយូរ, ការតាំងនៅមិនយូរ។

**អចិរនិវាស** : ការនៅមិនយូរប៉ុន្មាន; ការនៅសម្នាក់។

**អចិរនិវាសី** : អ្នកដែលនៅមិនយូរប៉ុន្មាន; ភ្ញៀវដែលមកនៅសម្នាក់មួយពេលពីរពេល (បើស្ត្រីជា អចិរនិវាសិនី)។

**អជ្ឈាចារ** (**បា.**) *ន.* ការប្រព្រឹត្តកន្លងបញ្ញត្តិ, ការប្រព្រឹត្តខុសច្បាប់; មារយាទអាក្រក់ :

❖ មនុស្សមានអជ្ឈាចារគេពិបាកស្តីថាណាស់។

**អណ្ដើរ** *ន.* ជណ្ដើរ (គួរនឹងយកសេចក្ដីថាបានជាហៅអណ្ដើរព្រោះសម្រាប់ដើរបង្អន់ជើងឡើងចុះ; បានជាហៅជណ្ដើរព្រោះសម្រាប់ជាន់ដើរឡើងចុះ; ប៉ុន្តែតាមលក្ខណៈនិងសណ្ឋាន, ពាក្យទាំងពីរនេះមានសេចក្ដីត្រូវគ្នាតែមួយយ៉ាងគឺសំដៅសេចក្ដីថា "ប្រដាប់មានកាំជាជាន់ៗឬជាថ្នាក់ៗសម្រាប់ឡើងចុះ" ប៉ុណ្ណោះឯង; សម័យបច្ចុប្បន្ននេះច្រើនប្រើពាក្យ ជណ្ដើរ ជាង)។

**អតិសារ** (**បា.សំ.**) *ន.* រោគមួល, រោគមួលឈាម :

- ❖ រោគអតិសារ ហៅ អតិសាររោគ ក៏បាន។

**អធិការ** (**បា.សំ.**) *ន.* ការបំពេញកុសលដ៏ក្រៃលែង (មហាបរិច្ចាគ); អំណាច; សិទ្ធិឬសិទ្ធិភាព; ការគ្រប់គ្រង; ការបង្គាប់បញ្ជា, បញ្ជាការ; មុខការ; មុខក្រសួង; ទីធ្វើរាជការ; ភារៈ; ច្បាប់, ច្បាប់បញ្ញត្តិ; ចំពូកសេចក្ដី; ដំណើរសេចក្ដី។ អ្នកគ្រប់គ្រង; អ្នកត្រួតត្រា; អ្នកទទួលការខុសត្រូវ :

- ❖ អធិការសាលាបឋមសិក្សា
- ❖ អធិការក្រុមនគរបាលជាតិ។

**អនាគារ** (**បា.**) *ន.* អ្នកគ្មានផ្ទះ គឺអ្នកដែលលះបង់ផ្ទះលំនៅហើយបួស។

- ☙ ***អនាគារធម៌*** : ធម៌សម្រាប់បព្វជិត។
- ☙ ***អនាគារវិន័យ*** : វិន័យសម្រាប់អ្នកបួស។

**អនាចារ** (**បា.សំ.**) *ន.* ការប្រព្រឹត្តខុសបែបបទ, ការខុសសណ្ដាប់ធ្នាប់; ការប្រព្រឹត្តអាក្រក់, ការខ្ជីខ្ជា, ការប្រព្រឹត្តពុំសមគួរ; ការឥតមារយាទ :

❖ ប្រព្រឹត្តអនាចារ។

**អនិស្សរ** (បា.) *គុ.* ឬ *ន.* ដែលមិនមែនជាធំ; អ្នកដែលមិនមែនជាធំលើគេ, ចិត្តដែលមិនមែនជាធំលើរូបកាយ :

❖ ខ្លួនខ្ញុំជាអនិស្សរធ្វើម្ដេចនឹងសម្រេចការនេះបាន!។

✍ **អនិស្សរជន** : ជនដែលមិនមែនជាធំលើគេ។

✍ **អនិស្សរបុគ្គល** : បុគ្គលដែលមិនមែនជាធំលើគេ។

✍ **អនិស្សរភាព** : ភាពនៃអ្នកដែលមិនមែនជាឥស្សរ។

**អនុត្តរ** (បា.សំ.) *គុ.* ដែលប្រសើរផុត, ឥតមានអ្វីស្មើ។

*ន.* ព្រះនាមព្រះសព្វញ្ញុពុទ្ធ :

✍ **អនុត្តរធម៌** : លោកុត្តរធម៌។

✍ **អនុត្តរភាព** : ភាពនៃបុគ្គលដែលគ្មាននរណាមួយផ្ទឹមស្មើបាន, អានុភាពដ៏ខ្ពង់ខ្ពស់; ឧត្តមានុភាពខាងនយោបាយនិងខាងកម្លាំងទ័ពដែលប្រទេសមហាអំណាចណាមួយផ្សាយគ្របសង្កត់ទៅលើប្រទេសដទៃ :

❖ រំលោភលើគេដោយអាងអនុត្តរភាពរបស់ខ្លួន។

**អនុត្ថេរ** (បា.) *ន.* ថេរៈបន្ទាប់, ថេរៈតូច។

**អនុបការ** (បា.សំ.) *គុ.* ដែលមិនមានឧបការ; ដែលមិនមែនជាឧបការ។

*ន.* អ្នកដែលឥតឧបការ (ប្រើជា និរុបការ ក៏បាន)។

✍ **អនុបការគុណ** : ដែលឥតឧបការគុណ; ដែលមិនមែនឧបការគុណ។

✍ **អនុបការជន** : ជនដែលឥតមានឧបការដល់គ្នា។

**អនុបចារ** (បា.សំ.) *គុ.* ដែលមិនមានឧបចារ; ដែលឥតព្រំជាសម្គាល់ :

❖ ដីអនុបចារ

❖ ភូមិអនុបចារ។

**អនុវិច្ឆការ** *ន.* ការពិចារណារួចស្រេចទើបធ្វើ, ការគិតឃើញរួចស្រេចទើបធ្វើអ្វីៗ។

**អនុសញ្ចារ** *ន.* ការដើរស្រួលតាមលំដាប់ឥតរអាក់រអួល; ការត្រាច់ទៅមករឿយៗ។

**អន្តរ** (បា.សំ.) *ន.* ចន្លោះ, រវាង; ដទៃ; រយៈ; ប្រហោង, រូង, រន្ធ; ទោស ភ្លាំងភ្លាត់; ឱកាស; ចំណែកខាងក្នុង; ចិត្ត, វិញ្ញាណ; សំពត់, សំពត់ស្លៀក។

**អបហារ** (បា.សំ.) *ន.* សេចក្តីវិនាស, ដំណើរលាញ; ការប្លន់គេ។

✍ ***អបហារកម្ម*** : ការបំផ្លាញ; ការធ្វើអំពើប្លន់គេ។

**អប្បការ** (បា.) *គុ.* ដែលមានរូបប្រែប្លែកខុសពីប្រក្រតីដើម; ដែលប្រែរូបប្រែទ្រង់ :

❖ ស្គមអប្បការ។

**អប្សរ** (សំ.អប្សរស) *ន.* ស្ត្រីមានសម្បុរថ្លាស្រស់, ស្ត្រីមានសម្បុរផូរផង់ ឬស្ត្រីមានមុខថ្លាស្រស់បំព្រង ស្ត្រីសួគ៌ :

❖ ស្រីអប្សរ

❖ នាងអប្សរ

❖ ស្រីទេពអប្សរ។

**អព្ភន្តរ** (បា.) *ន.* ខាងក្នុង, ប៉ែកខាងក្នុង, ចន្លោះឬរវាងខាងក្នុង; កណ្ដាល, ទីចំពាក់កណ្ដាល។ ឈ្មោះមាត្រារង្វាស់មួយប្រភេទប្រវែង៧ព្យាមគឺ២៨ហត្ថ :

➣ **ចម្ងាយ៧អព្ភន្តរ** : ចម្ងាយ៤៩ព្យាមឬ១៩៦ហត្ថ។

➣ **អព្ភន្តរកិរិយា** : កិរិយាខាងក្នុង គឺកិរិយាក្រិតដែលចុះ អន្ត-បច្ច័យ ឬមានបច្ច័យជាវិសេសនៈនៃនាមនាម (ពាក្យប្រើក្នុង វេយ្យាករណ៍បាលី និងសំស្ក្រឹត)។

➣ **អព្ភន្តរត្ថ** : រូបសេចក្ដីដែលនៅក្នុងអព្ភន្តរសញ្ញា (លេខក្នុង), ដូចជាកាលព្រះសក្យមុនីសម្មាសម្ពុទ្ធទ្រង់ជិតចូលបរិនិព្វានទ្រង់ត្រាស់ផ្ដាំថា អ្នកទាំងឡាយចូរកុំប្រមាទ!។

**អម្ពរ** (បា.សំ.) *ន.* សំពត់; អាកាស។

➣ **កណ្ដាលអម្ពរ** : កណ្ដាលអាកាស។

➣ **គ្រឿងអម្ពរ** : គ្រឿងស្លៀកពាក់។

➣ **អម្ពរគភ៌** : ផ្ទៃអាកាស, ផ្ទៃមេឃ។

**អម្ភោធរ** (សំ.) *ន.* មេឃ, ពពក, ពពកខាប់។

**អមរ** (បា.សំ.) *ន.* ទេវតា។

➣ **អមរកញ្ញា** : ស្ត្រីក្រមុំទេវតា។

➣ **អមរទ្រុម** : ឈើរបស់ទេវតា។

➣ **អមរនិករ** : ពួកទេវតា។

**អរ** *កិ.* មានអំណរ, មានសោមនស្ស, រីករាយចិត្ត, មានចិត្តរីករាយ :

❖ អរព្រោះបានទ្រព្យគាប់ចិត្ត

❖ បានឮថាកូនប្រលងជាប់ខ្ញុំអរណាស់!

**អរសាទរ** : អររីករាយដោយសាទរ។

**អរអេក** : អរខ្លាំងស្មើរភ្លេចខ្លួន, អរភ្លេភ្លា។

**អរគុណ** : អរចំពោះគុណគេ, មានអំណរគុណគេ។

**អលង្ការ** (បា.) *ន.* គ្រឿងប្រដាប់សម្រាប់តាក់តែងខ្លួនមាន ចិញ្ចៀន, កង, ខ្សែដៃ, ខ្សែខ្លួន ជាដើម។

❖ ព្រះមហាក្សត្រទ្រង់តែងព្រះអង្គដោយអលង្ការដ៏បវរអនគ្ឃ...។

**អវក្កុដារ** (សំ.) *គុ.* ដែលមានន័យ, ដែលមានដំណើរ, ដែលមានទំនងផ្សេងគ្នា; ដែលជាទំនាស់នឹងគ្នា, ដែលផ្ទុយគ្នា, ដែលទីទៃពីគ្នា, ដែលផ្សេងគ្នា។

**អវចរ** (បា.សំ.) *ន.* ដំណើរអន្ទោលឬត្រាច់រង្គាត់ទៅមក, ការវិលកើតវិលស្លាប់; ដែន, ខេត្ត, ខេត្តដែន; វិស័យ។

**កាមាវចរ** : ការអន្ទោលកើតស្លាប់ក្នុងកាមភព។

**អវតារ** (បា.សំ.) *ន.* ដំណើរឆ្លងចុះ (ពីមួយទៅមួយជាលំដាប់គ្នា), លំដាប់តៗគ្នា។

**អវសរ** (បា.សំ.) *ន.* ឱកាស; គ្រា, សម័យ, ពេល; ដើមហេតុ។

**អវហារ** (បា.សំ.) *ន.* ការយកដោយថេយ្យចិត្ត, ការលួច។

**អវិជ្ជន្ធការ** (បា.) *ន.* ងងឹតគឺអវិជ្ជា, អវិជ្ជាដែលជាងងឹតសូន្យសុង, សេចក្ដីល្ងង់ខ្លៅខ្លាំង :

❖ សព្វសត្វលោកតែងតែអន្ទោលកើតស្លាប់ក្នុងវាលវដ្ដសង្សារត្រូវអវិជ្ជន្ធការបិទបាំងគំនិតជានិច្ចកាល (ព.ពុ.)។

**អសារ** (បា.សំ.) *គុ.* ដែលឥតខ្លឹម; ដែលឥតប្រយោជន៍, ដែលឥតអំពើ; ដែលមិនកើតការឬដែលមិនបានការ; ដែលមិនខ្ជាប់ខ្ជួន, ដែលមិនរឹងប៉ឹង; ដែលគ្មានតម្លៃ; ដែលមិនពិត, ដែលពុំប្រាកដ; ... (ច្រើនប្រើផ្សំជាមួយនឹងពាក្យ ឥតការ) :

❖ សម្ដីអសារឥតការ

❖ របស់អសារឥតការ។

*កិ.វិ.* ទុកចោលអសារឥតការ, ខូចអសារឥតការ។ ប្រើជា អសារៈ ក៏បាន :

❖ សម្ដីអសារៈ។

✍ **អសារទ្រព្យ** : ទ្រព្យថយថោក, ទ្រព្យឥតតម្លៃ។

✍ **អសារព្រឹក្ស** : ឈើឥតខ្លឹមមានសុទ្ធតែសាច់ស្រាយ។

✍ **អសារវាចា** : សម្ដីឥតសារៈ, សម្ដីឥតសព្វឥតសារ។

✍ **អសារធម្ម** : ធម៌ឥតខ្លឹម, ធម៌ឥតគោលគឺមិច្ឆាប្រតិប័ទ។

✍ **អសារវាទិន** : អ្នកដែលច្រើនតែប្រើសម្ដីឥតសារៈ។

**អសុន្ទរ** (បា.សំ.) *គុ.* ដែលមិនល្អ; ដែលពុំពីរោះ (ព.កា. ប្រើជា អសុន្ទរោ, អសុន្ទរា, អសុន្ទរំ ក៏បាន)។

✍ **អសុទ្ធសទ្ទ** : សូរសព្ទពុំពីរោះ។

✍ **អសុទ្ធវាចា** : សម្ដីពុំពីរោះ; សម្ដីអាក្រក់។

✍ **អសុទ្ធវាទិន** : អ្នកដែលច្រើនតែប្រើសម្ដីអាក្រក់; បើស្ត្រីជា អសុទ្ធវាទិនី។

**អសុរ** (បា.សំ.) *ន.* គំនិតអាក្រក់; វិញ្ញាណជ្រោកជ្រាក។ អមនុស្សពួកមួយ, ទីទៃពីពួកទេវតា, នៅក្នុងអសុរភពមានវេបចិត្តិអសុរិន្ទជាស្ដេច, ជាសត្រូវនៃពួកទេវតានៅឋានត្រ័យត្រិង្ស :

❖ ពួក អសុរ (បើស្ត្រីជា អសុរី ប៉ុន្តែខ្មែរប្រើក្នុងកាព្យសំដៅសេចក្ដីថា "អសុរប្រុស" ឬ "យក្សអង់អាច" ក៏មាន, ជួនប្រើជា អសុរា សំដៅចំពោះអសុរប្រុសច្រើននាក់ឬតែម្នាក់ក៏មាន; ចំពោះយក្សប្រុសច្រើននាក់ឬតែម្នាក់ក៏មាន)។

**អាករ** (បា.សំ.) *ន.* គំនរ; ពួក, ក្រុម; លោហធាតុផ្សេងៗ; កំណើតលោហធាតុផ្សេងៗ, កំណើតត្បូងផ្សេងៗ។

*ន.* ល្អលើសលន់, ល្អកន្លង។ ខ្មែរប្រើពាក្យនេះសំដៅសេចក្ដីថា ស្ួយ, តង្វាយ, ជំនូន; ប្រាក់ពន្ធ :

❖ ស្ួយអាករឬស្ួយសារអាករ។

✍ **អាករដ្ឋាន** : ទីដែលមានត្បូង, ទីមានលោហធាតុ។

✍ **អាករខនិក** : អ្នកជីករកត្បូង (បើស្ត្រីជា អាករខនិកា)។

✍ **អាករវិទ** : អ្នកស្គាល់ត្បូង, អ្នកស្គាល់កន្លែងកើតត្បូង។

**អាការ** (បា.សំ.) *ន.* គ្រឿងសម្គាល់, លក្ខណៈជាគ្រឿងសម្គាល់, លក្ខណៈជាគ្រឿងសង្កេត; រូបរាង, ទ្រង់ទ្រាយ; ភិនភេទ, ភិនភាគ; វិធី, បែបបទ, បែបភាព, លំនាំ; ទំនង; ឫកពា, កិរិយា; សភាព; គុណសម្បត្តិ :

- **អាការរោគ** : ចេញអាការៈឱ្យដឹងថាល្អឬអាក្រក់។
- **អាការកិរិយា** : ឫកពាកិរិយា, លំនាំសមសារ។

**អាគារ** (បា.) *ន.* អ្នកដែលមានផ្ទះឬអ្នកដែលមានប្រយោជន៍ដោយផ្ទះសំបែង (គ្រហស្ថ)។

**សំ. អាគារ** ប្រែត្រឹមតែថា "ផ្ទះ" ដូចជា អគារ ដែរក៏មាន។

- **អាគារធម៌** : ធម៌សម្រាប់គ្រហស្ថ។
- **អាគារវិន័យ** : វិន័យសម្រាប់គ្រហស្ថ, ច្បាប់គ្រហស្ថ...។

**អាចារ** (បា.សំ.) *ន.* ការប្រព្រឹត្ត, ចរិយា; ឫក, ឫកពា, មារយាទ, ឫកមារយាទ; បែបបទ, សណ្ដាប់ធ្នាប់ :

- មានអាចារល្អ
- មានអាចារពុំគួរសម។

- **អាចារកុសល** : អ្នកដែលឈ្លាសក្នុងការរក្សាមារយាទឱ្យល្អ។
- **អាចារវិន័យ** : ច្បាប់សម្រាប់រក្សាមារយាទឱ្យល្អ, ឱ្យត្រឹមត្រូវ។
- **អាចារសម្បត្តិ** : ការបរិបូណ៌ដោយមារយាទល្អ គឺដំណើរមានមារយាទល្អ, ដំណើរមានមារយាទត្រឹមត្រូវ។

**អាឧម្ពរ** ឬ **អាឡម្ពរ** (សំ. ឬ បា.) *ន.* ស្គរធំសម្រាប់វាយឱ្យឮខ្លាំងជាអាណត្តិសញ្ញាក្នុងកាលដែលមានមហាភ័យក្នុងក្រុង ដូចយ៉ាងភ្លើងឆេះផ្ទះច្រើនក្នុងក្រុងឬមានទ័ពលុកចូលក្រុងជាដើម (ស្គរនេះគេដាក់តែនៅទីខ្ពស់ស្រឡះត្រង់កណ្ដាលក្រុង); ស្គរសម្រាប់វាយភ្ជុំកងទ័ព, ស្គរទ័ព។

✍ **អាឧម្ពរសព្ទ** : សូរអាឧម្ពរ (ស្គរធំនោះ)។

✍ **អាឧម្ពរសញ្ញា** : ការចំណាំដោយឮសូរស្គរអាឧម្ពរ។

**អាឍ្យចរ** (សំ.) *គុ.* ដែលធ្លាប់មានទ្រព្យស្ដុកស្ដម្ភពីដើមមក គឺដែលធ្លាប់តែមានទ្រព្យស្ដុកស្ដម្ភមាំមួនច្រើនតំណមកហើយ :

- ❖ ត្រកូលអាឍ្យចរ
- ❖ ពូជពង្សអាឍ្យចរ។

**អាតុរ** (បា.សំ.) *គុ.* ដែលក្ដៅអន្ទះអន្ទែង; ដែលមានជំងឺ, ដែលឈឺ; ដែលមានជំងឺគ្រុនក្ដៅខ្លាំង។

*ន.* ជំងឺ; ជំងឺក្ដៅ, ជំងឺគ្រុនក្ដៅខ្លាំង។

✍ **អាតុរមន្ទីរ** : មន្ទីរពេទ្យ។

✍ **អាតុរភាព** : ភាពនៃជំងឺ, ភាពនៃជំងឺគ្រុនក្ដៅខ្លាំង។

✍ **អាតុររូប** : ដែលមានសភាពជាអ្នកឈឺ, ដែលកំពុងមានជំងឺ។

**អាទរ** (បា.សំ.) *ន.* សេចក្ដីអើពើ, ការគោរព; ការយកចិត្តទុកដាក់; ការប្រុងប្រយត្ន; ការស្រវាស្រទេញ, ការនាំពា។

✍ **អាទរប្រតិបត្តិ** : ប្រតិបត្តិដោយយកចិត្តទុកដាក់។

**អាធារ** (បា.សំ.) *ន.* ប្រដាប់សម្រាប់រង, ប្រដាប់សម្រាប់ទ្រ, គ្រឿងទ្រ; ការទំនុកបម្រុង, ការគាំទ្រ; ការរ៉ាប់រង; សេចក្តីធន់ទ្រាំ, សេចក្តីទ្រាំទ្រ; អាងទឹក, ពាងទឹក; កន្លែងដែលទប់ខាំងទឹក, ស្រះទឹក; ទីដីមានជីជាតិល្អ។

*កិ.* ធន់ទ្រាំ, ទ្រាំទ្រ; រ៉ាប់រង :

❖ គ្មានអ្នកណានឹងអាធារចិញ្ចឹមវាទេ!។

**អាភស្សរ** (បា.) *ន.* ឈ្មោះព្រហ្មលោកជាន់ទី៦ក្នុងឋានរូបព្រហ្ម១៦ជាន់ :

❖ ឋានអាភស្សរ។

☙ ***អាភស្សរព្រហ្ម*** : ពួកព្រហ្មដែលកើតនៅក្នុងឋាននោះ។

**អាមាតិសារ** (បា.សំ.) *ន.* ជំងឺមួល, ជំងឺមួលឈាម, ជំងឺមួល (ព្រោះទាស់ចំណីណាមួយមានអាហារឆៅជាដើម)។

**អារ** *កិ.* កាត់, បំបែក, ច្រៀក, កាត់ផ្តាច់, តម្រឹមដោយរណារ :

❖ អាររំលំ

❖ អារច្រៀក

❖ អារបំបែក។

☞ កាត់ពន្លះ, លឿយ, កាត់ផ្តាច់ដោយសស្ត្រាមានកាំបិតជាដើម :

❖ អារពន្លះស្បែក។

*ឆ្ងុ.* ដែលកាត់ផ្តាច់ប្រយោជន៍ដែលខ្លួនត្រូវបាន គឺប្រយោជន៍ខាងការបន្តពូជពង្សនិងមាតាបិតុបដ្ឋាន។ អារនេះជាពាក្យហៅគូស្វាមីភរិយាដែល

ឥតកូនគឺដែលមិនធ្លាប់មានកូនសោះ, ហៅថា ស្រីអារ, ប្រុសអារ, អារនាំង ពីរនាក់ប្ដីប្រពន្ធ, មេគោអារ។

**អាសូរ** *កិ.* អាណិតទន់ចិត្ត, អាណិតជាប់ចិត្ត, អាណិតខ្លោចចិត្ត :

❖ ឃើញកូនតូចៗកំព្រីកំព្រាអនាថាគួរឱ្យអាសូរពេកណាស់។

✍ **អាសូរករុណា** : អាណិតក្រៃពេក។

**អាហារ** (បា.សំ.) *ន.* គ្រឿងសម្រាប់បរិភោគចម្អែតអាត្មា, ភោជន :

❖ ចម្អិនអាហារ

❖ បរិភោគអាហារ។

✍ **អាហារកិច្ច** : ការចាត់ចែងអាហារ, ការបរិភោគអាហារ។

✍ **អាហារគវេសនា** : ការស្វែងរកអាហារ។

✍ **អាហារបញ្ជី** : បញ្ជីរាយរាប់មុខម្ហូបដែលដាក់បង្ហាញភ្ញៀវ។

✍ **អាហារបិណ្ឌបាត** : អាហារដែលបានដោយការដើរបិណ្ឌបាត។

✍ **អាហារូបករណ៍** : គ្រឿងឧបករណ៍ដើម្បីអាហារ; ប្រាក់ដែលបើក ឱ្យនិស្សិតដើម្បីទំនុកបម្រុងឬទប់ទល់នឹងថ្លៃអាហារក្នុងពេលកំពុងរៀនសូត្រ។

✍ **អាហារូបករណិក** : អ្នកដែលបានទទួលនូវអាហារូបករណ៍ (បើ ស្ត្រីជា អាហារូបករណិកា)។

✍ **អាហារូបត្ថម្ភ** : ការជួយទំនុកបម្រុងដោយអាហារ; ការចិញ្ចឹម ជីវិតដោយអាហារ។

> **បណីតាហារ** : អាហារប្រណីត, អាហារឆ្ងាញ់ពិសា។

> **ភោជនាហារ** : ភោជនជាអាហារ។

> **លូខាហារ** : អាហារសៅហ្មង។

**ឥសុការ** (សំ.) *ន.* អ្នកធ្វើព្រួញ; អ្នកធ្វើគ្រឿងបាញ់គ្រប់យ៉ាង (មាន ធ្នូ, ស្នា ជាដើម ព្រមទាំង សរ គឺព្រួញនិងគ្រាប់សម្រាប់បាញ់ផង)។

> **ឥសុការស្ថាន** : កន្លែងធ្វើគ្រឿងបាញ់។

**ឥស្សរ** (សំ. ឈ្មើ្សរ) *គុ.* ដែលជាធំ, ដែលជាចម្បង, ដែលជាកំពូលលើគេ, ដែលជាម្ចាស់លើគេ :

> **ចង្សពុទ្ធង្គរ** : ឥស្សរកំពូលលើអស់អ្នកផងគោរពមាតាកុំឱ្យមានហ្មងពុំដែលកន្លងទសពិធធម៌ថ្លៃ។

*ន.* ព្រះសិវៈ; អ្នកធំ; អ្នកដែលជាចម្បងលើសអស់អ្នកផង, ម្ចាស់លើគេ, ម្ចាស់ផែនដី (ក្សត្រទ្រង់រាជ្យ); ចៅហ្វាយធំ។

> **ព្រះឥស្សរ** : ព្រះសិវៈ (ព្រះឥស្សរឬព្រះសិវៈនេះជាទេវតាឬជាព្រះសក្តិសិទ្ធិវិសេសមួយអង្គរបស់ពួកព្រាហ្មណិក)។

## ពាក្យកាព្យ

ឥស្សរនារាយណ៍និងព្រះព្រហ្ម  អ្នកជឿនិយមថាសក្តិសិទ្ធិ
ឯព្រះសម្ពុទ្ធទ្រង់ពិនិត្យ  ឃើញថាការណ៍ពិតផ្សេងទៅវិញ។
ទ្រង់ឃើញអដ្ឋង្គិកមគ្គ  ជាផ្លូវជៀងជាក់ត្រង់រលេញ
ទើបលះចោលផ្លូវអមខាងចេញ  ចំណេញបានត្រាស់ពោធិញ្ញាណ។

☞ ខ្មែរសម័យបុរាណប្រើពាក្យ ឥស្វរ ឬ ឦស្វរ នេះជាគោរមព្រះបរមនាមនៃក្សត្រទ្រង់រាជ្យក្នុងរជ្ជកាលខ្លះក៏មាន, ដូចជា ក្សត្រយេស្វរ, បរមេស្វរ (តមកក្លាយជា បរមីស្វរ ក៏មាន) រាមេស្វរ, នរេស្វរ ជាដើម; ប្រើជាឋានន្តរមន្ត្រីក៏មាន, ដូចជា ពិពិធឦស្វរ, ឥស្វរមេត្រី, ឥស្វរសម្បត្តិ ជាដើម។

**ឥស្សរ** (បា.) *គុ.* ឬ *ន.* ឥស្សរ។

- **ឥស្សរចិត្ត** : ដំណើរស្រេចនឹងចិត្ត។
- **ឥស្សរជន** : ជនជាឥស្សរៈ (អ្នកធំ)។
- **ឥស្សរបុគ្គល** : បុគ្គលជាឥស្សរៈ (អ្នកធំ)។
- **ឥស្សរភាព** : ភាពនៃអ្នកធំ; ភាវៈជាឥស្សរៈ។
- **ឥស្សរសព្ទ** : ពាក្យសម្រាប់និយាយទៅរកឥស្សរជន។
- **ឥស្សរាធិបតី** : អធិបតីនៃពួកឥស្សរជន។
- **ឥស្សរានុភាព** : អានុភាពនៃអ្នកធំ...។

**ឦសធរ** (បា.) *ន.* ឈ្មោះភ្នំមួយក្នុងពួកភ្នំសត្តបរិភណ្ឌ (ហៅ ឥសិន្ធរ ក៏បាន ខ្មែរប្រើពាក្យនេះជាងថា ភ្នំឥសិន្ធរ)។

**ឧច្ចារ** ឬ **ឧច្ចារៈ** (បា.សំ.) *ន.* លាមក, វច្ចៈ (ព.សា. អាចម៍) :

- **ទល់ឧច្ចារៈ** : ទល់លាមក។
- **បន្ទោឧច្ចារៈ** : បត់ជើងធំ។
- **ឧច្ចារកិច្ច** : កិច្ចដោយឧច្ចារៈ គឺការបន្ទោឧច្ចារៈ។
- **ឧច្ចារដ្ឋាន** : ទីសម្រាប់បន្ទោឧច្ចារៈ; បង្គន់បត់ជើងធំ។

✍ **ឧច្ចារមគ្គ** : ទ្វារបាត, ទ្វារធំ។

✍ **ឧច្ចាររោគ** : រោគរាករូស; រោគដែលបណ្ដាលពីឧច្ចារៈ។

**ឧត្តរ** (**បា.សំ.**) ***គុ.*** ឬ ***ន.*** ខ្ពស់; លើ; ឆ្វេង; ក្រោយ; ខាងលើ; ខាងខ្ពស់; ខាងជើង; ខាងឆ្វេង; ខាងចុង; ខាងក្រោយ :

✍ **ទិសឧត្តរ** : ទិសខាងជើង។

✍ **ឧត្តរកាល** : អនាគតកាល។

✍ **ឧត្តរកុរុទ្វីប** : ឈ្មោះមហាទ្វីបមួយនៅទិសាភាគខាងជើងភ្នំសិនេរុ។

✍ **ឧត្តរនិកាយ** : ពួកខាងជើង គឺពួកពុទ្ធសាសនិកខាងលទ្ធិមហាយាន។

✍ **ឧត្តរប័ង** : សំពត់សម្រាប់ពានាឬសំពត់បង់ក, សំពត់ដណ្ដប់។

**ឧទរ** (**បា.សំ.**) ***ន.*** ពោះ, ផ្ទៃ។ (**រ.ស.**) ព្រះឧទរ។ ប្រើជាឥស្សរសព្ទនិងសមណសព្ទក៏បាន :

❖ ព្រះតេជព្រះគុណមិនស្រួលសប្បាយឧទរ (កុំប្រើពាក្យ ព្រះ)។

☞ ប្រើដូចជា ***គុ.*** ក៏បាន

✍ **របរឧទរការណ៍** : របរគ្រាន់តែចម្អែតពោះ។

✍ **ឧទរបាត្រ** : ក្រពះ។

✍ **ឧទរប្បមាណ** : ការស្មានឬស្ទង់ឱ្យល្មមតែមួយចម្អែត។

✍ **អាហារឧទរប្បមាណ** : អាហារមានចំនួនត្រឹមតែមួយចម្អែត។

✍ **ឧទររោគ** ឬ **ឧទរាពាធ** : រោគឈឺពោះ, ជំងឺឈឺពោះ។

**ឧទុម្ពរ** (បា.សំ.) *ន.* ល្វា :

❖ ឧទុម្ពរជាពួកវនស្បតិព្រឹក្ស, គេតែងយកឈើឧទុម្ពរមកធ្វើជារាជាសនៈក្នុងព្រះរាជពិធីរាជាភិសេកតាមរជ្ជប្បវេណីយូរអង្វែងមកហើយ។

**ឧបការ** (បា.សំ.) *ន.* ការទំនុកបម្រុង, ការផ្គត់ផ្គង់, ការផ្គុងផ្តើម; ការអនុលោមតាម; ប្រយោជន៍, គុណប្រយោជន៍ :

❖ មាតាបិតាមានឧបការច្រើនចំពោះបុត្រធីតាៗត្រូវធ្វើបដិការចំពោះមាតាបិតាវិញ។

**ឧបចារ** (បា.សំ.) *ន.* ការចូលជិត; ទីជិត; ព្រំ; ខេត្ត :

- **ឧបចារកិរិយា** : សណ្តាប់ធ្នាប់គួរសម, ឫកពាត្រឹមត្រូវ។
- **ឧបចារបទ** : ពាក្យគួរសម, សម្តីមានច្បាប់។
- **ឧបចារវត្ត** : ព្រំវត្ត (អារាមូបចារ)។
- **ឧបចារសមាធិ** : សមាធិដែលជិតដល់អប្បនា (ព.ពុ.)។

**អុរ** *កិ.វិ.* ឬ *គុ.* ដែលធ្លាក់ភ្លៀងខ្លាំង :

- **ភ្លៀងអុរ** : ភ្លៀងខ្លាំង, ភ្លៀងធំ។

*ន.* មុខមាត់ដែលទើបភ្ញាក់ពីដេកមិនទាន់លុបលាងជម្រះនៅឡើយ :

❖ ទឹកមាត់អុរ

❖ ឈ្មោះទាំងអុរ។

*កិ.វិ.* ឬ *គុ.* ថ្នាំអុរ ថ្នាំសម្រាប់ប្រើទាំងអុរ។

**ឧសុការ** (បា.) *ន.* អ្នកធ្វើព្រួញ; អ្នកធ្វើគ្រឿងបាញ់គ្រប់យ៉ាង (មាន ធ្នូ, ស្នា ជាដើមព្រមទាំងសរគឺ ព្រួញ និង គ្រាប់ សម្រាប់បាញ់ផង)។

**ឧសុការដ្ឋាន** : កន្លែងធ្វើគ្រឿងបាញ់។

**ឧឡារ** (បា.) *គុ.* ខ្ពស់, ខ្ពង់ខ្ពស់; ថ្លៃ, មានតម្លៃ; ថ្លៃថ្លា; ថ្កើង, ថ្កើងថ្កាន, ថ្កុំថ្កើង; រុងរឿង; ឧត្តម, ប្រសើរ; អធិកអធម; លើសលន់; បរិបូណ៌, ច្រើន។

**ឧឡារកម្ម** : អំពើខ្ពង់ខ្ពស់, កិច្ចការខ្ពង់ខ្ពស់។

**ឧឡារចរិត** : អ្នកដែលមានឫកខ្ពស់, អ្នកដែលមានឫកថ្លៃ។

**ឧឡារបូជា** : ការបូជាដ៏លើសលន់។

**ឧឡារពលី** : ពលិការដ៏លើសលុប។

**ឧឡារភណ្ឌ** : របស់មានតម្លៃ។

**ឧឡារភាព** : ភាពខ្ពស់, ភាពឧត្តម។

**ឧឡារមេធា** : ប្រាជ្ញាខ្ពស់, ប្រាជ្ញាឆើត។

**ឧឡារមេធី** : អ្នកមានប្រាជ្ញាខ្ពស់ (បើស្ត្រីជា ឧឡារមេធិនី)។

**អូរ** *ន.* ជ្រលងជាផ្លូវទឹកដែលក្នុងរដូវភ្លៀងមានទឹកហូរចូលមកក្នុងនទីឬក្នុងបឹង, ក្នុងសមុទ្រ :

- ទឹកអូរតូចធំហូរប្រជុំចុះមកក្នុងនទី។

**អ៊ូអរ** *កិ.វិ.* ឈូឆរដោយមានអំណរ, ឈូឆរដោយស្រុះស្រួល :

- បងប្អូនមកជួបជុំអ៊ូអរពេញផ្ទះ។

**អំណារ** *ន.* សេចក្ដីអរ :

❖ មានអំណរ (កុំប្រើថា សេចក្ដីអំណរ ព្រោះពាក្យនេះជានាមទាមប្រាប់ដំណើររបស់កិរិយាសព្ទ អរ ស្រេចហើយ; បើចង់ប្រើពាក្យថា សេចក្ដី ត្រូវថាមាន សេចក្ដីអរ ក៏គឺ មានអំណរ ហ្នឹងឯង)។

**អំបូរ** *ន.* ពូជ, ពូជពង្ស; វង្ស, ត្រកូល :

❖ អំបូរខ្ពស់

❖ អំបូរក្សត្រ។

**អំពៀរ** *កិ.* ឬ *កិ.វិ.* ដើរសសៀរគន់មើលម្ដងៗ; សសៀរមមៀរងាកនាយងាកអាយ :

❖ ដើរអំពៀរ

❖ ដោះអំពៀរ

❖ អំពៀរក្បែររបងផ្ទះ។

## គន្ថនិទ្ទេស


១- អៀវ-កើស ភាសាខ្មែរ

២- ហ៊ីង-ធីឫទ្ធិ អត្ថាធិប្បាយវចនានុក្រមច្បាប់

៣- រស់-ឆោម គន្លឹះអនុពាក្យ សម្គាល់ពាក្យខ្មែរនិងចំណាំអក្សរ រ

៤- សទ្ទានុក្រមពាក្យច្បាប់និងរដ្ឋបាល (អង់គ្លេស-បារាំង-ខ្មែរ)

៥- វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ ការផ្សាយនៃវិទ្យាស្ថានភាសាជាតិ

៦- វចនានុក្រមខ្មែរ KHMER DICTIONARY ការផ្សាយបណ្ណាគារអង្គរធំ ព.ស. ២៥៥៥ គ.ស. ២០១១

៧- ជួន-ណាត វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ ព.ស. ២៥១១- ២៥១២ គ.ស. ១៩៦៧-១៩៦៨។

៨- ច័ន្ទ សំណព្វ (១៩៩៩) វិជ្ជមានន័យ អវិជ្ជមានន័យ និងបរិធាតុរបស់វា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៩- ច័ន្ទ សំណព្វ (២០០២) គោលការណ៍នៃការបង្កើតពាក្យនិងកម្ចីពាក្យ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១០- ច័ន្ទ សំណព្វ (២០០៣) ធាតុវេយ្យាករប្រើសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១១- ច័ន្ទ សំណព្វ (២០០៦) ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ : តួនាទីនៃបុរេបទ ការ និងផ្នត់ជែក [-អ់ម/ណា-] / [-អ៊់ម/ន-] សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## ជីវប្រវត្តិ

ខ្ញុំ **នួច-តីមស្រ៊ាង** កើតនៅឆ្នាំ១៩៧៤ នៅក្នុងភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ ជាកូនទី៥ ក្នុងចំណោមបងប្អូនប្រុសស្រី៦នាក់ ស្រី៤ ប្រុស២

ឪពុកឈ្មោះ **ទ៊ី-យ៉េន** ស្លាប់

ម្ដាយឈ្មោះ **អ៊ី-មាស** ស្លាប់

## ការសិក្សា

២០០៩ បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យខេមរៈ

២០០៧ បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យបៀលប្រាយ

២០០៣ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

២០០១ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ នៅពុទ្ធិកវិទ្យាល័យសម្ដេច **ជួន-ណាត**

១៩៩៦ ពុទ្ធិកបឋមសិក្សាវត្តសុន្ទរវង្ស ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ

១៩៨០ សាលាបឋមសិក្សាភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ

## មុខតំណែងនិងការងារ

សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការភាសាវិទ្យាខ្មែរនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការនៃការបង្កើតពាក្យនិងកម្ពីពាក្យនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការអក្ខរាវិរុទ្ធនិងអំណាននៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ប្រធានសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរនៃវត្តខ្ទុណ្ណាលោម

ISBN-13 : 978-99963-705-7-1

9 789996 370571